# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្តីប្រែភាសាខ្មែរ
# សុត្តន្តបិដក
## សំយុត្តនិកាយ មហាវារវគ្គ
## នវមភាគ
# ៣៧

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៤៩៦

សុត្តន្តបិដក

សំយុត្តនិកាយ មហាវារវគ្គ

នវមភាគ

៣៧

# សុត្តន្តបិដកេ

## សំយុត្តនិកាយស្ស មហាវារវគ្គោ

## នវមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### អវិជ្ជាវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ។

# សុត្តន្តបិដក

## សំយុត្តនិកាយ មហាវារវគ្គ

## នវមភាគ

---

*សូមនមស្ការព្រះដ៏មានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

### អវិជ្ជាវគ្គ

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលថា ។

(២) អវិជ្ជា ភិក្ខវេ បុព្វង្គមា អកុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ អហិរិកំ អនោត្តប្បំ ។ អវិជ្ជាគតស្ស ភិក្ខវេ អវិទ្ទសុនោ មិច្ឆាទិដ្ឋិ បហោតិ មិច្ឆាទិដ្ឋិស្ស មិច្ឆាសង្កប្បោ បហោតិ មិច្ឆាសង្កប្បស្ស មិច្ឆាវាចា បហោតិ មិច្ឆាវាចស្ស មិច្ឆាកម្មន្តោ បហោតិ មិច្ឆាកម្មន្តស្ស មិច្ឆាអាជីវោ បហោតិ មិច្ឆាអាជីវស្ស មិច្ឆាវាយាមោ បហោតិ មិច្ឆាវាយាមស្ស មិច្ឆាសតិ បហោតិ មិច្ឆាសតិស្ស មិច្ឆាសមាធិ បហោតិ ។

(៣) វិជ្ជា ច ខោ ភិក្ខវេ បុព្វង្គមា កុសលានំ ធម្មានំ សមាបត្តិយា អន្វទេវ ហិរោត្តប្បំ ។ វិជ្ជាគតស្ស ភិក្ខវេ វិទ្ទសុនោ សម្មាទិដ្ឋិ បហោតិ សម្មាទិដ្ឋិស្ស សម្មាសង្កប្បោ បហោតិ សម្មាសង្កប្បស្ស សម្មាវាចា បហោតិ សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ



(២) ម្នាលភិក្ខុទាំងឡាយ អវិជ្ជាជាប្រធាននៃអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីញ៉ាំងសេចក្តីមិនខ្មាសបាបនឹងមិនខ្លាចបាបឲ្យកើតឡើងជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ឃើញខុស រមែងកើតឡើងដល់បុគ្គលល្ងង់ខ្លៅ ប្រកបដោយអវិជ្ជា សេចក្តីត្រិះរិះខុស កើតឡើងដល់បុគ្គលមានសេចក្តីយល់ឃើញខុស វាចាខុស កើតឡើងដល់បុគ្គលមានសេចក្តីត្រិះរិះខុស ការងារខុស កើតឡើងដល់បុគ្គលមានវាចាខុស ការចិញ្ចឹមជីវិតខុស កើតឡើងដល់បុគ្គលមានការងារខុស ការព្យាយាមខុស កើតឡើងដល់បុគ្គលមានការចិញ្ចឹមជីវិតខុស ការរឭកខុស កើតឡើងដល់បុគ្គលមានព្យាយាមខុស ការតាំងចិត្តមាំខុស កើតឡើងដល់បុគ្គលមានការរឭកខុស ។

(៣) ម្នាលភិក្ខុទាំងឡាយ ឯវិជ្ជាជាប្រធាននៃកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីញ៉ាំងសេចក្តីខ្មាសបាបនឹងសេចក្តីខ្លាចបាបឲ្យកើតឡើងជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ឃើញត្រូវ រមែងកើតឡើងដល់បុគ្គលអ្នកដឹងច្បាស់ ប្រកបដោយវិជ្ជា សេចក្តីត្រិះរិះត្រូវ កើតឡើងដល់បុគ្គលមានសេចក្តីយល់ឃើញត្រូវ វាចាត្រូវ កើតឡើងដល់បុគ្គលមានសេចក្តីត្រិះរិះត្រូវ ការងារត្រូវ កើតឡើងដល់បុគ្គលមានវាចាត្រូវ

សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ សម្មាវាយាមស្ស សម្មាសតិ បហោតិ សម្មាសតិស្ស សម្មាសមាធិ បហោតីតិ ។

(៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ[១] វិហរតិ សក្ករំ នាម សក្យានំ និគមោ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឧបឌ្ឍមិទំ ភន្តេ ព្រហ្មចរិយស្ស យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតាតិ ។

---

១ សក្កេសូតិ [illegible] ។



ការចិញ្ចឹមជីវិតត្រូវ កើតឡើងដល់បុគ្គលមានការងារត្រូវ ការព្យាយាមត្រូវ កើតឡើងដល់បុគ្គលមានការចិញ្ចឹមជីវិតត្រូវ ការរឭកត្រូវ កើតឡើងដល់បុគ្គលអ្នកមានព្យាយាមត្រូវ ការតាំងចិត្តមាំត្រូវ កើតឡើងដល់បុគ្គលអ្នកមានការរឭកត្រូវ ។

(៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគមរបស់ពួកសក្យៈ ក្នុងដែនសក្យៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គុណជាតឯណា គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានទេក្ខល្អ គុណជាតនេះ ជាពាក់កណ្តាលនៃព្រហ្មចរិយធម៌ ។

(៤) មា ហេវំ អានន្ទ អវច មា ហេវំ អានន្ទ អវច សកលមេវ ហិទំ អានន្ទ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតា ។ កល្យាណមិត្តស្សេតំ អានន្ទ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេស្សតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករិស្សតីតិ ។

(៥) កថញ្ចានន្ទ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធានន្ទ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ សម្មាសង្កប្បំ ភាវេតិ វិវេកនិស្សិតំ ។ បេ ។ សម្មាវាចំ ភាវេតិ ។ បេ ។ សម្មាកម្មន្តំ ភាវេតិ ។ បេ ។ សម្មាអាជីវំ ភាវេតិ ។ បេ ។ សម្មាវាយាមំ ភាវេតិ ។ បេ ។ សម្មាសតឹ ភាវេតិ ។ បេ ។



(៤) ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ គុណជាតឯណា គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានគ្នេល្អ គុណជាតនេះឯង ជារ់ ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯង ត្រូវដល់ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានគ្នេល្អ នឹងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

(៥) ម្នាលអានន្ទ ចុះភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានគ្នេល្អ ចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចំរើននូវសម្មាសង្កប្បៈ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ។ បេ ។ ចំរើននូវសម្មាវាចា ។ បេ ។ ចំរើននូវសម្មាកម្មន្តៈ ។ បេ ។ ចំរើននូវសម្មាអាជីវៈ ។ បេ ។ ចំរើននូវសម្មាវាយាមៈ ។ បេ ។ ចំរើននូវសម្មាសតិ ។ បេ ។

សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោ-ធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ អានន្ទ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណ-សម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

(៧) តទមិនាបេតំ អានន្ទ បរិយាយេន វេទិតព្វំ យថា សកលមេវិទំ ព្រហ្មចរិយំ យទិទំ កល្យាណ-មិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតា-តិ ។ មមញ្ហិ អានន្ទ កល្យាណមិត្តំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ សោ-កបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោក-បរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ ។ ឥមិនា ខោ ឯតំ អានន្ទ បរិយាយេន វេទិតព្វំ យថា ស-កលមេវិទំ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតាតិ ។



ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅ ដើម្បីលះបង់ ។ ម្នាលអានន្ទ ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានគ្នីល្អ ចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

(៧) ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្ដីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានគ្នីល្អ ។ ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន ពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្ដីនុ៎ះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានគ្នីល្អ ។

[៤] សាវត្ថីនិទានំ ។ អថខោ អាយស្មា សារិបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច សកលមិទំ ភន្តេ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតា ។

[៥] សាធុ សាធុ សារីបុត្ត សកលមិទំ សារីបុត្ត ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតា ។ កល្យាណមិត្តស្សេតំ សារីបុត្ត ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេស្សតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករិស្សតីតិ ។



[៤] សាវត្ថីនិទាន ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានក្ញើល្អ ។

[៥] ម្នាលសារីបុត្ត ប្រពៃណាស់ហើយ ម្នាលសារីបុត្ត នេះហើយជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានក្ញើល្អ ។ ម្នាលសារីបុត្ត ព្រហ្មចរិយធម៌នេះ ប្រាកដដល់ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានក្ញើល្អ គឺនឹងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

(១០) កថញ្ច សារីបុត្ត ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ សារីបុត្ត ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ សារីបុត្ត ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

(១១) តទមិនាបេតំ សារីបុត្ត បរិយាយេន វេទិតព្វំ យថា សកលមិទំ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតា ។ មមញ្ហិ សារីបុត្ត កល្យាណមិត្តំ អាគម្ម ជាតិធម្មា សត្តា ជាតិយា បរិមុច្ចន្តិ ជរាធម្មា សត្តា ជរាយ បរិមុច្ចន្តិ មរណធម្មា សត្តា មរណេន បរិមុច្ចន្តិ



(១០) ម្នាលសារីបុត្ត ចុះភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានគ្នើល្អ តែងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។បេ។ ចំរើននូវសម្មាសមាធិដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលសារីបុត្ត ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានគ្នើល្អ តែងចំរើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

(១១) ម្នាលសារីបុត្ត អ្នកគប្បីដឹងនូវសេចក្តីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ នឹងការមានគ្នើល្អ ។ ម្នាលសារីបុត្ត ព្រោះអាស្រ័យនូវតថាគតជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន

សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា សត្តា សោ-កបរិទេវទុក្ខទោមនស្សុបាយាសេហិ បរិមុច្ចន្តិ ។ ឥមិ-នា ខោ ឯតំ អានន្ទ បរិយាយេន វេទិតព្វំ យថា សកលមិទំ ព្រហ្មចរិយំ យទិទំ កល្យាណមិត្តតា កល្យាណសហាយតា កល្យាណសម្បវង្កតាតិ ។

(១៤) សាវត្ថីនិទានំ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ ជាណុស្សោណឹ ព្រាហ្មណំ សព្វសេតេន វឡវាភិរថេន សាវត្ថិយា និយ្យាយន្តំ សេតា សុទំ អស្សា យុត្តា ហោន្តិ សេតាលង្ការា សេតោ រថោ សេតបរិវារោ សេតា រស្មិយោ សេតា បតោទលដ្ឋិ សេតំ ឆត្តំ សេតំ ឧណ្ហីសំ សេតានិ វត្ថានិ សេតា ឧបាហនា សេតាយ សុទំ វាលវីជនិយា វីជិយតិ ។ តមេនំ ជនោ ទិស្វា ឯវមាហ ព្រហ្មំ វត ភោ យានំ ព្រហ្មយានរូបំ វត ភោតិ ។



ពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនុ៎ះដោយបរិយាយនេះចុះថា នេះហើយជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសំឡាញ់ល្អ និងការមានគ្នេល្អ ។

(១៤) សាវត្ថីនិទាន ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ ព្រះអានន្ទដ៏មានអាយុបានឃើញព្រាហ្មណ៍ឈ្មោះជាណុស្សោណិ បររថទឹមមេសេះសសុទ្ធ ចេញអំពីក្រុងសាវត្ថីទៅ ជាណុស្សោណិព្រាហ្មណ៍ ទឹមសេះស មានគ្រឿងប្រដាប់ស រថស មានគ្រឿងបំពាក់ស ខ្សែស ជន្លួញស ឆ័ត្រស ឈ្នួតក្បាលស សំពត់ស ស្បែកជើងស គេបក់ដោយផ្លិតរោមសត្វស ។ ជនបានឃើញជាណុស្សោណិព្រាហ្មណ៍នោះហើយ ក៏ពោលយ៉ាងនេះថា អើហ្ន៎ ប្រសើរពេកណាស់ អើហ្ន៎ យានមានសភាពដូចជាយានរបស់ព្រហ្ម ។

## អវិជ្ជាវគ្គោ

(១៣) អថខោ អាយស្មា អានន្ទោ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹ អទ្ទសំ ខ្វាហំ ភន្តេ ជាណុស្សោណឹ ព្រាហ្មណំ សព្វសេតេន វឡវាភិរថេន សាវត្ថិយា និយ្យាយន្តំ សេតា សុទំ អស្សា យុត្តា សេតាលង្ការា សេតោ រថោ សេតបរិវារោ សេតា រស្មិយោ សេតា បតោទលដ្ឋិ សេតំ ឆត្តំ សេតំ ឧណ្ហីសំ សេតានិ វត្ថានិ សេតា ឧបាហនា សេតាយ សុទំ វាលវីជនិយា វីជិយតិ ។ តមេនំ ជនោ ទិស្វា ឯវមាហ ព្រហ្មំ វត ភោ យានំ ព្រហ្មយានរូបំ វត ភោតិ ។ សក្កា នុ ខោ ភន្តេ ឥមស្មឹ ធម្មវិនយេ ព្រហ្មយានំ បញ្ញបេតុន្តិ ។



## អវិជ្ជាវគ្គ

(១៣) គ្រានោះ ព្រះអានន្ទដ៏មានអាយុត្រាច់ទៅក្នុងក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រឡប់មកអំពីបិណ្ឌបាតវិញក្នុងកាលជាខាងក្រោយនៃភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងថ្ងៃណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញជាណុស្សោណិព្រាហ្មណ៍ បររថទឹមដោយមេសេះសសុទ្ធ ចេញអំពីក្រុងសាវត្ថី ជាណុស្សោណិព្រាហ្មណ៍ទឹមសេះស មានគ្រឿងប្រដាប់ក៏ស រថក៏ស មានគ្រឿងបំពាក់ក៏ស ខ្សែក៏ស ដងជន្លួញក៏ស ឆត្រក៏ស ឈ្នួតក្បាលក៏ស សំពត់ក៏ស ស្បែកជើងក៏ស គេបក់ដោយផ្លិតកម សក៏សទៀត ។ ជនបានឃើញជាណុស្សោណិព្រាហ្មណ៍នោះហើយ ក៏ពោលយ៉ាងនេះថា អើហ្ន៎ យានប្រសើរពេកណាស់ អើហ្ន៎ យានមានសភាពដូចជាយានរបស់ព្រហ្ម ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ញត្តនូវព្រហ្មយាន ក្នុងធម្មវិន័យនេះបានដែរឬ ។

[១៤] សត្ថា អាចិក្ខតិ ភគវា អវោច ឥមស្សេវ ខោ ឯតំ អានន្ទ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ ព្រហ្មយានំ ឥតិបិ ធម្មយានំ ឥតិបិ អនុត្តរោ សង្គាមវិជយោ ឥតិបិ ។

[១៥] សម្មាទិដ្ឋិ អានន្ទ ភាវិតា ពហុលីកតា រាគវិនយបរិយោសានា ហោតិ ទោសវិនយបរិយោសានា ហោតិ មោហវិនយបរិយោសានា ហោតិ ។

[១៦] សម្មាសង្កប្បោ អានន្ទ ភាវិតោ ពហុលីកតោ រាគវិនយបរិយោសានោ ហោតិ ទោសវិនយបរិយោសានោ ហោតិ មោហវិនយបរិយោសានោ ហោតិ ។

[១៧] សម្មាវាចា អានន្ទ ភាវិតា ពហុលីកតា រាគវិនយបរិយោសានា ហោតិ ទោសវិនយបរិយោសានា ហោតិ មោហវិនយបរិយោសានា ហោតិ ។



[១៤] ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគត កេចនឹងបញ្ញត្តក្នុង ហើយក៏ត្រាស់ថា ម្នាលអានន្ទ ពាក្យថា ព្រហ្មយានក្តី ធម្មយានក្តី ជាអនុត្តរសង្គាមវិជ័យ (ការឈ្នះសង្គ្រាមដ៏ប្រសើរក្រៃលែង) ក្តី នេះជាឈ្មោះនៃមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ។

[១៥] ម្នាលអានន្ទ សម្មាទិដ្ឋិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

[១៦] ម្នាលអានន្ទ សម្មាសង្កប្បៈ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

[១៧] ម្នាលអានន្ទ សម្មាវាចា ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

(១៨) សម្មាកម្មន្តោ អានន្ទ ភាវិតោ ពហុលីកតោ រាគវិនយបរិយោសានោ ហោតិ ទោសវិនយបរិយោសានោ ហោតិ មោហវិនយបរិយោសានោ ហោតិ ។

(១៩) សម្មាអាជីវោ អានន្ទ ភាវិតោ ពហុលីកតោ រាគវិនយបរិយោសានោ ហោតិ ទោសវិនយបរិយោសានោ ហោតិ មោហវិនយបរិយោសានោ ហោតិ ។

(២០) សម្មាវាយាមោ អានន្ទ ភាវិតោ ពហុលីកតោ រាគវិនយបរិយោសានោ ហោតិ ទោសវិនយបរិយោសានោ ហោតិ មោហវិនយបរិយោសានោ ហោតិ ។

(២១) សម្មាសតិ អានន្ទ ភាវិតា ពហុលីកតា រាគវិនយបរិយោសានា ហោតិ ទោសវិនយបរិយោសានា ហោតិ មោហវិនយបរិយោសានា ហោតិ ។

(២២) សម្មាសមាធិ អានន្ទ ភាវិតោ ពហុលីកតោ រាគវិនយបរិយោសានោ ហោតិ ទោសវិនយបរិយោសានោ ហោតិ មោហវិនយបរិយោសានោ ហោតិ ។





(១៨) ម្នាលអានន្ទ សម្មាកម្មន្តៈ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

(១៩) ម្នាលអានន្ទ សម្មាអាជីវៈ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

(២០) ម្នាលអានន្ទ សម្មាវាយាមៈ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

(២១) ម្នាលអានន្ទ សម្មាសតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

(២២) ម្នាលអានន្ទ សម្មាសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។

[២៣] ឥមិនា ខោ ឯតំ អានន្ទ បរិយាយេន វេទិតព្វំ យថា ឥមស្សេវេតំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ ព្រហ្មយានំ ឥតិបិ ធម្មយានំ ឥតិបិ អនុត្តរោ សង្គាមវិជយោ ឥតិបីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[២៤] យស្ស សទ្ធា ច បញ្ញា ច
ធម្មា យុត្តា សទា ធុរំ
ហិរី ឦសា មនោ យោត្តំ
សតិ អារក្ខសារថិ ។
រថោ សីលបរិក្ខារោ
ឈានក្ខោ ចក្កវីរិយោ
ឧបេក្ខា ធុរសមាធិ
អនិច្ឆា បរិវារណំ ។
អព្យាបាទោ អវិហិំសា
វិវេកោ យស្ស អាវុធំ



[២៣] ម្នាលអានន្ទ អ្នកគប្បីដឹងនូវសេចក្តីនុ៎ះដោយបរិយាយនេះចុះថា ពាក្យថា ព្រហ្មយានផ្លូវប្រសើរក្តី ធម្មយានផ្លូវប្រសើរក្តី ជាអនុត្តរសង្គាមវិជ័យផ្លូវប្រសើរក្តី នេះជាឈ្មោះនៃមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះហើយ លុះព្រះសុគតជាសាស្តាទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះរួចហើយ ក៏ទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះតទៅទៀតថា

[២៤] ធម៌ទាំងឡាយជាគូគ្នា គឺសទ្ធានឹងបញ្ញារបស់ផ្លូវ គឺអរិយមគ្គឯណា ឯសទ្ធាទុកជាធ្នឹម ហិរិជាចន្ទោល មនោជាខ្សែរ សតិជាសារថីអ្នកថែរក្សា ។ ផ្លូវគឺអរិយមគ្គ (នោះ) មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយៈជាកង់ មានឧបេក្ខាជាកំណល់ធ្នឹម មានអនិច្ឆា (សេចក្តីមិនលោភ) ជាគ្រឿងបាំង ។ សេចក្តីមិនព្យាបាទ សេចក្តីមិនបៀតបៀន នឹងសេចក្តីស្ងប់ស្ងាត់ ទុកជាអាវុធរបស់កុលបុត្ត (អ្នកស្ថិតនៅក្នុងផ្លូវគឺអរិយមគ្គ) ឯណា (កុលបុត្តនោះ)

តិតិក្ខា ចម្មសន្នាហោ(១)

យោគក្ខេមាយ វត្តតិ ។

ឯតទត្តនិ សម្ភូតំ

ព្រហ្មយានំ អនុត្តរំ

និយ្យន្តិ ធីរា លោកម្ហា

អញ្ញទត្ថុ ជយំ ជយន្តិ ។

[២៥] សាវត្ថីនិទានំ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ នោ ភន្តេ អញ្ញ-តិត្ថិយា បរិព្វាជកា អម្ហេ ឯវំ បុច្ឆន្តិ កិមត្ថិយំ អាវុ-សោ សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ។ ឯវំ បុដ្ឋា មយំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ

១ អដ្ឋកថាយំ ចម្មសន្នាហោតិ ទិស្សតិ ។



មានធម៌គឺអធិវាសនខន្តីជាគ្រឿងក្រោះ ប្រព្រឹត្តទៅដើម្បីព្រះ និព្វានជាទីក្សេមចាកយោគៈ ។ ព្រហ្មយាននេះ កើតក្នុង- ជាគ្រឿងទៅក្រៃលែងជាទីបាន កើតព្រមក្នុងខ្លួន អ្នកប្រាជ្ញ ទាំងឡាយ កាលមានជ័យជំនះ (ឈ្នះកាមកិលេស) រមែង ចេញចាកលោកបានដោយពិត ។

(២៥) សាវត្ថីនិទាន ។ គ្រានោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុង ទីនេះណា ពួកអន្យតិរ្ថិយបរិព្វាជកសួរខ្ញុំព្រះអង្គទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកលោកនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំ-ណាក់ព្រះសមណគោតមដើម្បីប្រយោជន៍អ្វី ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គទាំងឡាយ

ឯវំ ព្យាករោម ទុក្ខស្ស ខោ អាវុសោ បរិញ្ញត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ កច្ចិ មយំ ភន្តេ ឯវំ បុដ្ឋា ឯវំ ព្យាករមានា វុត្តវាទិនោ ចេវ ភគវតោ ហោម ន ច ភគវន្តំ អភូតេន អព្ភាចិក្ខាម ធម្មស្ស ចានុធម្មំ ព្យាករោម ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។

(៦៦) តគ្ឃ តុម្ហេ ភិក្ខវេ ឯវំ បុដ្ឋា ឯវំ ព្យាករមានា វុត្តវាទិនោ ចេវ មេ ហោថ ន ច មំ អភូតេន អព្ភាចិក្ខថ ធម្មស្ស ចានុធម្មំ ព្យាករោថ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ ទុក្ខស្ស ហិ បរិញ្ញត្ថំ មយិ ព្រហ្មចរិយំ វុស្សតិ ។



ក៏ដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ កាលបើគេសួរយ៉ាងនេះហើយ ដោះស្រាយយ៉ាងនេះ ឈ្មោះថាពោលតាមពាក្យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយផង មិនពោលបង្កាច់ព្រះដ៏មានព្រះភាគដោយពាក្យមិនពិតផង ដោះស្រាយនូវធម៌តាមសមគួរដល់ធម៌ផង ទាំងពាក្យពោលចំកួចនីមួយដែលប្រកបដោយធម៌ ក៏មិនដល់នូវហេតុដែលបណ្ឌិតគប្បីតិះដៀលផងដែរឬ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ អើ កាលបើគេសួរយ៉ាងនេះហើយ អ្នកទាំងឡាយដោះស្រាយយ៉ាងនេះ ឈ្មោះថាពោលតាមពាក្យដែលតថាគតពោលហើយផង មិនឈ្មោះថាពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ដោះស្រាយនូវធម៌តាមសមគួរដល់ធម៌ផង ទាំងពាក្យពោលចំកួចនីមួយដែលប្រកបដោយធម៌ ក៏មិនដល់នូវហេតុដែលបណ្ឌិតគប្បីតិះដៀលផងដែរ ព្រោះអ្នកទាំងឡាយនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ដើម្បីកំណត់ដឹងនូវទុក្ខពិត ។

[៦៧] សចេ ភោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ អត្ថិ ខោ អាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។

[៦៨] កតមោ ច ភិក្ខវេ មគ្គោ កតមា បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ អយំ ភិក្ខវេ មគ្គោ អយំ បដិបទា ឯតស្ស ទុក្ខស្ស បរិញ្ញាយាតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។



[៦៧] ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយបរិព្វាជកសួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចុះមគ្គនឹងបដិបទា ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនុះមានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះ អ្នកទាំងឡាយគប្បីដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ មគ្គនឹងបដិបទាប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនុះ មានដែរ ។

[៦៨] ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនុះ ។ គឺមគ្គដ៏ប្រសើរប្រកបដោយអង្គ៨ហ្នឹងឯង ។ មគ្គទាំង៨តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះជាមគ្គ នេះជាបដិបទា ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនុះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះហើយ អ្នកទាំងឡាយគប្បីដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ យ៉ាងនេះចុះ ។

(២៩) សាវត្ថីនិទានំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ព្រហ្មចរិយំ ព្រហ្មចរិយន្តិ ភន្តេ វុច្ចតិ ។ កតមំ នុ ខោ ភន្តេ ព្រហ្មចរិយំ កតមំ ព្រហ្មចរិយបរិយោសានន្តិ ។

(៣០) អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ យោ ខោ ភិក្ខុ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ ព្រហ្មចរិយបរិយោសានន្តិ ។



(២៩) សាវត្ថីនិទាន ។ គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា ព្រហ្មចរិយៈ ព្រហ្មចរិយៈ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រហ្មចរិយៈតើដូចម្តេច ទីបំផុតរបស់ព្រហ្មចរិយៈតើដូចម្តេច ។

(៣០) ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថាព្រហ្មចរិយៈ ។ មគ្គទាំង ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថាទីបំផុតនៃព្រហ្មចរិយៈ ។

(៣១) សាវត្ថិនិទានំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច រាគវិនយោ ទោសវិនយោ មោហវិនយោតិ ភន្តេ វុច្ចតិ ។ កតមស្ស នុ ខោ ឯតំ ភន្តេ អធិវចនំ រាគវិនយោ ទោសវិនយោ មោហវិនយោតិ ។ និព្វានធាតុយា ខោ ឯតំ ភិក្ខុ អធិវចនំ រាគវិនយោ ទោសវិនយោ មោហវិនយោតិ ។ អាសវានំ ខយោ តេន វុច្ចតីតិ ។





(៣១) សាវត្ថីនិទាន ។ គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា ការកំចាត់បង់នូវលោភៈ ការកំចាត់បង់នូវទោសៈ ការកំចាត់បង់នូវមោហៈ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះពាក្យថា ការកំចាត់បង់នូវលោភៈ ការកំចាត់បង់នូវទោសៈ ការកំចាត់បង់នូវមោហៈនុ៎ះ ជាឈ្មោះនៃអ្វីហ្ន៎ ។ ម្នាលភិក្ខុ ពាក្យថា ការកំចាត់បង់នូវលោភៈ ការកំចាត់បង់នូវទោសៈ និងការកំចាត់បង់នូវមោហៈនុ៎ះ ជាឈ្មោះនៃនិព្វានធាតុ ។ ព្រោះហេតុនោះទើបហៅថា ការអស់ទៅនៃអាសវៈទាំងឡាយ ។

(៣២) ឯវំ វុត្តេ សោ ភិក្ខុ ភគវន្តំ ឯតទវោច អមតំ អមតន្តិ ភន្តេ វុច្ចតិ ។ កតមំ នុ ខោ ភន្តេ អមតំ កតមោ អមតគាមិមគ្គោតិ ។ យោ ខោ ភិក្ខុ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ វុច្ចតិ អមតំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អមតគា-មិមគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មា-សមាធីតិ ។

(៣៣) សាវត្ថីនិទានំ ។ អរិយំ វោ ភិក្ខវេ អដ្ឋង្គិកំ មគ្គំ ទេសេស្សាមិ វិភជិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។



(៣២) កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុនោះក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា អមតៈ អមតៈ (មិនស្លាប់ មិនស្លាប់) ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន អមតៈតើដូចម្តេច ផ្លូវជាដំណើរទៅកាន់អមតៈតើដូចម្តេច ។ ម្នាលភិក្ខុ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថាអមតៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាផ្លូវដំណើរទៅកាន់អមតៈ ។ មគ្គមានអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។

(៣៣) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង នឹងចែកនូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវមគ្គនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ មគ្គមានអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។

[៣៤] កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ។ យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាទិដ្ឋិ ។

[៣៥] កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ។ យោ ខោ ភិក្ខវេ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ ។

[៣៦] កតមា ច ភិក្ខវេ សម្មាវាចា ។ យា ខោ ភិក្ខវេ មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា ។

[៣៧] កតមោ ច ភិក្ខវេ សម្មាកម្មន្តោ ។ យា ខោ ភិក្ខវេ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី អព្រហ្មចរិយា វេរមណី ។ អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ ។



[៣៤] ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីដឹងក្នុងទុក្ខ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃទុក្ខ សេចក្តីដឹងក្នុងការរលត់នៃទុក្ខ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃទុក្ខឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាទិដ្ឋិ ។

(៣៥) ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះក្នុងការចេញចាកកាម សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀនឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាសង្កប្បៈ ។

[៣៦] ម្នាលភិក្ខុទាំងឡាយ សម្មាវាចាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចេតនាវៀរចាកការនិយាយកុហក ចេតនាវៀរចាកការនិយាយញុះញង់ ចេតនាវៀរចាកការនិយាយទ្រគោះ ចេតនាវៀរចាកការនិយាយរោយរាយឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាវាចា ។

(៣៧) ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចេតនាវៀរចាកការសម្លាប់សត្វ ចេតនាវៀរចាកការលួចទ្រព្យគេ ចេតនាវៀរចាកការប្រព្រឹត្តធម៌មិនប្រសើរឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាកម្មន្តៈ ។

(៣៨) កតមោ ច ភិក្ខវេ សម្មាអាជីវោ ។ ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិកំ កប្បេតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ ។

(៣៩) កតមោ ច ភិក្ខវេ សម្មាវាយាមោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ ។



(៣៨) ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស សម្រេចការចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាអាជីវៈ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ សម្មាវាយាមៈតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យតាំងនៅមិនឲ្យភ្លេចភាំងទៅវិញ ឲ្យចំរើនទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាវាយាមៈ ។

បាលីភាគ

(៦០) កតមា ច ភិក្ខវេ សម្មាសតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ។



អត្ថប្រែ

(៦០) ម្នាលភិក្ខុទាំងឡាយ សម្មាសតិតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាសតិ ។

[៤១] កតមោ ច ភិក្ខវេ សម្មាសមាធិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធីតិ ។



(៤១) ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានតែបីតិនិងសុខកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅ បានដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាធាតុខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិគឺបឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ហើយសម្រេចសម្រាន្តនៅ ភិក្ខុមានចិត្តនឿយណាយចាកបីតិ ប្រកបដោយឧបេក្ខា មានស្មារតីដឹងខ្លួន សោយនូវសុខដោយនាមកាយ ព្រោះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលដែលបាននូវតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅ ភិក្ខុលះបង់នូវសុខផង លះបង់នូវទុក្ខផង ហាមសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈានដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធដែលកើតអំពីឧបេក្ខា ហើយសម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសម្មាសមាធិ ។

សូកវគ្គោ

(៤២) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ សាលិសូកំ វា យវសូកំ វា មិច្ឆាបណិហិតំ ហត្ថេន វា បាទេន វា អក្កន្តំ ហត្ថំ វា បាទំ វា ភិន្ទិស្សតិ លោហិតំ វា ឧប្បាទេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ មិច្ឆាបណិហិតត្តា ភិក្ខវេ សូកស្ស ។ ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ មិច្ឆាបណិហិតាយ ទិដ្ឋិយា មិច្ឆាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្វានំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ មិច្ឆាបណិហិតត្តា ភិក្ខវេ ទិដ្ឋិយា ។

(៤៣) សេយ្យថាបិ ភិក្ខវេ សាលិសូកំ វា យវសូកំ វា សម្មាបណិហិតំ ហត្ថេន វា បាទេន វា អក្កន្តំ ហត្ថំ វា បាទំ វា ភិន្ទិស្សតិ លោហិតំ វា ឧប្បាទេស្សតីតិ ឋានមេតំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។



សូកវគ្គ

(៤២) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ដូចចុងស្រូវខ្សាយ ឬចុងស្រូវដំណើប ដែលគេដាក់លំទុកខុស នឹងមុតដៃឬជើង ឬនឹងញ៉ាំងឈាមឲ្យកើតឡើងបាន ដល់បុគ្គលដែលជាន់ដោយដៃឬជាន់ដោយជើង ហេតុនេះរមែងមិនមានឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចុងនៃស្រូវគេដាក់លំទុកខុស យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះនឹងអាចទំលាយនូវអវិជ្ជា នឹងញ៉ាំងវិជ្ជាឲ្យកើតឡើង នឹងបានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយទិដ្ឋិដែលខ្លួនដាក់លំខុស ដោយមគ្គភាវនាដែលខ្លួនដាក់លំខុស ហេតុនេះរមែងមិនមានឡើយ ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាទិដ្ឋិដែលភិក្ខុនោះដាក់លំខុស ក៏យ៉ាងនោះដែរ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ ដូចចុងស្រូវខ្សាយ ឬចុងស្រូវដំណើប ដែលបុគ្គលដាក់លំទុកត្រូវ នឹងអាចមុតដៃឬជើង ឬនឹងញ៉ាំងឈាមឲ្យកើតឡើងបាន ដល់បុគ្គលដែលជាន់ដោយដៃឬជាន់ដោយជើង ហេតុនេះរមែងមានជាប្រាកដ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

សម្មាបណិហិតត្តា ភិក្ខវេ សូកស្ស ។ ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្ពានំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ សម្មាបណិហិតត្តា ភិក្ខវេ ទិដ្ឋិយា ។

(៦៦) កថញ្ច ភិក្ខវេ ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្ពានំ សច្ឆិករិស្សតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ សម្មាសមាធិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្ពានំ សច្ឆិករិស្សតីតិ ។



ម្នាលភិក្ខុទាំងឡាយ ព្រោះជាចុងនៃស្រូវដែលគេតំកល់ទុកត្រូវ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះនឹងទំលាយនូវអវិជ្ជា នឹងញុំាងវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន ដោយទិដ្ឋិដែលខ្លួនតំកល់ត្រូវ ដោយមគ្គភាវនាដែលខ្លួនតំកល់ត្រូវ ហេតុនេះរមែងមានជាប្រាកដ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះជាទិដ្ឋិដែលភិក្ខុនោះតំកល់ត្រូវ ក៏យ៉ាងនោះដែរ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុនឹងទំលាយនូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង នឹងបានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយទិដ្ឋិដែលខ្លួនតំកល់ត្រូវ ដោយមគ្គភាវនាដែលខ្លួនតំកល់ត្រូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនឹងទំលាយនូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយទិដ្ឋិដែលខ្លួនតំកល់ត្រូវ ដោយមគ្គភាវនាដែលខ្លួនតំកល់ត្រូវ យ៉ាងនេះឯង ។

(២៨) សាវត្ថីនិទានំ ។ អថខោ ឆន្នោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឆន្នោ បរិព្វាជកោ ភគវន្តំ ឯតទវោច កតិ នុ ខោ ភោ គោតម ធម្មា ភាវិតា ពហុលីកតា និព្វានគមា ហោន្តិ និព្វានបរាយនា និព្វានបរិយោសានាតិ ។ អដ្ឋិមេ ខោ ឆន្ន ធម្មា ភាវិតា ពហុលីកតា និព្វានគមា ហោន្តិ និព្វានបរាយនា និព្វានបរិយោសានា ។ កតមេ អដ្ឋ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥមេ ខោ ឆន្ន អដ្ឋ ធម្មា ភាវិតា ពហុលីកតា និព្វានគមា ហោន្តិ និព្វានបរាយនា និព្វានបរិយោសានាតិ ។





(២៨) សាវត្ថីនិទាន ។ គ្រានោះ ឆន្នបរិព្វាជកចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយទៅរកព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះឆន្នបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌មានដំណើរទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅក្នុងខាងមុខ មានព្រះនិព្វានជាទីបំផុត មានប៉ុន្មានហ្ន៎ ។ ម្នាលឆន្នៈ ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌មានដំណើរទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត នេះមាន ៨ យ៉ាង ។ ធម៌ទាំង ៨ យ៉ាងតើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលឆន្នៈ ធម៌ទាំង ៨ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌មានដំណើរទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ។

(៤៦) ឯវំ វុត្តេ ឧជ្ជយោ ព្រាហ្មណោ ភគវន្តំ ឯត-ទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ ប-ដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធ-ការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវ ភោតា គោតមេន អនេកបរិយា-យេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

វគ្គោ បឋមោ ។



(៤៦) កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ឧជ្ជយ-ព្រាហ្មណ៍ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ដូចបុគ្គលផ្ងាររបស់ដែលគេផ្កាប់ ឬបើករបស់ដែលបិទបាំង ពុំនោះសោត ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលប្រទីបប្រេងបំភ្លឺក្នុងទីងងឹតដោយគិតថាបុរសអ្នកមានភ្នែកនឹងបានឃើញរូបទាំងឡាយ យ៉ាងណាមិញ ។ ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់សំដែងហើយដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចំរើន ទាំងព្រះធម៌ទាំងព្រះភិក្ខុសង្ឃថាជាទីពឹងទីរឭក សូមព្រះគោតមដ៏ចំរើនចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវព្រះត្រៃរ័ត្នជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

ចប់ វគ្គទី ១ ។

## តស្សុទ្ទានំ

អវិជ្ជញ្ច ឧបឌ្ឍញ្ច
សារីបុត្តោ ច ព្រាហ្មណោ
កិមត្ថិយំ[១] ច ទ្វេ ភិក្ខូ
វិភង្គោ សូកនន្ទិយាតិ ។

---

១ ម. កិមត្ថិយោ ។





## ឧទ្ទាននៃអវិជ្ជាវគ្គនោះគឺ

និយាយអំពីអវិជ្ជា ១ អំពីពាក់កណ្តាលនៃព្រហ្មចរិយៈ ១ អំពីព្រះសារីបុត្ត ១ អំពីជាណុស្សោណិព្រាហ្មណ៍ ១ អំពីការប្រព្រឹត្តព្រហ្មចរិយៈដើម្បីប្រយោជន៍អ្វី ១ អំពីភិក្ខុមួយរូបចូលទៅក្រាបទូលព្រះដ៏មានព្រះភាគមាន២លើក អំពីព្រះដ៏មានព្រះភាគសំដែងវិភង្គអដ្ឋង្គិកមគ្គ ១ អំពីសេចក្តីប្រៀបដូចចុងនៃស្រូវ ១ អំពីនន្ទិយបរិព្វាជក ១ ។

# វិហារវគ្គោ

(៦៧) សាវត្ថិនិទានំ ។ ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លីយិតុំ នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា ។ នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន ។

(៦៨) អថខោ ភគវា តស្ស អឌ្ឍមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ យេន ស្វាហំ ភិក្ខវេ វិហារេន បឋមាភិសម្ពុទ្ធោ វិហរាមិ តស្ស បទេសេន វិហាសឹ សោ ឯវំ បជានាមិ មិច្ឆាទិដ្ឋិបច្ចយាបិ វេទយិតំ សម្មាទិដ្ឋិបច្ចយាបិ វេទយិតំ ។បេ។ មិច្ឆាសមាធិបច្ចយាបិ វេទយិតំ

# វិហារវគ្គ

(៦៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីសម្ងំនៅក្នុងទីស្ងាត់អស់កន្លះខែ អ្នកណាកុំគប្បីចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបអ្នកនាំនូវចង្ហាន់បិណ្ឌបាតទៅ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ អ្នកណាមួយក៏មិនហ៊ានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងទីនោះឡើយ វៀរលែងតែភិក្ខុមួយរូបអ្នកនាំនូវចង្ហាន់បិណ្ឌបាតទៅ ។

(៦៨) គ្រានោះ ព្រះដ៏មានព្រះភាគ លុះកន្លងកាលកន្លះខែនោះហើយ ក៏ទ្រង់ចេញចាកទីស្ងាត់ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងជាដំបូង ដោយធម៌ជាគ្រឿងនៅឯណា តថាគតក៏បានសម្រេចសម្រាន្តនៅដោយចំណែកនៃធម៌ជាគ្រឿងនៅនោះ តថាគតដឹងច្បាស់យ៉ាងនេះថា ការសោយអារម្មណ៍ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះសម្មាទិដ្ឋិជាបច្ច័យក៏មាន ។បេ។ ការសោយអារម្មណ៍ព្រោះមិច្ឆាសមាធិជាបច្ច័យក៏មាន

សម្មាសមាធិប្បច្ចយាបិ វេទយិតំ ឆន្ទប្បច្ចយាបិ វេទយិតំ វិតក្កប្បច្ចយាបិ វេទយិតំ សញ្ញាបច្ចយាបិ វេទយិតំ ឆន្ទោ ច អវូបសន្តោ ហោតិ វិតក្កោ ច អវូបសន្តោ ហោតិ សញ្ញា ច អវូបសន្តា ហោតិ តប្បច្ចយាបិ វេទយិតំ ឆន្ទោ ច វូបសន្តោ ហោតិ វិតក្កោ ច វូបសន្តោ ហោតិ សញ្ញា ច វូបសន្តា ហោតិ តប្បច្ចយាបិ វេទយិតំ អប្បត្តស្ស បត្តិយា អត្ថិ អាយាមំ តស្មឹបិ ឋានេ អនុប្បត្តេ តប្បច្ចយាបិ វេទយិតន្តិ ។

(៤៩) សាវត្ថីនិទានំ ។ ឥច្ឆាមហំ ភិក្ខវេ ឆមាសំ បដិសល្លីយិតុំ នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា ។ នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន ។



ការសោយអារម្មណ៍ព្រោះសម្មាសមាធិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះឆន្ទៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះវិតក្កៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះសញ្ញាជាបច្ច័យក៏មាន ឆន្ទៈមិនស្ងប់ក៏មាន វិតក្កៈមិនស្ងប់ក៏មាន សញ្ញាមិនស្ងប់ក៏មាន ការសោយអារម្មណ៍ព្រោះមិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ក៏មាន វិតក្កៈស្ងប់ក៏មាន សញ្ញាស្ងប់ក៏មាន ការសោយអារម្មណ៍ព្រោះស្ងប់នោះជាបច្ច័យក៏មាន សេចក្ដីព្យាយាមប្រព្រឹត្តទៅដើម្បីដល់នូវគុណវិសេសដែលមិនទាន់បានដល់ក៏មាន កាលបើហេតុនោះមិនទាន់សម្រេចហើយ ការសោយអារម្មណ៍ព្រោះមិនសម្រេចនោះជាបច្ច័យក៏មាន ។

(៤៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីសម្ងំនៅក្នុងទីស្ងាត់អស់ ៦ ខែ អ្នកណាមួយកុំគប្បីចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបអ្នកនាំនូវបង្ហាន់បិណ្ឌបាតទៅ ។ ភិក្ខុទាំងនោះទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ អ្នកណាមួយក៏មិនហ៊ានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងទីនោះឡើយ វៀរលែងតែភិក្ខុមួយរូបអ្នកនាំនូវបង្ហាន់បិណ្ឌបាតទៅ ។

(៥៨) អថខោ ភគវា តស្ស តេមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ យេន ស្វាហំ ភិក្ខវេ វិហារេន បឋមាភិសម្ពុទ្ធោ វិហរាមិ តស្ស បទេសេន វិហាសឹ សោ ឯវំ បជានាមិ មិច្ឆាទិដ្ឋិបច្ចយាបិ វេទយិតំ មិច្ឆាទិដ្ឋិវូបសមបច្ចយាបិ វេទយិតំ សម្មាទិដ្ឋិបច្ចយាបិ វេទយិតំ សម្មាទិដ្ឋិវូបសមបច្ចយាបិ វេទយិតំ ។ បេ ។ មិច្ឆាសមាធិបច្ចយាបិ វេទយិតំ មិច្ឆាសមាធិវូបសមបច្ចយាបិ វេទយិតំ សម្មាសមាធិបច្ចយាបិ វេទយិតំ សម្មាសមាធិវូបសមបច្ចយាបិ វេទយិតំ ឆន្ទបច្ចយាបិ វេទយិតំ ឆន្ទវូបសមបច្ចយាបិ វេទយិតំ វិតក្កបច្ចយាបិ វេទយិតំ វិតក្កវូបសមបច្ចយាបិ វេទយិតំ សញ្ញាបច្ចយាបិ វេទយិតំ សញ្ញាវូបសមបច្ចយាបិ វេទយិតំ ឆន្ទោ ច អវូបសន្តោ ហោតិ វិតក្កោ ច អវូបសន្តោ ហោតិ សញ្ញា ច



(៥០) គ្រានោះ ព្រះដ៏មានព្រះភាគលុះកន្លង ៣ ខែនោះហើយ ក៏ចេញចាកទីស្ងាត់ ហើយត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងជាដំបូងដោយធម៌ជាគ្រឿងនៅឯណា តថាគតក៏បានសម្រេចសម្រាន្តនៅដោយចំណែកនៃធម៌ជាគ្រឿងនៅនោះ តថាគតដឹងច្បាស់យ៉ាងនេះថា ការសោយអារម្មណ៍ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់មិច្ឆាទិដ្ឋិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះសម្មាទិដ្ឋិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់សម្មាទិដ្ឋិជាបច្ច័យក៏មាន ។ បេ ។ ការសោយអារម្មណ៍ព្រោះមិច្ឆាសមាធិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់មិច្ឆាសមាធិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះសម្មាសមាធិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់សម្មាសមាធិជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះឆន្ទៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់ឆន្ទៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះវិតក្កៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់វិតក្កៈជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះសញ្ញាជាបច្ច័យក៏មាន ការសោយអារម្មណ៍ព្រោះរម្ងាប់សញ្ញាជាបច្ច័យក៏មាន ឆន្ទៈមិនរម្ងាប់ក៏មាន វិតក្កៈមិនរម្ងាប់ក៏មាន សញ្ញា

អវូបសន្តា ហោតិ តប្បច្ចយាបិ វេទយិតំ ឆន្ទោ ច វូប-
សន្តោ ហោតិ វិតក្កោ ច វូបសន្តោ ហោតិ សញ្ញា ច វូប-
សន្តា ហោតិ តប្បច្ចយាបិ វេទយិតំ អប្បត្តស្ស បត្តិយា
អត្ថិ អាយាមំ តស្មឹបិ ឋានេ អនុប្បត្តេ តប្បច្ចយាបិ
វេទយិតន្តិ ។

(៥៣) សាវត្ថីនិទានំ ។ អថខោ អញ្ញតរោ ភិក្ខុ
យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ
ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សេក្ខោ សេក្ខោតិ
ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សេក្ខោ ហោតីតិ ។
ឥធ ភិក្ខុ សេក្ខាយ សម្មាទិដ្ឋិយា សមន្នាគតោ
ហោតិ ។ បេ ។ សេក្ខេន សម្មាសមាធិនា សមន្នាគតោ
ហោតិ ។ ឯត្តាវតា ខោ ភិក្ខុ សេក្ខោ ហោតីតិ ។



មិនរម្ងាប់ក៏មាន ការសោយអារម្មណ៍ព្រោះមិនរម្ងាប់នោះជាបច្ច័យក៏មាន
ឆន្ទៈរម្ងាប់ក៏មាន វិតក្កៈរម្ងាប់ក៏មាន សញ្ញារម្ងាប់ក៏មាន ការសោយ
អារម្មណ៍ព្រោះរម្ងាប់នោះជាបច្ច័យក៏មាន សេចក្តីព្យាយាមប្រព្រឹត្តទៅ
ដើម្បីដល់នូវគុណវិសេសដែលមិនទាន់បានដល់ក៏មាន កាលបើហេតុ
នោះមិនទាន់សម្រេចហើយ ការសោយអារម្មណ៍ព្រោះហេតុមិនសម្រេច
នោះជាបច្ច័យក៏មាន ។

[៥៣] សាវត្ថីនិទាន ។ គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះ
ដ៏មានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាប
បង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យគេ
តែងនិយាយថា សេក្ខៈ សេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ដែល
ឈ្មោះថាសេក្ខៈនោះដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាស-
នានេះ ប្រកបដោយសេក្ខសម្មាទិដ្ឋិ ។ បេ ។ ប្រកបដោយសេក្ខសម្មា-
សមាធិ ។ ម្នាលភិក្ខុ ដែលឈ្មោះថាសេក្ខៈដោយហេតុប៉ុណ្ណេះឯង ។

(៨៦) សាវត្ថិនិទានំ ។ អដ្ឋិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្ស ។ កតមេ អដ្ឋ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

(៨៧) សាវត្ថិនិទានំ ។ អដ្ឋិមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយា ។ កតមេ អដ្ឋ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយាតិ ។



(៨៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាង នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។ ធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាង នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។

(៨៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាង នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីវិន័យព្រះសុគតទេ ។ ធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាង នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីវិន័យព្រះសុគតទេ ។

(៨៧) សាវត្ថីនិទានំ ។ អដ្ឋិមេ ភិក្ខវេ ធម្មា បរិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្កិលេសា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្ស ។ កតមេ អដ្ឋ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា បរិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្កិលេសា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

(៨៨) សាវត្ថីនិទានំ ។ អដ្ឋិមេ ភិក្ខវេ ធម្មា បរិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្កិលេសា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយា ។ កតមេ អដ្ឋ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា បរិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្កិលេសា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយាតិ ។



(៨៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះឯង ដែលបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេសហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។ ធម៌ទាំង ៨ យ៉ាងតើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះឯង ដែលបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេសហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។

(៨៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះឯង ដែលបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេសហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីវិន័យព្រះសុគតទេ ។ ធម៌ទាំង ៨ យ៉ាងតើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះឯង ដែលបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេសហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើង មិនមែនកើតឡើងក្រៅអំពីវិន័យព្រះសុគតទេ ។

(៥៦) សាវត្ថីនិទានំ ។ ឯកំ សមយំ អាយស្មា ច អានន្ទោ អាយស្មា ច ភទ្ទោ បាដលិបុត្តេ វិហរន្តិ កុក្កុដារាមេ ។ អថខោ អាយស្មា ភទ្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភទ្ទោ អាយស្មន្តំ អានន្ទំ ឯតទវោច អព្រហ្មចរិយំ អព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ អព្រហ្មចរិយន្តិ ។ សាធុ សាធុ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ ភទ្ទកំ បដិភានំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ អាវុសោ ភទ្ទ បុច្ឆសិ អព្រហ្មចរិយំ អព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ អព្រហ្មចរិយន្តិ ។ ឯវមាវុសោតិ ។ អយមេវ ខោ អាវុសោ អដ្ឋង្គិកោ មិច្ឆាមគ្គោ អព្រហ្មចរិយំ ។ សេយ្យថីទំ ។ មិច្ឆាទិដ្ឋិ ។បេ។ មិច្ឆាសមាធីតិ ។





(៥៦) សាវត្ថីនិទាន ។ ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះអានន្ទដ៏មានអាយុនឹងព្រះភទ្ទៈដ៏មានអាយុគង់នៅក្នុងកុក្កុដារាម ជិតក្រុងបាដលីបុត្ត ។ គ្រានោះ ព្រះភទ្ទៈដ៏មានអាយុចេញចាកទីពួនសម្ងំក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើនូវសេចក្តីរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអានន្ទ ពាក្យគេតែងនិយាយថា អព្រហ្មចរិយៈ អព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ អព្រហ្មចរិយៈតើដូចម្តេច ។ ម្នាលអាវុសោភទ្ទៈ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលអាវុសោភទ្ទៈ ការស្ទង់រកប្រាជ្ញារបស់អ្នក ល្អពេកណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏មានខ្លឹមល្អ ម្នាលអាវុសោភទ្ទៈ ព្រោះថាអ្នកសួរយ៉ាងនេះថា ម្នាលអាវុសោអានន្ទ ពាក្យគេតែងនិយាយថា អព្រហ្មចរិយៈ អព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ អព្រហ្មចរិយៈតើដូចម្តេច ។ យ៉ាងនេះហើយ អាវុសោ ។ ម្នាលអាវុសោ មិច្ឆាមគ្គប្រកបដោយអង្គ ៨ នេះឯង ហៅថាអព្រហ្មចរិយៈ ។ មិច្ឆាមគ្គមានអង្គ ៨ តើដូចម្តេច ។ គឺមិច្ឆាទិដ្ឋិ ១ ។បេ។ មិច្ឆាសមាធិ ១ ។

[៨៧] បាដលិបុត្តនិទានំ ។បេ។ ព្រហ្មចរិយំ ព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ ព្រហ្មចរិយំ កតមំ ព្រហ្មចរិយបរិយោសានន្តិ ។ សាធុ សាធុ ខោ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ អាវុសោ ភទ្ទ បុច្ឆសិ ព្រហ្មចរិយំ ព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ ព្រហ្មចរិយំ កតមំ ព្រហ្មចរិយបរិយោសានន្តិ ។ ឯវមាវុសោតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ ព្រហ្មចរិយបរិយោសានន្តិ ។



(៨៧) បាដលីបុត្តនិទាន ។បេ។ ម្នាលអាវុសោអានន្ទ ពាក្យនៅតែនិយាយថា ព្រហ្មចរិយៈ ព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ ព្រហ្មចរិយៈ តើដូចម្ដេច ទីបំផុតរបស់ព្រហ្មចរិយៈ តើដូចម្ដេច ។ ម្នាលអាវុសោភទ្ទៈ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលអាវុសោភទ្ទៈ ការស្ទង់រកប្រាជ្ញារបស់អ្នក ល្អពេកណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏មានចំនួនល្អ ម្នាលអាវុសោភទ្ទៈ ព្រោះថាអ្នកសួរយ៉ាងនេះថា ម្នាលអាវុសោអានន្ទ ពាក្យនៅតែនិយាយថា ព្រហ្មចរិយៈ ព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ ព្រហ្មចរិយៈ តើដូចម្ដេច ទីបំផុតរបស់ព្រហ្មចរិយៈ តើដូចម្ដេច ។ យ៉ាងនេះហើយ អាវុសោ ។ ម្នាលអាវុសោ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថាព្រហ្មចរិយៈ ។ មគ្គមានអង្គ ៨ តើដូចម្ដេច ។ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថាទីបំផុតរបស់ព្រហ្មចរិយៈ ។

(៩៨) បាដលិបុត្តនិទានំ ។ ព្រហ្មចរិយំ ព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ ព្រហ្មចរិយំ កតមោ ព្រហ្មចារី កតមំ ព្រហ្មចរិយបរិយោសានន្តិ ។ សាធុ សាធុ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ ភទ្ទកំ បដិភានំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ អាវុសោ ភទ្ទ បុច្ឆសិ ព្រហ្មចរិយំ ព្រហ្មចរិយន្តិ អាវុសោ អានន្ទ វុច្ចតិ កតមំ នុ ខោ អាវុសោ ព្រហ្មចរិយំ កតមោ ព្រហ្មចារី កតមំ ព្រហ្មចរិយបរិយោសានន្តិ ។ ឯវមាវុសោតិ ។ អយមេវ ខោ អាវុសោ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យោ ខោ អាវុសោ ឥមិនា អរិយេន អដ្ឋង្គិកេន មគ្គេន សមន្នាគតោ អយំ វុច្ចតិ ព្រហ្មចារី ។ យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ឥទំ ព្រហ្មចរិយបរិយោសានន្តិ ។ សុត្តន្តយំ ឯកនិទានំ[1] ។

វិហារវគ្គោ ទុតិយោ ។

---

១ ម. តីណិ សុត្តានិ ឯកនិទានានិ ។



(៩៨) បាដលិបុត្តនិទាន ។ ម្នាលអាវុសោអានន្ទ ពាក្យគេតែងនិយាយថា ព្រហ្មចរិយៈ ព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ ព្រហ្មចរិយៈ តើដូចម្តេច ព្រហ្មចារី (បុគ្គលអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ) តើដូចម្តេច ទីបំផុតរបស់ព្រហ្មចរិយៈ តើដូចម្តេច ។ ម្នាលអាវុសោភទ្ទៈ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលអាវុសោភទ្ទៈ ការស្ទង់គេប្រាជ្ញារបស់អ្នក ល្អពេកណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏មានទំនងល្អ ម្នាលអាវុសោភទ្ទៈ ព្រោះថាអ្នកសួរយ៉ាងនេះថា ម្នាលអាវុសោអានន្ទ ពាក្យគេតែងនិយាយថា ព្រហ្មចរិយៈ ព្រហ្មចរិយៈ ដូច្នេះ ម្នាលអាវុសោ ព្រហ្មចរិយៈ តើដូចម្តេច ព្រហ្មចារី តើដូចម្តេច ទីបំផុតរបស់ព្រហ្មចរិយៈ តើដូចម្តេច ។ យ៉ាងនេះហើយ អាវុសោ ។ ម្នាលអាវុសោ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថាព្រហ្មចរិយៈ ។ មគ្គមានអង្គ ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលអាវុសោ បុគ្គលឯណា ប្រកបដោយមគ្គដ៏ប្រសើរមានអង្គ ៨ នេះ បុគ្គលនេះហៅថាព្រហ្មចារី ។ ម្នាលអាវុសោ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថាទីបំផុតរបស់ព្រហ្មចរិយៈ ។ គឺសូត្រ ៣ នេះ មាននិទានតែមួយ ។

ចប់ វិហារវគ្គ ទី ២ ។

# តស្សុទ្ទានំ

ទ្វេ វិហារា ច សេក្ខា ច
ឧប្បាទេ(*) អបរេ ឆុបេ
បរិសុទ្ធេន ទ្វេ វុត្តា
ញត្តិជាកមេន តយោតិ ។

---

* ម. ឧប្បាទេ ។



# ឧទ្ទាននៃវិហារវគ្គនោះគឺ

និយាយអំពីវិហារធម៌របស់ព្រះដ៏មានព្រះភាគមាន ៦ លើក អំពីសេក្ខ ១ អំពីធម៌ ៨ យ៉ាងដែលបុគ្គលចំរើនឲ្យច្រើនហើយ ដែលមិនទាន់កើតឡើង កើតឡើង មាន ៦ លើក និយាយអំពីធម៌ ៨ យ៉ាងដែលបរិសុទ្ធមាន ៦ លើក អំពីធម៌ ដែលព្រះភទ្ទដ៏មានអាយុសួរព្រះភគវន្តក្នុងញត្តិកម្មមាន ៣ លើក ។

## មិច្ឆត្តវគ្គោ

(៥៩) សាវត្ថីនិទានំ ។ មិច្ឆត្តញ្ច ភិក្ខវេ ទេសេស្សាមិ សម្មត្តញ្ច តំ សុណាថ ។

(៦០) កតមញ្ច ភិក្ខវេ មិច្ឆត្តំ ។ សេយ្យថីទំ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ មិច្ឆត្តំ ។

(៦១) កតមញ្ច ភិក្ខវេ សម្មត្តំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ សម្មត្តំ ។

(៦២) សាវត្ថីនិទានំ ។ អកុសលេ ច ភិក្ខវេ ធម្មេ ទេសេស្សាមិ កុសលេ ច ធម្មេ តំ សុណាថ ។

(៦៣) កតមេ ច ភិក្ខវេ អកុសលា ធម្មា ។ សេយ្យថីទំ ។ មិច្ឆាទិដ្ឋិ ។ បេ ។ មិច្ឆាសមាធិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អកុសលា ធម្មា ។

## មិច្ឆត្តវគ្គ

(៥៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវភាពខុសផង នូវភាពត្រូវផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។

(៦០) ម្នាលភិក្ខុទាំងឡាយ ភាពខុស តើដូចម្តេច ។ អ្វីខ្លះ ។ គឺមិច្ឆាទិដ្ឋិ ១ ។ បេ ។ មិច្ឆាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភាពខុស ។

(៦១) ភាពត្រូវ តើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភាពត្រូវ ។

(៦២) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាអកុសលផង នូវធម៌ជាកុសលផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។

(៦៣) ម្នាលភិក្ខុទាំងឡាយ ធម៌ជាអកុសល តើដូចម្តេច ។ អ្វីខ្លះ ។ គឺមិច្ឆាទិដ្ឋិ ១ ។ បេ ។ មិច្ឆាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ជាអកុសល ។

(៦៤) កតមេ ច ភិក្ខវេ កុសលា ធម្មា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ កុសលា ធម្មាតិ ។

(៦៥) សាវត្ថីនិទានំ ។ មិច្ឆាបដិបទញ្ច វោ ភិក្ខវេ ទេសេស្សាមិ សម្មាបដិបទញ្ច តំ សុណាថ ។

[៦៦២] សារត្ថិចិតានំ ។ សេយ្យថាបិ ភិក្ខវេ យានិ កានិចិ តន្តាវុតានំ វត្ថានំ កាសិកវត្ថំ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ ។ អប្បមត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេស្សតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករិស្សតីតិ ។

[៦៦៣] កថញ្ច ភិក្ខវេ ភិក្ខុ អប្បមត្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គ-



[៦៦២] សារត្ថមិតាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសំពត់ដែលគេត្បាញ សំពត់ឯណានីមួយ សំពត់ក្នុងដែនកាសី រមែងប្រាកដជាប្រសើរជាងសំពត់ទាំងនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ មានអប្បមាទជាមូល មានអប្បមាទជាទីប្រជុំចុះ អប្បមាទធម៌រមែងប្រាកដជាប្រសើរជាងធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថាប្រសើរនុ៎ះ ជាទីសង្ឃឹមរបស់ភិក្ខុដែលមិនប្រមាទ ភិក្ខុអ្នកមិនប្រមាទ នឹងចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ។

[៦៦៣] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកមិនប្រមាទ រមែងចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោន

បរិហានាយ ។ បេ ។ សម្មាសមាធិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អប្បមត្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតីតិ ។

អប្បមាទវគ្គោ ទសមោ ។

## តស្សុទ្ទានំ

តថាគតំ បទំ កូដំ
មូលំ សារេន(១) វស្សិកំ
រាជា ចន្ទិមសុរិយា ច
វត្ថេន ទសមំ បទំ ។

(យថាបិ តថាគតំ តថាបិ វិត្ថារេតព្វំ) ។

---

១ ម. ច. សារេន ។



ទៅកាន់ការលះបង់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនប្រមាទ រមែងចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូចពោលមកហ្នឹងឯង ។

ចប់ អប្បមាទវគ្គទី ១០ ។

## ឧទ្ទាននៃអប្បមាទវគ្គនោះគឺ

និយាយអំពីព្រះតថាគតប្រសើរជាងសត្វ ១ អំពីស្នាមជើង (សត្វ) ១ អំពីបង្គង់ផ្ទះមានកំពូល ១ អំពីក្លិននៃឫស ១ អំពីក្លិននៃខ្លឹម ១ អំពីផ្កាម្លិះលា ១ អំពីស្តេច ១ អំពីព្រះចន្ទ ១ ព្រះអាទិត្យ ១ អំពីសំពត់ ១ ត្រូវជាបទទី ១០ ។

(បណ្ឌិតគប្បីធ្វើការសេចក្តីឲ្យពិស្តារត្រង់សេចក្តីដែលនិយាយអំពីព្រះតថាគតជាដើមចុះ) ។

## ពលករណីយវគ្គោ

(៦២៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

(៦២៧) កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ

## ពលករណីយវគ្គ

(៦២៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយឯណានីមួយ ដែលបុគ្គលត្រូវធ្វើដោយកំឡាំង ការងារទាំងអស់នោះ បុគ្គលត្រូវអាស្រ័យនូវផែនដី ឋិតនៅលើផែនដី ទើបធ្វើបាន ការងារទាំងនោះ ដែលបុគ្គលត្រូវធ្វើដោយកំឡាំង គឺរមែងធ្វើបានប្រាកដយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ក៏យ៉ាងនោះដែរ ។

៦២៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក

និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតីតិ ។

(បរតត្ថាបេយ្យាលំ វណ្ណិយតោ បរិបុណ្ណសុត្តន្តិ វិត្ថារេតព្វំ) ។

(៤៦៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករីយន្តិ សព្វេ តេ បថវឹ និស្សាយ បថវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។



អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនក្រៃលែងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង ។ (បរតត្ថាបេយ្យាល ហេចដំណើរ ពិស្តារដោយព្រះសូត្រជាបរិបុណ្ណ របស់បណ្ឌិតពោលពណ៌នា) ។

[៤៦៦] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយឯណានីមួយ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលត្រូវអាស្រ័យនូវផែនដី ឋិតនៅលើផែនដី ទើបធ្វើបាន ការងារទាំងនោះ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង រមែងធ្វើបានព្រោះផែនដី យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនក្រៃលែងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ក៏យ៉ាងនោះដែរ ។

[៦៦៧] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។បេ។ សម្មាសមាធឹ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតីតិ ។

[៦៦៨] សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។



(៦៦៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ មានការកំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ។បេ។ ចំរើននូវសម្មាសមាធិ មានការកំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង ។

(៦៦៨) ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយឯណានីមួយ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលត្រូវអាស្រ័យនូវផែនដី ឋិតនៅលើផែនដី ទើបធ្វើបាន ការងារទាំងនោះ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង គឺរមែងធ្វើបានប្រាកដ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន គឺយ៉ាងនោះដែរ ។

[៦៦៩] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ អមតោគធំ អមតបរាយនំ អមតបរិយោសានំ ។ បេ ។ សម្មាសមាធឹ ភាវេតិ អមតោគធំ អមតបរាយនំ អមតបរិយោសានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។

[៦៧០] សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។



[៦៦៩] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដោយប្រការដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលចុះស៊ប់ក្នុងអមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលចុះស៊ប់ក្នុងអមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង ។

[៦៧០] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយឯណានីមួយ ដែលបុគ្គលធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលត្រូវអាស្រ័យនូវផែនដី ឋិតនៅលើផែនដី ទើបធ្វើបាន ការងារទាំងនោះ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង រមែងធ្វើបានប្រាកដ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ក៏យ៉ាងនោះដែរ ។

(៦៧០) កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ និព្វាននិន្នំ និព្វានបោណំ និព្វានបព្ភារំ ។ បេ ។ សម្មាសមាធឹ ភាវេតិ និព្វាននិន្នំ និព្វានបោណំ និព្វានបព្ភារំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតីតិ ។

(៦៧១) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ យេ កេចិមេ ពីជគាមភូតគាមា វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពីជគាមភូតគាមា វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ



(៦៧០) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលឱនទៅកាន់ព្រះនិព្វាន ទេរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ។បេ។ ចំរើននូវសម្មាសមាធិ ដែលឱនទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង ។

(៦៧១) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ពួកពីជគាមនិងភូតគាមឯណានីមួយ ដល់នូវការចំរើនដុះដាលលូតលាស់ឡើងបាន ពួកពីជគាមនិងភូតគាមទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ទើបពួកពីជគាមនិងភូតគាមទាំងនុ៎ះ ដល់នូវការចំរើនដុះដាលលូតលាស់ឡើងបានច្រើន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ

អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។

[៦៧៣] កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ បាបុណាតិ ធម្មេសូតិ ។



ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងដល់នូវការចំរើនដុះដាលលូតលាស់ឡើងក្នុងធម៌ទាំងឡាយបាន ក៏យ៉ាងនោះដែរ ។

(៦៧៣) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងដល់នូវការចំរើនដុះដាលលូតលាស់ឡើងក្នុងធម៌ទាំងឡាយបាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងដល់នូវការចំរើនដុះដាលលូតលាស់ឡើងក្នុងធម៌ទាំងឡាយបាន យ៉ាងនេះឯង ។

(២៧៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ហិមវន្តំ ភិក្ខវេ បព្វតរាជំ និស្សាយ នាគា កាយំ វឌ្ឍេន្តិ ពលំ គាហេន្តិ តេ តត្ថ កាយំ វឌ្ឍេត្វា ពលំ គាហេត្វា កុសុព្ភេ ឱតរន្តិ កុសុព្ភេ ឱតរិត្វា មហាសោព្ភេ ឱតរន្តិ មហាសោព្ភេ ឱតរិត្វា កុន្នទិយោ ឱតរន្តិ កុន្នទិយោ ឱតរិត្វា មហានទិយោ ឱតរន្តិ មហានទិយោ ឱតរិត្វា មហាសមុទ្ទសាគរំ ឱតរន្តិ តេ តត្ថ មហន្តត្តំ វេបុល្លត្តំ អាបជ្ជន្តិ កាយេន ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ មហន្តត្តំ វេបុល្លត្តំ បាបុណាតិ ធម្មេសុ ។

(២៧៧) កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ មហន្តត្តំ វេបុល្លត្តំ បាបុណាតិ ធម្មេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ



(២៧៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ពួកនាគអាស្រ័យនូវស្តេចភ្នំឈ្មោះហិមពាន្ត ចំរើនកាយ បំប៉នកម្លាំង លុះពួកនាគនោះ ចំរើនកាយ បំប៉នកម្លាំងក្នុងទីនោះហើយ ក៏ចុះទៅកាន់បឹងតូច លុះចុះទៅកាន់បឹងតូចហើយ ក៏ចុះទៅកាន់បឹងធំ លុះចុះទៅកាន់បឹងធំហើយ ក៏ចុះទៅកាន់ស្ទឹងតូច លុះចុះទៅកាន់ស្ទឹងតូចហើយ ក៏ចុះទៅកាន់ស្ទឹងធំ លុះចុះទៅកាន់ស្ទឹងធំហើយ ក៏ចុះទៅកាន់មហាសមុទ្ទសាគរ ពួកនាគនោះក៏ដល់នូវការធំធាត់ឡើងដោយកាយក្នុងទីនោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងដល់នូវការធំទូលាយឡើងក្នុងកុសលធម៌ទាំងឡាយបាន ក៏យ៉ាងនោះដែរ ។

(២៧៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងដល់នូវការធំទូលាយឡើងក្នុងកុសលធម៌ទាំងឡាយបាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់

វោស្សគ្គបរិណាមឹ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ មហន្តត្តំ វេបុល្លត្តំ បាបុណាតិ ធម្មេសុ ។

(១៧៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ បាចីននិន្នោ បាចីនបោណោ បាចីនបព្ភារោ សោ មូលច្ឆិន្នោ កតមេន បបតេយ្យាតិ[១] យេន និន្នោ យេន បោណោ យេន បព្ភារោតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ និព្ពាននិន្នោ ហោតិ និព្ពានបោណោ និព្ពានបព្ភារោ ។

១ ម. ម. សោ មូលេ ឆិន្នោ កតមេន ឧបាតេន បបតេយ្យាតិ ។ ឱ. សោ មូលច្ឆិន្នោ កតមេន បបតេយ្យាតិ ។



បណ្តើរទៅកាន់ការលះបង់ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បណ្តើរទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តែងដល់នូវការធំទូលាយទៀតក្នុងកុសលធម៌ទាំងឡាយបាន យ៉ាងនេះឯង ។

(១៧៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលទេរទៅទិសខាងកើត ទោរទៅទិសខាងកើត ឈមទៅទិសខាងកើត លុះគេកាប់គល់ផ្តាច់ឫសហើយ ក៏រលំទៅត្រង់ទីដែលទេរ ដែលទោរ ដែលឈម យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ក៏ឈ្មោះថាជាអ្នកទេរទៅកាន់ព្រះនិព្វាន ទោរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

(២៨៧) កតមញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។



(២៨៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ឈ្មោះថាជាអ្នកឱនទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ឈ្មោះថាជាអ្នកឱនទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

[៦៧៨] សាវត្ថិនិទានំ ។ សេយ្យថាបិ ភិក្ខវេ កុម្ភោ និក្កុជ្ជោ វមតេវ ឧទកំ នោ បច្ចាវមតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វមតេវ បាបកេ អកុសលេ ធម្មេ នោ បច្ចាវមតិ ។

[៦៧៩] កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វមតេវ បាបកេ អកុសលេ ធម្មេ នោ បច្ចាវមតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ



[៦៧៨] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ក្អមដែលគេផ្កាប់ចុះ រមែងខ្ជាក់ចោលនូវទឹក មិនស្រូបចូលមកវិញឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនក្រៃលែងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងខ្ជាក់ចោលនូវអកុសលធម៌ដ៏លាមកចេញ មិនស្រូបចូលទៅវិញឡើយ ក៏យ៉ាងនោះដែរ ។

[៦៧៩] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនក្រៃលែងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងខ្ជាក់ចោលនូវអកុសលធម៌ដ៏លាមកចេញ មិនស្រូបចូលទៅវិញឡើយ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់

វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ វមតេវ បាបកេ អកុសលេ ធម្មេ នោ បច្ចាវមតីតិ ។

(៦៤០) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ សាលិសុកំ វា យវសុកំ វា សម្មាបណិហិតំ ហត្ថេន វា បាទេន វា អក្កន្តំ ហត្ថំ វា បាទំ វា ភិន្ទិស្សតិ[១] លោហិតំ វា ឧប្បាទេស្សតីតិ ឋានមេតំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ សម្មាបណិហិតត្តា ភិក្ខវេ សុកស្ស ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្វានំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ សម្មាបណិហិតត្តា ភិក្ខវេ ទិដ្ឋិយា ។

១ ម. ឆិន្ទិ ។



អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងខ្ជាក់ចោលនូវអកុសលធម៌ទាំងឡាយដ៏លាមកចេញ មិនស្រូបចូលទៅវិញឡើយ យ៉ាងនេះឯង ។

(៦៤០) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ដូចចុងស្រូវខៅស្រូវទាំងឡាយ ឬចុងស្រូវខៅស្រូវដំណើប ដែលគេដាក់ទុកដោយល្អ ដែលគេសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃឬជើងដុំខាង ពិនិញាំងឈាមឲ្យកើតឡើងបាន ហេតុនេះរមែងមាន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុចុងស្រូវខៅស្រូវគេបានដាក់ទុកដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះក៏យ៉ាងនេះឯង កាលបើទិដ្ឋិដែលភិក្ខុដំកល់ទុកដោយល្អ មគ្គភាវនាដែលភិក្ខុដំកល់ទុកដោយល្អហើយ ភិក្ខុនឹងទំលាយនូវអវិជ្ជា ពិនិញាំងវិជ្ជាឲ្យកើតឡើង ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះរមែងមាន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិ ភិក្ខុបានដំកល់ទុកដោយល្អ ។

[៦៨១] កថញ្ច ភិក្ខវេ ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទតិ វិជ្ជំ ឧប្បាទេតិ និព្វានំ សច្ឆិករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្មាបណិហិតាយ ទិដ្ឋិយា សម្មាបណិហិតាយ មគ្គភាវនាយ អវិជ្ជំ ភិន្ទតិ វិជ្ជំ ឧប្បាទេតិ និព្វានំ សច្ឆិករោតីតិ ។



[៦៨១] ម្នាលភិក្ខុទាំងឡាយ ចុះកាលទិដ្ឋិដែលភិក្ខុបានដំកល់ទុកដោយល្អ មគ្គភាវនាដែលភិក្ខុដំកល់ទុកដោយល្អហើយ ភិក្ខុរមែងទំលាយនូវអវិជ្ជា រមែងញុំាងវិជ្ជាឲ្យកើតឡើង ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលទិដ្ឋិដែលភិក្ខុបានដំកល់ទុកដោយល្អ មគ្គភាវនាដែលភិក្ខុបានដំកល់ទុកដោយល្អហើយ ភិក្ខុរមែងទំលាយនូវអវិជ្ជា រមែងញុំាងវិជ្ជាឲ្យកើតឡើង ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន យ៉ាងនេះឯង ។

(២៨៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ អាកាសេ វិវិធា វាតា វាយន្តិ បុរត្ថិមាបិ វាតា វាយន្តិ បច្ឆិមាបិ វាតា វាយន្តិ ឧត្តរាបិ វាតា វាយន្តិ ទក្ខិណាបិ វាតា វាយន្តិ សរជាបិ វាតា វាយន្តិ អរជាបិ វាតា វាយន្តិ សីតាបិ វាតា វាយន្តិ ឧណ្ហាបិ វាតា វាយន្តិ បរិត្តាបិ វាតា វាយន្តិ អធិមត្តាបិ វាតា វាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវយតោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតោ ចត្តារោបិ សតិបដ្ឋានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ សម្មប្បធានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ ឥទ្ធិបាទា ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ឥន្ទ្រិយានិ ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ពលានិ ភាវនាបារិបូរឹ គច្ឆន្តិ សត្តបិ ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តិ ។



(២៨៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ខ្យល់ផ្សេងៗ ដែលបក់ក្នុងអាកាស គឺខ្យល់ក្នុងទិសខាងកើតបក់ទៅខ្លះ ខ្យល់ទិសខាងលិចបក់ទៅខ្លះ ខ្យល់ទិសខាងជើងបក់ទៅខ្លះ ខ្យល់ទិសខាងត្បូងបក់ទៅខ្លះ ខ្យល់ប្រកបដោយធូលីបក់ទៅខ្លះ ខ្យល់មិនមានធូលីបក់ទៅខ្លះ ខ្យល់ត្រជាក់បក់ទៅខ្លះ ខ្យល់ក្តៅបក់ទៅខ្លះ ខ្យល់តិចបក់ទៅខ្លះ ខ្យល់ខ្លាំងបក់ទៅខ្លះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រៃលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សតិប្បដ្ឋាន ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា សម្មប្បធាន ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ពល ៥ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ពោជ្ឈង្គ ៧ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ក៏យ៉ាងនោះដែរ ។

(៤៨៣) កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ចត្តារោ សតិបដ្ឋានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោ សម្មប្បធានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោ ឥទ្ធិបាទា ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចិន្ទ្រិយានិ ភាវនាបារិបូរឹ គច្ឆន្តិ បញ្ច ពលានិ ភាវនាបារិបូរឹ គច្ឆន្តិ សត្ត ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ចត្តារោ សតិបដ្ឋានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោ សម្មប្បធានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោ ឥទ្ធិបាទា ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចិន្ទ្រិយានិ ភាវនាបារិបូរឹ គច្ឆន្តិ បញ្ច ពលានិ ភាវនាបារិបូរឹ គច្ឆន្តិ សត្ត ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តីតិ ។



(៤៨៣) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សតិប្បដ្ឋាន ៤ ក្តី ក៏រមែងដល់នូវការពេញលេញដោយភាវនា សម្មប្បធាន ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ពល ៥ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ពោជ្ឈង្គ ៧ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សតិប្បដ្ឋាន ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា សម្មប្បធាន ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា ពោជ្ឈង្គ ៧ ក្តី ក៏ដល់នូវការពេញលេញដោយភាវនា យ៉ាងនេះឯង ។

(៦៨៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ ឩហតំ(១) រជោជល្លំ តមេនំ មហា អកាលមេឃោ ឋានសោ អន្តរធាបេតិ វូបសមេតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។

(៦៨៧) កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ

១ ម. ឩហតំ ។



(៦៨៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ធង់ធូលីដែលហុយឡើង ក្នុងខែជាខាងចុងនៃគិម្ហរដូវ (ខែអាសាឍ) ភ្លៀងធំក្នុងកាលមិន រមែងញ៉ាំងធង់ធូលីនោះឲ្យវិនាស ឲ្យស្ងប់ស្ងាត់ទៅដោយឆាប់ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់ស្ងាត់ទៅដោយស្រួល គឺយ៉ាងនោះដែរ ។

(៦៨៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ទៅដោយស្រួល តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ

ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។

(៦៨៦) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ ឧប្បន្នំ មហាមេឃំ តមេនំ មហាវាតោ អន្តរាយេវ អន្តរធាបេតិ វូបសមេតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ អន្តរាយេវ អន្តរធាបេតិ វូបសមេតិ ។

(៦៨៧) កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ អន្តរាយេវ អន្តរធាបេតិ វូបសមេតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ



រមែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ទៅដោយស្រួល យ៉ាងនេះឯង ។

(៦៨៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ខ្យល់ធំរមែងញុំាងមេឃធំដែលកើតឡើងនោះ ឲ្យវិនាស ឲ្យស្ងប់ ក្នុងចន្លោះទៅបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញុំាងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ ក្នុងចន្លោះទៅបាន ក៏យ៉ាងនោះដែរ ។

(៦៨៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ ក្នុងចន្លោះទៅបាន តើដោយប្រការដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់

វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតីតិ ។

[២៨៨] សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ សាមុទ្ទិកាយ នាវាយ វេត្តពន្ធនពទ្ធាយ ឆ មាសានិ ឧទកេ បរិយាទាយ ហេមន្តិកេន ថលំ ឧក្ខិត្តាយ វាតាតបបរេតានិ ពន្ធនានិ តានិ បាវុស្សកេន មេឃេន អភិប្បវុដ្ឋានិ អប្បកសិរេនេវ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវយតោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតោ អប្បកសិរេនេវ សញ្ញោជនានិ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តិ ។



អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយ ៗ ឲ្យវិនាស ឲ្យស្ងប់រម្ងាប់ ក្នុងចន្លោះទៅបាន ដោយស្រួលយ៉ាងនេះឯង ។

(២៨៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ទូកដែលប្រើប្រាស់ក្នុងសមុទ្រ គេចងដោយខ្សែផ្តៅ ទម្លាក់ចុះទៅក្នុងទឹកអស់ ៦ ខែ លុះដល់ហេមន្តរដូវ ទើបគេលើកឡើងមកដាក់ទីគោក គ្រឿងចំណងនោះដែលនៅហាលខ្យល់ ហាលកំដៅថ្ងៃ លុះភ្លៀងធ្លាក់ពពកបង្អុរមក ក៏រមែងពុកផុយដោយងាយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សញ្ញោជនៈទាំងពួងក៏ស្ងប់រម្ងាប់ ស្អុយរលួយទៅ ដោយមិនយឺតយូរឡើយ ក៏យ៉ាងនោះដែរ ។

(៤៨៩) កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ អប្បកសិរេន សញ្ញោជនានិ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ អប្បកសិរេន សញ្ញោជនានិ បដិប្បស្សម្ភន្តិ បូតិកានិ ភវន្តីតិ ។

(៤៩០) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ អាគន្តុកាគារំ តត្ថ បុរត្ថិមាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ បច្ឆិមាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ ឧត្តរាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ ទក្ខិណាយបិ ទិសាយ អាគន្ត្វា វាសំ កប្បេន្តិ



(៤៨៩) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សញ្ញោជនធម៌រមែងស្ងប់រម្ងាប់ ស្អុយរលួយទៅ ដោយមិនយឺតយូរ តើដោយប្រការដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើនផ្លូវសម្មាទិដ្ឋិ ។បេ។ ចំរើនផ្លូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើនផ្លូវមគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ ធ្វើឲ្យច្រើននូវផ្លូវមគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរ សញ្ញោជនធម៌ក៏រមែងស្ងប់រម្ងាប់ ស្អុយរលួយទៅ ដោយមិនយឺតយូរឡើយ យ៉ាងនេះឯង ។

(៤៩០) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សមកកាន់ផ្ទះសម្រាប់ទទួលភ្ញៀវអំពីទិសខាងកើត សម្រេចការនៅក្នុងផ្ទះនោះក្តី មកអំពីទិសខាងលិច សម្រេចការស្នាក់នៅក្តី មកអំពីទិសខាងជើង សម្រេចការស្នាក់នៅក្តី មកអំពីទិសខាងត្បូង សម្រេចការស្នាក់នៅក្តី

ខត្តិយាបិ អាគន្ត្វា វាសំ កប្បេន្តិ ព្រាហ្មណាបិ អាគន្ត្វា វាសំ កប្បេន្តិ វេស្សាបិ អាគន្ត្វា វាសំ កប្បេន្តិ សុទ្ទាបិ អាគន្ត្វា វាសំ កប្បេន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ យេ ធម្មា អភិញ្ញា បរិញ្ញេយ្យា តេ ធម្មេ អភិញ្ញា បរិជានាតិ យេ ធម្មា អភិញ្ញា បហាតព្វា តេ ធម្មេ អភិញ្ញា បជហតិ យេ ធម្មា អភិញ្ញា សច្ឆិកាតព្វា តេ ធម្មេ អភិញ្ញា សច្ឆិករោតិ យេ ធម្មា អភិញ្ញា ភាវេតព្វា តេ ធម្មេ អភិញ្ញា ភាវេតិ ។

(៦៨១) កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច ។ សេយ្យថីទំ ។ រូបូបាទានក្ខន្ធោ ។បេ។ វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេ ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។



ពួកក្សត្រិយ៍មកសម្រេចការស្នាក់នៅក្តី ពួកព្រាហ្មណ៍មកសម្រេចការស្នាក់នៅក្តី ពួកវេស្សៈមកសម្រេចការស្នាក់នៅក្តី ពួកសុទ្ទៈមកសម្រេចការស្នាក់នៅក្តី យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណាដែលគួរកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម រមែងកំណត់ដឹងនូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរលះបង់ដោយប្រាជ្ញាដ៏ឧត្តម រមែងលះបង់នូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម រមែងធ្វើឲ្យជាក់ច្បាស់នូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរចំរើនដោយប្រាជ្ញាដ៏ឧត្តម រមែងចំរើននូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ក៏យ៉ាងនោះដែរ ។

(៦៨១) ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ។ គប្បីឆ្លើយថា ឧបាទានក្ខន្ធទាំង ៥ ឧបាទានក្ខន្ធទាំង ៥ គឺអ្វីខ្លះ ។ ឧបាទានក្ខន្ធទាំង ៥ គឺ ។ រូបូបាទានក្ខន្ធ ១ ។បេ។ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ដែលគួរកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម ។

(៦៩២) កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បហាតព្ពា ។ អវិជ្ជា ច ភវតណ្ហា ច ។ ឥមេ ភិក្ខវេ ធម្មា អភិញ្ញា បហាតព្ពា ។

(៦៩៣) កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្ពា ។ វិជ្ជា ច វិមុត្តិ ច ។ ឥមេ ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្ពា ។

(៦៩៤) កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្ពា ។ សមថោ ច វិបស្សនា ច ។ ឥមេ ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្ពា ។

(៦៩៥) កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ យេ ធម្មា អភិញ្ញា បរិញ្ញេយ្យា តេ ធម្មេ អភិញ្ញា បរិជានាតិ ។ បេ ។ យេ ធម្មា អភិញ្ញា ភាវេតព្ពា តេ ធម្មេ អភិញ្ញា ភាវេតិ ។ ឥធ ភិក្ខវេ ភិក្ខុ



(៦៩២) ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ។ គឺអវិជ្ជា១ ភវតណ្ហា១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ដែលគួរលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។

(៦៩៣) ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ។ គឺវិជ្ជា១ វិមុត្តិ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

(៦៩៤) ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរចំរើនដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ។ គឺសមថៈ១ វិបស្សនា១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ដែលគួរចំរើនដោយប្រាជ្ញាដ៏ឧត្តម ។

(៦៩៥) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យក្រាស់ក្រែលនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណាដែលគួរកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម រមែងកំណត់ដឹងនូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ។ បេ ។ ពួកធម៌ណាដែលគួរចំរើនដោយប្រាជ្ញាដ៏ឧត្តម រមែងចំរើននូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

សម្មាទិដ្ឋិំ ភាវេតិ ។ បេ ។ សម្មាសមាធិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ យេ ធម្មា អភិញ្ញា បរិញ្ញេយ្យា តេ ធម្មេ អភិញ្ញា បរិជានាតិ យេ ធម្មា អភិញ្ញា បហាតព្វា តេ ធម្មេ អភិញ្ញា បជហតិ យេ ធម្មា អភិញ្ញា សច្ឆិកាតព្វា តេ ធម្មេ អភិញ្ញា សច្ឆិករោតិ យេ ធម្មា អភិញ្ញា ភាវេតព្វា តេ ធម្មេ អភិញ្ញា ភាវេតិ ។

(៤៤៦) សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីនន្និន្នា បាចីនបោណា បាចីនបព្ភារា អថ មហាជនកាយោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ មយំ ឥមំ គង្គំ នទឹ បច្ឆានិន្នំ ករិស្សាម បច្ឆាបោណំ





ចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណាដែលគួរកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម រមែងកំណត់ដឹងនូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរលះបង់ដោយប្រាជ្ញាដ៏ឧត្តម រមែងលះបង់នូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម រមែងធ្វើឲ្យជាក់ច្បាស់នូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម ពួកធម៌ណាដែលគួរចំរើនដោយប្រាជ្ញាដ៏ឧត្តម រមែងចំរើននូវពួកធម៌នោះដោយប្រាជ្ញាដ៏ឧត្តម យ៉ាងនេះឯង ។

(៤៤៦) ម្នាលភិក្ខុទាំងឡាយ ដូចទន្លេគង្គាដែលជ្រាលទៅទិសខាងកើត ទេរទៅទិសខាងកើត ឈមទៅទិសខាងកើត កាលនោះ ពួកមហាជនកាន់យកចបនិងកញ្ជ្រែងមក និយាយថា ពួកយើងនឹងបង្វែរទន្លេគង្គានេះឲ្យជ្រាលទៅកាន់ទិសខាងលិច ឲ្យទេរទៅទិសខាងលិច

បច្ឆាបព្ភារន្តិ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ សោ មហាជនកាយោ គង្គំ នទឹ បច្ឆានិន្នំ ករេយ្យ បច្ឆាបោណំ បច្ឆាបព្ភារន្តិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ គង្គា ភន្តេ នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា សា ន សុករា បច្ឆានិន្នំ កាតុំ បច្ឆាបោណំ បច្ឆាបព្ភារំ យាវទេវ ច បន សោ មហាជនកាយោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តំ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តំ រាជានោ វា រាជមហាមត្តា វា មិត្តា វា អមច្ចា វា ញាតិសាលោហិតា វា ភោគេហិ អភិហដ្ឋុំ(១) បវារេយ្យុំ ឯហម្ភោ បុរិស កិំ តេ ឥមេ កាសាវា អនុទហន្តិ កិំ មុណ្ឌោ កបាលមនុស្សយំ(២) ចរសិ ឯហិ ហីនាយាវត្តិត្វា

១ ឱ. ម. អភិហដ្ឋុំបវារេយ្យុំ ។ ២ កបាលមនុស្សំ ។



ឲ្យឈមទៅទិសខាងលិចវិញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្ដីនោះដូចម្ដេច ពួកមហាជននោះគួរធ្វើនូវគង្គានទីឲ្យជ្រាលទៅទិសខាងលិច ឲ្យទេរទៅទិសខាងលិច ឲ្យឈមទៅទិសខាងលិចវិញ បានដែរឬ ។ បពិត្រមិនបានទេ ព្រះអង្គ ។ ដំណើរនោះតើព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន (ព្រោះ) គង្គានទីជ្រាលទៅទិសខាងកើត ទេរទៅទិសខាងកើត ឈមទៅទិសខាងកើត ទន្លេគង្គានោះគេមិនងាយនឹងធ្វើឲ្យជ្រាលទៅទិសខាងលិច ឲ្យទេរទៅទិសខាងលិច ឲ្យឈមទៅទិសខាងលិចវិញបានទេ តាំងនៅតែពួកមហាជននោះបានចំណែកនៃសេចក្ដីលំបាក សេចក្ដីហត់នឿយប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះក៏ដូច្នោះដែរ ពួកស្ដេចក្ដី ពួកមហាមាត្យនៃស្ដេចក្ដី ពួកមិត្តក្ដី ពួកអមាត្យក្ដី ពួកញាតិសាលោហិតក្ដី បបួលលោមភិក្ខុដែលកំពុងចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ កំពុងធ្វើឲ្យច្រើនក្រៃលែងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ឲ្យវិលមកត្រេកអរដោយភោគសម្បត្តិវិញថា ម្នាលបុរសអើយ អ្នកចូរមក សំពត់កាសាវៈរបស់អ្នកនេះ រឿងនឹងដុតកំដៅដល់អ្វី អ្នកម្ដេចក៏ធ្វើជាមនុស្សត្រងោល ប្រព្រឹត្តកាន់អំបែងវិញ អ្នកចូរត្រឡប់មកកាន់ហីនភេទវិញទៅ

ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ សោ វត ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តោ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោន្តោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ យញ្ហិ តំ ភិក្ខវេ ចិត្តំ ទីឃរត្តំ វិវេកនិន្នំ វិវេកបោណំ វិវេកបព្ភារំ តំ វត ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

[៦៩៧] កថញ្ច ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។



ហើយប្រើប្រាស់នូវភោគសម្បត្តិផង ធ្វើនូវបុណ្យផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺលះបង់នូវសិក្ខា ហើយត្រឡប់មកកាន់ហីនភេទវិញ ពាក្យដូច្នេះនេះមិនតាំងឋានៈឡើយ ។ ដំណើរនោះតើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តឯណា ដែលឱនទៅកាន់សេចក្តីស្ងប់ស្ងាត់ ទេរទៅកាន់សេចក្តីស្ងប់ស្ងាត់ ឈមទៅកាន់សេចក្តីស្ងប់ស្ងាត់ អស់កាលយូរ ចិត្តនោះឯង នឹងត្រឡប់មកកាន់ហីនភេទវិញ ពាក្យដូច្នេះនេះមិនមែនជាឋានៈឡើយ ។

[៦៩៧] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។បេ។

សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតីតិ ។ (យថា ពលករណីយំ តថា វិត្ថារេតព្វំ) ។

ពលករណីយវគ្គោ ឯកាទសមោ ។

## តស្សុទ្ទានំ

ពលំ ពីជញ្ច នាគោ ច
រុក្ខោ កុម្ភេន សូកិយា
អាកាសេន ច ទ្វេ មេឃា
នាវា អាគន្តុកា នទីតិ ។



ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺយ៉ាងនេះឯង ។ (បណ្ឌិតគប្បីពង្រីកសេចក្ដីក្នុងពលករណីយវគ្គឲ្យពិស្ដារផងចុះ) ។

ចប់ ពលករណីយវគ្គ ទី ១១ ។

## ឧទ្ទាននៃពលករណីយវគ្គនោះគឺ:

និយាយអំពីការងារដែលត្រូវធ្វើដោយកម្លាំង ១ អំពីពីជគាម ពីជគ្រាមដែលល្អណាស់ ១ អំពីនាគអាស្រ័យនៅភ្នំ ១ អំពីដើមឈើ ១ អំពីក្អមផ្កាប់ ១ អំពីចុងស្រូវនៃស្រូវ ១ អំពីខ្យល់ឯអាកាស ១ អំពីភ្លៀងពីរលើក អំពីនាវា ១ អំពីពួកមនុស្សមកកាន់ផ្ទះសម្រាប់ទទួលភ្ញៀវ ១ អំពីទន្លេគង្គា ១ ។

## ឯសនាវគ្គោ

(៦៤៨) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

(៦៤៩) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

## ឯសនាវគ្គ

(៦៤៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើដូចម្តេច ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៦៤៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរំលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។

(៣០០) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

(៣០១) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។

(៣០២) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។



(៣០០) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៣០១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។

(៣០២) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

[៣០៣] តាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ អមតោគធំ អមតបរាយនំ អមតបរិយោសានំ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

[៣០៤] សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។



[៣០៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលចុះស៊ប់កាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។

[៣០៤] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៣០៥) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិំ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ និព្វាននិន្នំ និព្វានបោណំ និព្វានបព្ភារំ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣០៦) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

(៣០៧) ឥមាសំ ភិក្ខវេ តិស្សន្នំ ឯសនានំ បរិញ្ញាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។





(៣០៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលឱនទៅកាន់ព្រះនិព្វាន ទេរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់នូវការស្វែងរក ៣ យ៉ាងនេះឯង ។

(៣០៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៣០៧) ម្នាលភិក្ខុទាំងឡាយ ដើម្បីកំណត់ដឹងនូវការស្វែងរក ៣ យ៉ាងនេះ ។ បេ ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣០៨) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ បេ ។ (យថា អភិញ្ញាយ តថា បរិញ្ញាយ វិត្ថារេតព្វំ) ។ បេ ។

(៣០៩) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

(៣១០) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ បរិក្ខយាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។ (យថា អភិញ្ញាយ តថា បរិញ្ញាយ វិត្ថារេតព្វំ បរិក្ខយាយ វិត្ថារេតព្វំ) ។ បេ ។



(៣០៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ បេ ។ (បណ្ឌិតគប្បីពង្រីកសេចក្តីត្រង់បទដែលថា ដើម្បីកំណត់ដឹង ឲ្យពិស្តារដូចបទដែលថា ដើម្បីដឹងច្បាស់ផងចុះ) ។ បេ ។

(៣០៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៣១០) ម្នាលភិក្ខុទាំងឡាយ ដើម្បីអស់ទៅនូវការស្វែងរក ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ (បណ្ឌិតគប្បីពង្រីកសេចក្តីត្រង់បទដែលថា ដើម្បីកំណត់ដឹង ឲ្យពិស្តារ, ដើម្បីអស់ទៅ ឲ្យពិស្តារ ឲ្យដូចបទដែលថា ដើម្បីដឹងច្បាស់ផងចុះ) ។ បេ ។

(៣០០) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

(៣០៦) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ បហានាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ បហានាយ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។ (យថាបិ អភិញ្ញាយ តថាបិ បហានាយ វិត្ថារេតព្វំ) ។ បេ ។



(៣០០) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាងតើអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

(៣០៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីលះបង់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ដើម្បីលះបង់នូវការស្វែងរក ៣ យ៉ាងនេះឯង ។ (បណ្ដាំគម្ពីរតម្រិះសេចក្ដីនេះបទដែលថា ដើម្បីលះបង់ ឲ្យពិស្ដារ ឲ្យដូចបទដែលថា ដើម្បីដឹងច្បាស់ផងចុះ) ។ បេ ។

[៣១៣] សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ វិធា ។ កតមា តិស្សោ ។ សេយ្យោហមស្មីតិ វិធា សទិសោហមស្មីតិ វិធា ហីនោហមស្មីតិ វិធា ។ ឥមា ខោ ភិក្ខវេ តិស្សោ វិធា ។

[៣១៤] ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ វិធានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋិំ ភាវេតិ ។ បេ ។ សម្មាសមាធិំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ វិធានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។ (យថា ឯសនា ឯវំ វិត្ថារេតព្វា) ។ បេ ។



[៣១៣] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រកាន់នេះមាន ៣ យ៉ាង ។ សេចក្ដីប្រកាន់ ៣ យ៉ាងតើដូចម្ដេច ។ គឺប្រកាន់ថាអញជាបុគ្គលប្រសើរ (ជាងគេ)១ ប្រកាន់ថាអញជាបុគ្គលស្មើ (នឹងគេ)១ ប្រកាន់ថាអញជាបុគ្គលថោកទាប (ជាងគេ)១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រកាន់មាន ៣ យ៉ាងនេះឯង ។

[៣១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវការប្រកាន់ ៣ យ៉ាងនេះឯង ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវការប្រកាន់ ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ (បណ្ឌិតគប្បីពង្រីកសេចក្ដីឲ្យពិស្តារ ដូចការស្វែងរកផងចុះ) ។ បេ ។

## ឯសនាវគ្គោ

[៣១៥] សាវត្ថីនិទានំ ។ តយោមេ ភិក្ខវេ អាសវា ។ កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ ឥមេ ខោ ភិក្ខវេ តយោ អាសវា ។

[៣១៦] ឥមេសំ ខោ ភិក្ខវេ តិណ្ណំ អាសវានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

[៣១៧] សាវត្ថីនិទានំ ។ តយោមេ ភិក្ខវេ ភវា ។ កាមភវោ រូបភវោ អរូបភវោ ។ ឥមេ ខោ ភិក្ខវេ តយោ ភវា ។

[៣១៨] ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ភវានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។



## ឯសនាវគ្គ

[៣១៥] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះមាន ៣ យ៉ាង ។ អាសវៈមាន ៣ យ៉ាងតើដូចម្តេច ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈមាន ៣ យ៉ាងនេះឯង ។

[៣១៦] ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវអាសវៈ ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

[៣១៧] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ភពនេះមាន ៣ យ៉ាង ។ ភពមាន ៣ យ៉ាងតើដូចម្តេច ។ គឺកាមភព ១ រូបភព ១ អរូបភព ១ ។ ម្នាលភិក្ខុទាំងឡាយ ភពមាន ៣ យ៉ាងនេះឯង ។

[៣១៨] ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវភព ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៥៩) សាវត្ថីនិទានំ ។ តិស្សោ ឥមា ភិក្ខវេ ទុក្ខតា ។ កតមា តិស្សោ ។ ទុក្ខទុក្ខតា សង្ខារទុក្ខតា វិបរិណាមទុក្ខតា ។ ឥមា ខោ ភិក្ខវេ តិស្សោ ទុក្ខតា ។

(៣៦០) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ទុក្ខតានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៦១) សាវត្ថីនិទានំ ។ តយោមេ ភិក្ខវេ ខិលា ។ កតមេ តយោ ។ រាគោ ខិលោ ទោសោ ខិលោ មោហោ ខិលោ ។ ឥមេ ខោ ភិក្ខវេ តយោ ខិលា ។

(៣៦២) ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ខិលានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។



(៣៥៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីទុក្ខនេះមាន ៣ យ៉ាង ។ សេចក្ដីទុក្ខមាន ៣ យ៉ាងតើដូចម្ដេច ។ គឺសេចក្ដីទុក្ខព្រោះអត់ធន់បានដោយក្រ ១ សេចក្ដីទុក្ខព្រោះសង្ខារ ១ សេចក្ដីទុក្ខព្រោះការប្រែប្រួល ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីទុក្ខមាន ៣ យ៉ាងនេះឯង ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសេចក្ដីទុក្ខ ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៦១) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សសរគោលនេះមាន ៣ យ៉ាង ។ សសរគោលមាន ៣ យ៉ាងតើដូចម្ដេច ។ គឺរាគៈជាសសរគោល ១ ទោសៈជាសសរគោល ១ មោហៈជាសសរគោល ១ ។ ម្នាលភិក្ខុទាំងឡាយ សសរគោលមាន ៣ យ៉ាងនេះឯង ។

(៣៦២) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសសរគោល ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

[៣៦៣] សាវត្ថីនិទានំ ។ តីណិមានិ ភិក្ខវេ ខិលានិ ។ កតមានិ តីណិ ។ រាគោ ខិលំ ទោសោ ខិលំ មោហោ ខិលំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ខិលានិ ។

[៣៦៤] ឥមេសំ ខោ ភិក្ខវេ តិណ្ណន្នំ ខិលានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

[៣៦៥] សាវត្ថីនិទានំ ។ តយោមេ ភិក្ខវេ និឃា ។ កតមេ តយោ ។ រាគោ និឃោ ទោសោ និឃោ មោហោ និឃោ ។ ឥមេ ខោ ភិក្ខវេ តយោ និឃា ។

[៣៦៦] ឥមេសំ ខោ ភិក្ខវេ តិណ្ណន្នំ និឃានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។



(៣៦៣) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ចម្រិលនេះមាន ៣ យ៉ាង ។ ចម្រិលមាន ៣ យ៉ាងតើអ្វីខ្លះ ។ គឺរាគៈជាចម្រិល ១ ទោសៈជាចម្រិល ១ មោហៈជាចម្រិល ១ ។ ម្នាលភិក្ខុទាំងឡាយ ចម្រិលមាន ៣ យ៉ាងនេះឯង ។

(៣៦៤) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវចម្រិល ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៦៥) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីលំបាកនេះមាន ៣ យ៉ាង ។ សេចក្ដីលំបាកមាន ៣ យ៉ាងតើអ្វីខ្លះ ។ គឺរាគៈជាសេចក្ដីលំបាក ១ ទោសៈជាសេចក្ដីលំបាក ១ មោហៈជាសេចក្ដីលំបាក ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីលំបាកមាន ៣ យ៉ាងនេះឯង ។

(៣៦៦) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីលះបង់ នូវសេចក្ដីលំបាក ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៦៧) សាវត្ថិនិទានំ ។ តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនា ។

(៣៦៨) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ វេទនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៦៩) តិស្សោ ឥមា ភិក្ខវេ តណ្ហា ។ កតមា តិស្សោ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥមា ខោ ភិក្ខវេ តិស្សោ តណ្ហា ។



(៣៦៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ យ៉ាង ។ វេទនាមាន ៣ យ៉ាងតើអ្វីខ្លះ ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ យ៉ាងនេះឯង ។

(៣៦៨) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនអរិយមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវវេទនា ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើនអរិយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រ-សើរនេះ ។

(៣៦៩) ម្នាលភិក្ខុទាំងឡាយ តណ្ហានេះមាន ៣ យ៉ាង ។ តណ្ហាមាន ៣ យ៉ាងតើអ្វីខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាមាន ៣ យ៉ាងនេះឯង ។

(៣៣០) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ តណ្ហានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មា-ទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេ-កនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណា-មឹ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ តណ្ហានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៣១) តិស្សោ ឥមា ភិក្ខវេ តណ្ហា ។បេ។



(៣៣០) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវតណ្ហា ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។បេ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវតណ្ហា ៣ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៣១) ម្នាលភិក្ខុទាំងឡាយ តណ្ហានេះមាន ៣ យ៉ាង ។បេ។

(៣៣៦) ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ តណ្ហានំ(១) អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ បេ ។ អមតោគធំ អមតបរាយនំ អមតបរិយោសានំ ។ បេ ។ និព្វាននិន្នំ និព្វានពោណំ និព្វានបព្ភារំ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ តណ្ហានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

ឯសនាវគ្គោ ទ្វាទសមោ ។

តស្សុទ្ទានំ

ឯសនា វិធា អាសវោ
ទុក្ខតា ច តិស្សោ ខិលា(២)
មលំ នីឃោ ច វេទនា
ទុវេ តណ្ហាយេន(៣) ចាតិ ។

១ ម. ឧ. តសិនានំ ។ ២ ឥតិ ទុក្ខតា ច ខិលា ។ ៣ នីឃោ ច វេទនា ទ្វេ តណ្ហា តសិនាយ ចាតិ ។



(៣៣៦) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវតណ្ហា ៣ យ៉ាងនេះឯង ។ បេ ។ (ភិក្ខុចំរើនផ្លូវសម្មាទិដ្ឋិ) មានការកំចាត់បង់នូវរាគៈជាទីបំផុត កំចាត់បង់នូវទោសៈជាទីបំផុត កំចាត់បង់នូវមោហៈជាទីបំផុត ។ បេ ។ ចុះស៊ប់កាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បេ ។ ឱនទៅកាន់ព្រះនិព្វាន ទេរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវតណ្ហា ៣ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

ចប់ ឯសនាវគ្គទី ១២ ។

## ឧទ្ទាននៃឯសនាវគ្គនោះគឺ

និយាយអំពីការស្វែងរក ១ អំពីការប្រកាន់ ១ អំពីអាសវៈ ១ អំពីទុក្ខតាភព ១ អំពីសសរគោល ៣ យ៉ាង ១ អំពីមន្ទិល ១ អំពីសេចក្តីលំបាក ១ អំពីវេទនា ១ អំពីការអស់ទៅនៃតណ្ហា ២ លើក ។

## ឱឃវគ្គោ

(៣៣៣) សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ ឱឃា ។ កតមេ ចត្តារោ ។ កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោឃោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឱឃា ។

(៣៣៤) ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឱឃានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។ (យថា ឯសនា ឯវំ វិត្ថារេតព្វំ) ។

(៣៣៥) សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ យោគា ។ កតមេ ចត្តារោ ។ កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ យោគា ។

## ឱឃវគ្គ

(៣៣៣) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឱឃៈ (អន្លង់) នេះមាន ៤ យ៉ាង ។ ឱឃៈមាន ៤ យ៉ាងតើអ្វីខ្លះ ។ គឺកាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ឱឃៈមាន ៤ យ៉ាងនេះឯង ។

(៣៣៤) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឱឃៈ ៤ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ (បណ្ឌិតគប្បីពង្រីកសេចក្ដីឲ្យពិស្ដារ ដូចសេចក្ដីស្វែងរកដទៃចុះ) ។

(៣៣៥) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ យោគៈ (គឺកិលេសជាគ្រឿងប្រកប) នេះមាន ៤ យ៉ាង ។ យោគៈមាន ៤ យ៉ាងតើអ្វីខ្លះ ។ គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ យោគៈមាន ៤ យ៉ាងនេះឯង ។

(៣៣៦) ឥមេសំ ខោ ភិក្ខវេ ចតុន្នំ យោគានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៣៧) សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ ឧបាទានានិ ។ កតមានិ ចត្តារិ ។ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ឧបាទានានិ ។

(៣៣៨) ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឧបាទានានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។



(៣៣៦) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវយោគៈ ៤ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៣៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឧបាទាន (សេចក្តីប្រកាន់មាំ) នេះមាន ៤ យ៉ាង ។ ឧបាទានមាន ៤ យ៉ាងតើអ្វីខ្លះ ។ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានមាន ៤ យ៉ាងនេះឯង ។

(៣៣៨) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧបាទាន ៤ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៣៩) សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ គន្ថា ។ កតមេ ចត្តារោ ។ អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ គន្ថា ។

(៣៤០) ឥមេសំ ខោ ភិក្ខវេ ចតុន្នំ គន្ថានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៤១) សាវត្ថីនិទានំ ។ សត្តិមេ ភិក្ខវេ អនុសយា ។ កតមេ សត្ត ។ កាមរាគានុសយោ បដិឃានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ។ ឥមេ ខោ ភិក្ខវេ សត្ត អនុសយា ។



(៣៣៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ គន្ថៈ(កិលេសជាគ្រឿងចាក់ក្រង) នេះមាន ៤ យ៉ាង ។ គន្ថៈ ៤ យ៉ាងតើដូចម្តេច ។ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ[១] ១ ។ ម្នាលភិក្ខុទាំងឡាយ គន្ថៈមាន ៤ យ៉ាងនេះឯង ។

(៣៤០) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនអរិយមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវគន្ថៈ ៤ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនអរិយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៤១) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អនុស័យ កិលេសជាគ្រឿងដេកត្រាំ នេះមាន ៧ យ៉ាង ។ អនុស័យ ៧ យ៉ាង តើដូចម្តេច ។ កាមរាគានុស័យ ១ បដិឃានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ មានានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុស័យមាន ៧ យ៉ាងនេះឯង ។

---

១ កិលេសជាគ្រឿងចាក់ក្រងនូវនាមកាយ គឺសេចក្តីប្រកាន់ថា នេះជារបស់ទៀង ដោយអំណាចនៃអត្តទិដ្ឋិ (អដ្ឋកថា) ។

[៣៦៦] ឥមេសំ ខោ ភិក្ខវេ សត្តន្នំ អនុសយានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

[៣៦៧] សាវត្ថីនិទានំ ។ បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ។បេ។ ឃានវិញ្ញេយ្យា គន្ធា ។ ជិវ្ហាវិញ្ញេយ្យា រសា ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។

[៣៦៨] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ កាមគុណានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។បេ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។



[៣៦៦] ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវអនុស័យ ៧ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

[៣៦៧] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្តេច ។ គឺរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ។បេ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ។ រសដែលគប្បីដឹងដោយអណ្តាត ។ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ កាមគុណមាន ៥ យ៉ាងនេះឯង ។

[៣៦៨] ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវកាមគុណ ៥ យ៉ាងនេះឯង ។បេ។ ភិក្ខុគប្បីចំរើនមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

[៣៤៥] សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ នីវរណានិ ។ កតមានិ បញ្ច ។ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។ ឥមានិ ខោ ភិក្ខវេ បញ្ច នីវរណានីតិ ។

[៣៤៦] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ នីវរណានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

[៣៤៧] សាវត្ថីនិទានំ ។ បញ្ចិមេ ភិក្ខវេ ឧបាទានក្ខន្ធា ។ កតមេ បញ្ច ។ សេយ្យថីទំ ។ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ ឥមេ ខោ ភិក្ខវេ បញ្ចុបាទានក្ខន្ធាតិ ។



(៣៤៥) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ នីវរណៈ (កិលេសជាគ្រឿងរាំង) នេះមាន ៥ យ៉ាង ។ នីវរណៈ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺកាមច្ឆន្ទនីវរណៈ១ ព្យាបាទនីវរណៈ១ ថីនមិទ្ធនីវរណៈ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ១ វិចិកិច្ឆានីវរណៈ១ ។ ម្នាលភិក្ខុទាំងឡាយ នីវរណៈមាន ៥ យ៉ាងនេះឯង ។

(៣៤៦) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវនីវរណៈ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៤៧) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធនេះមាន ៥ យ៉ាង ។ ឧបាទានក្ខន្ធ ៥ យ៉ាងតើដូចម្តេច ។ គឺអ្វីខ្លះ ។ គឺរូបូបាទានក្ខន្ធ១ វេទនូបាទានក្ខន្ធ១ សញ្ញូបាទានក្ខន្ធ១ សង្ខារូបាទានក្ខន្ធ១ វិញ្ញាណូបាទានក្ខន្ធ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធមាន ៥ យ៉ាងនេះឯង ។

(៣៤៨) ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧបាទានក្ខន្ធានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៤៩) សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឱរម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ច ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ កាមច្ឆន្ទោ ព្យាបាទោ ។ ឥមានិ ខោ ភិក្ខវេ បញ្ចោរម្ភាគិយានិ សំយោជនានិ ។

(៣៥០) ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

(៣៥១) សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សំយោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សំយោជនានិ ។



(៣៤៨) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧបាទានក្ខន្ធ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៤៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងក្រោមនេះ មាន ៥ យ៉ាង ។ សញ្ញោជនៈ ៥ យ៉ាងតើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងក្រោម មាន ៥ យ៉ាងនេះឯង ។

(៣៥០) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើននូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

(៣៥១) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះ មាន ៥ យ៉ាង ។ សញ្ញោជនៈ ៥ យ៉ាងតើអ្វីខ្លះ ។ គឺរូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ យ៉ាងនេះឯង ។

[៣៨៦] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។ សេយ្យថាបិ ភិក្ខវេ គង្គា នទី ។ បេ ។

[៣៨៧] សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។





[៣៨៦] ម្នាលភិក្ខុទាំងឡាយ (ភិក្ខុសម្បយុត្តដោយមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុសម្បយុត្តដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុសម្បយុត្តដោយមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុសម្បយុត្តដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចទន្លេគង្គា ។ បេ ។

[៣៨៧] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះ មាន ៥ យ៉ាង ។ សញ្ញោជនៈ ៥ យ៉ាង តើដូចម្តេច ។ គឺរូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ យ៉ាងនេះឯង ។

(៣៥៤) ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សំយោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោ ។ កតមោ អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខវេ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ អមតោគធំ អមតបរាយនំ អមតបរិយោសានំ និព្វាននិន្នំ និព្វានបោណំ និព្វានបព្ភារំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សំយោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ។ បេ ។ អយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវេតព្វោតិ ។

ឱឃវគ្គោ តេរសមោ ។



(៣៥៤) ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងចំរើននូវសម្មាទិដ្ឋិ ។ បេ ។ ចំរើននូវសម្មាសមាធិ ដែលមានការកំចាត់បង់នូវរាគៈជាទីបំផុត មានការកំចាត់បង់នូវទោសៈជាទីបំផុត មានការកំចាត់បង់នូវមោហៈជាទីបំផុត ដែលចុះស៊ប់ទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ដែលឱនទៅកាន់ព្រះនិព្វាន ទេរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុគប្បីចំរើនផ្លូវមគ្គ) ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ យ៉ាងនេះឯង ។ បេ ។ ភិក្ខុគប្បីចំរើនផ្លូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ ។

ចប់ ឱឃវគ្គ ទី ១៣ ។

ឃោសេច្ច

## តស្សុទ្ទានំ

ឱឃោ យោគោ ទុចាពាធំ

គន្ថំ អនុសយេន ច

កាមគុណា នីវរណា

ខន្ធា ឧទ្ធម្ភាគិយានិ ។

ឧឡូសំយុត្ត សមត្ថ ។



ឧបវត្ថុ

## ឧទ្ទាននៃនិយវគ្គតោះពី

និយាយអំពីឱឃៈ១ អំពីយោគៈ១ អំពីទុចាតខ១ អំពី

គន្ថៈ១ អំពីអនុស័យៈ១ អំពីកាមគុណ១ អំពីនីវរណៈ១

អំពីខន្ធ១ អំពីសញ្ញោជនៈជាចំណែកខាងក្រោម១ ខាង

លើ១ ។

ចប់ ឧឡូសំយុត្ត ។

# ពោជ្ឈង្គសំយុត្តំ

## បព្វតវគ្គោ

[៣៨៨] ហិមវន្តំ[១] ភិក្ខវេ បព្វតរាជំ និស្សាយ នាគា កាយំ វឌ្ឍេន្តិ ពលំ គាហេន្តិ តេ តត្ថ កាយំ វឌ្ឍេត្វា ពលំ គាហេត្វា កុសុព្ភេ ឱតរន្តិ កុសុព្ភេ ឱតរិត្វា មហាសោព្ភេ ឱតរន្តិ មហាសោព្ភេ ឱតរិត្វា កុន្នទិយោ ឱតរន្តិ កុន្នទិយោ ឱតរិត្វា មហានទិយោ ឱតរន្តិ មហានទិយោ ឱតរិត្វា មហាសមុទ្ទសាគរំ ឱតរន្តិ តេ តត្ថ មហន្តត្តំ វេបុល្លត្តំ អាបជ្ជន្តិ កាយេន ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ មហន្តត្តំ វេបុល្លត្តំ បាបុណាតិ ធម្មេសុ ។

១ ម. សារត្ថ ។ ពត្រ បាឋ ។ ឥ. សារត្ថទីបនី ។

# ពោជ្ឈង្គសំយុត្ត

## បព្វតវគ្គ

(៣៨៨) ម្នាលភិក្ខុទាំងឡាយ នាគទាំងឡាយតែងធ្វើកាយឲ្យចំរើន ឲ្យមានកម្លាំង ព្រោះអាស្រ័យស្តេចភ្នំឈ្មោះហិមវន្ត នាគទាំងនោះលុះធ្វើកាយឲ្យចំរើន ឲ្យមានកម្លាំង ក្នុងស្តេចភ្នំឈ្មោះហិមវន្តនោះហើយ ទើបចុះក្នុងបឹងតូច លុះចុះក្នុងបឹងតូចហើយ ទើបចុះក្នុងបឹងធំ លុះចុះក្នុងបឹងធំហើយ ទើបចុះក្នុងស្ទឹងតូច លុះចុះក្នុងស្ទឹងតូចហើយ ទើបចុះក្នុងស្ទឹងធំ លុះចុះក្នុងស្ទឹងធំហើយ ទើបចុះកាន់មហាសមុទ្ទសាគរ នាគទាំងនោះ រមែងមានកាយដល់នូវការចំរើនធំទូលាយក្នុងមហាសមុទ្ទសាគរនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងនៅក្នុងសីល កាលចំរើននូវពោជ្ឈង្គ (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ទាំង ៧ កាលធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងដល់នូវការចំរើន ធំទូលាយក្នុងធម៌ទាំងឡាយ យ៉ាងនោះឯង ។

(៣៨៦) កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ធម្មេ ភាវេន្តោ សត្ត ធម្មេ ពហុលីករោន្តោ វេបុល្លំ មហត្តំ បាបុណាតិ ធម្មេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ វីរិយសម្ពោជ្ឈង្គំ ភាវេតិ ។ បីតិសម្ពោជ្ឈង្គំ ភាវេតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ ។ សមាធិសម្ពោជ្ឈង្គំ ភាវេតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ធម្មេ ភាវេន្តោ សត្ត ធម្មេ ពហុលីករោន្តោ វេបុល្លំ មហត្តំ បាបុណាតិ ធម្មេសូតិ ។



(៣៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងស៊ប់នៅក្នុងសីល កាលចំរើននូវធម្មទាំង ៧ កាលធ្វើឲ្យច្រើននូវធម្មទាំង ៧ តែងដល់នូវការចំរើនធំទូលាយក្នុងធម៌ទាំងឡាយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតណ្ហា អាស្រ័យសេចក្តីរលត់ បង្អោនទៅរកការលះបង់ ចំរើនធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ចំរើនវីរិយសម្ពោជ្ឈង្គ ។ ចំរើនបីតិសម្ពោជ្ឈង្គ ។ ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ។ ចំរើនសមាធិសម្ពោជ្ឈង្គ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតណ្ហា អាស្រ័យសេចក្តីរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងនៅស៊ប់ក្នុងសីល កាលចំរើននូវធម្មទាំង ៧ កាលធ្វើឲ្យច្រើននូវធម្មទាំង ៧ រមែងដល់នូវការចំរើនធំទូលាយក្នុងធម៌ទាំងឡាយ យ៉ាងនេះឯង ។

[៣៨៧] សេយ្យថាបិ ភិក្ខវេ អយំ កាយោ អាហារដ្ឋិតិកោ អាហារំ បដិច្ច តិដ្ឋតិ អនាហារោ នោ តិដ្ឋតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ច នីវរណា អាហារដ្ឋិតិកា អាហារំ បដិច្ច តិដ្ឋន្តិ អនាហារា នោ តិដ្ឋន្តិ ។

[៣៨៨] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ សុភនិមិត្តំ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។



[៣៨៧] ម្នាលភិក្ខុទាំងឡាយ កាយនេះតាំងនៅដោយអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ នីវរណៈទាំង ៥ តាំងនៅដោយសារអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ ក៏យ៉ាងនោះដែរ ។

[៣៨៨] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងកាមច្ឆន្ទៈ មិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងកាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយឡើង ។ ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តមានមែន ការធ្វើទុកក្នុងចិត្តខុសទំនងនឹងការធ្វើឲ្យច្រើនក្រៃលែងក្នុងសុភនិមិត្តនោះ នេះជាអាហារដែលញ៉ាំងកាមច្ឆន្ទៈមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងកាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។

(៣៥៩) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ បដិឃនិមិត្តំ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។

(៣៦០) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ អរតិ តន្ទិ វិជម្ភិតា ភត្តសម្មទោ ចេតសោ ច លីនត្តំ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។



(៣៥៩) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងព្យាបាទដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្ត (និមិត្តចាំឲ្យបង្វៀរទង្គល់ចិត្ត) រមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនងនឹងធ្វើឲ្យច្រើនក្រៃលែងក្នុងបដិឃនិមិត្តនោះ នេះជាអាហារដែលញ៉ាំងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងព្យាបាទដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងថីនមិទ្ធមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងថីនមិទ្ធដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុញទ្រាន់ សេចក្តីខ្ជិល មិនតក់កាយ ពុលបាយ រួញចិត្តរមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនងនឹងការធ្វើឲ្យច្រើនក្រៃលែងក្នុងការទាំងនោះ នេះជាអាហារដែលញ៉ាំងថីនមិទ្ធមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងថីនមិទ្ធដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។

[៣៦១] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ ចេតសោ អវូបសមោ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។

[៣៦២] កោ ច ភិក្ខវេ អាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ វិចិកិច្ឆាដ្ឋានិយា ធម្មា តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។

[៣៦៣] សេយ្យថាបិ ភិក្ខវេ អយំ កាយោ អាហារដ្ឋិតិកោ អាហារំ បដិច្ច តិដ្ឋតិ អនាហារោ នោ តិដ្ឋតិ ។ ឯវមេវ ខោ ភិក្ខវេ បញ្ច នីវរណា



[៣៦១] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងឧទ្ធច្ចកុក្កុច្ចមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនស្ងប់ចិត្តរមែងមាន ការធ្វើទុកក្នុងចិត្តមិនត្រូវទំនងនឹងការធ្វើឲ្យក្រាស់ក្រែលក្នុងរឿងនោះ នេះជាអាហារដែលញ៉ាំងឧទ្ធច្ចកុក្កុច្ចមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារដែលញ៉ាំងវិចិកិច្ឆាមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងវិចិកិច្ឆាដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃវិចិកិច្ឆារមែងមាន ការធ្វើទុកក្នុងចិត្តមិនត្រូវទំនងនឹងការធ្វើឲ្យក្រាស់ក្រែលក្នុងធម៌ទាំងនោះ នេះជាអាហារដែលញ៉ាំងវិចិកិច្ឆាមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងវិចិកិច្ឆាដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ។

[៣៦៣] ម្នាលភិក្ខុទាំងឡាយ កាយនេះតែងតាំងនៅព្រោះអាហារ ព្រោះអាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ នីវរណៈទាំង ៥ នេះ

អាហារដ្ឋិតិកា អាហារំ បដិច្ច តិដ្ឋន្តិ អនាហារា នោ តិដ្ឋន្តិ ។

(៣៦៤) សេយ្យថាបិ ភិក្ខវេ អយំ កាយោ អាហារដ្ឋិតិកោ អាហារំ បដិច្ច តិដ្ឋតិ អនាហារោ នោ តិដ្ឋតិ ។ ឯវមេវ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា អាហារដ្ឋិតិកា អាហារំ បដិច្ច តិដ្ឋន្តិ អនាហារា នោ តិដ្ឋន្តិ ។

(៣៦៥) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



តែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារក៏តាំងនៅមិនបានទេ យ៉ាងនោះដែរ ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ កាយនេះតែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ តែងតាំងនៅព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ ក៏យ៉ាងនោះដែរ ។

[៣៦៥] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យដល់នូវការចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គរមែងមាន ការធ្វើទុកក្នុងចិត្ត ត្រូវទំនងនឹងធ្វើឲ្យច្រើនក្រៃលែងក្នុងធម៌ទាំងនោះ នេះជាអាហារនៃសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យដល់នូវការចំរើនពេញលេញឡើងបាន ។

(៣៦៦) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កុសលាកុសលា ធម្មា សាវជ្ជានវជ្ជា ធម្មា ហីនប្បណីតា ធម្មា កណ្ហសុក្កសប្បដិភាគា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៣៦៧) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ អារព្ភធាតុ និក្កមធាតុ បរក្កមធាតុ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



(៣៦៦) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនៃធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនៃធម្មវិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរីករាលចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាកុសលនិងអកុសល ធម៌ដែលប្រកបដោយទោសនិងមិនមានទោស ធម៌ថោកទាបនិងឧត្តម ធម៌ជាចំណែកគូសត្រា គឺធម៌ខ្មៅនិងធម៌ស រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវនឹងផ្លូវឲ្យច្រើនក្រៃលែងក្នុងធម៌ទាំងនោះ នេះជាអាហារនៃធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនៃធម្មវិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរីករាលចំរើនពេញលេញឡើងបាន ។

(៣៦៧) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនៃវីរិយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនៃវីរិយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរីករាលចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធាតុគឺសេចក្ដីផ្ដើម ធាតុគឺសេចក្ដីព្យាយាម ធាតុគឺសេចក្ដីខ្នះខ្នែងប្រឹងប្រែង រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវនឹងផ្លូវឲ្យច្រើនក្រៃលែងក្នុងធាតុទាំងនោះ នេះជាអាហារនៃវីរិយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនៃវីរិយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរីករាលចំរើនពេញលេញឡើងបាន ។

(៣៦៨) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ បីតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៣៦៩) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កាយបស្សទ្ធិ ចិត្តបស្សទ្ធិ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



(៣៦៨) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គរមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនងនឹងធ្វើឲ្យច្រើនក្រៃលែងក្នុងធម៌ទាំងនោះ នេះជាអាហារនាំបីតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

(៣៦៩) ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំបស្សទ្ធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនងនឹងធ្វើឲ្យច្រើនក្រៃលែងក្នុងសេចក្តីស្ងប់ទាំងនោះ នេះជាអាហារនាំបស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

[៣៧០] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សមថនិមិត្តំ អព្យគ្គនិមិត្តំ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

[៣៧១] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ ឧបេក្ខាសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



[៣៧០] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ហេតុនៃការតាំងចិត្តមាំ ហេតុមិនរាយមាយ រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវផង និងការធ្វើឲ្យច្រើនក្រៃលែងក្នុងហេតុទាំងនោះ នេះជាអាហារនាំសមាធិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

[៣៧១] ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហារនាំឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គរមែងមាន ការធ្វើទុកក្នុងចិត្តត្រូវផង និងការធ្វើឲ្យច្រើនក្រៃលែងក្នុងធម៌ទាំងនោះ នេះជាអាហារនាំឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

បព្វតវគ្គោ

(៣៧២) សេយ្យថាបិ ភិក្ខវេ អយំ កាយោ អាហារដ្ឋិតិកោ អាហារំ បដិច្ច តិដ្ឋតិ អនាហារោ នោ តិដ្ឋតិ ។ ឯវមេវ ខោ ភិក្ខវេ ឥមេ សត្ត ពោជ្ឈង្គា អាហារដ្ឋិតិកា អាហារំ បដិច្ច តិដ្ឋន្តិ អនាហារា នោ តិដ្ឋន្តិ ។

(៣៧៣) យេ តេ ភិក្ខវេ ភិក្ខូ សីលសម្បន្នា សមាធិសម្បន្នា បញ្ញាសម្បន្នា(១) វិមុត្តិសម្បន្នា វិ-មុត្តិញាណទស្សនសម្បន្នា ទស្សនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហូបការំ វទាមិ សវនម្បហំ ភិក្ខវេ

១ ម. ញាណសម្បន្នា ។



បព្វតវគ្គ

(៣៧២) ម្នាលភិក្ខុទាំងឡាយ កាយនេះដែលតាំងនៅព្រោះអាហារ ក៏ស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ សោត ដែលតាំងនៅព្រោះអាហារ ក៏ស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបានទេ ក៏យ៉ាងនោះដែរ ។

(៣៧៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយឯណាបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ) ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវការឃើញនូវភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវការស្តាប់

តេសំ ភិក្ខូនំ ពហូបការំ វទាមិ ឧបសង្កមនម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហូបការំ វទាមិ បយិរុបាស-នម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហូបការំ វទាមិ អ-នុស្សតិម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហូបការំ វទាមិ អនុប្បព្វជ្ជម្បហំ ភិក្ខវេ តេសំ ភិក្ខូនំ ពហូបការំ វទាមិ ។ តំ កិស្ស ហេតុ ។ តថារូបានំ ភិក្ខវេ ភិក្ខូនំ ធម្មំ សុត្វា ទ្វយេន(១) វូបកដ្ឋោ វិហរតិ កាយវូបកាសេន ច ចិត្តវូបកាសេន ច ។ សោ តថា វូបកដ្ឋោ វិហរន្តោ តំ ធម្មំ អនុស្សរតិ អនុវិតក្កេតិ ។

[៣៧៦] យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថា វូប-កដ្ឋោ វិហរន្តោ តំ ធម្មំ អនុស្សរតិ អនុវិតក្កេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនា-បារិបូរឹ គច្ឆតិ ។ សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ ។

១ ឱ. ម. វូបកាសេន ។



នូវភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវការចូលទៅរកភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវការចូលទៅអង្គុយជិតភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរនូវការរឭករឿយ ៗ នូវភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ម្នាលភិក្ខុទាំង-ឡាយ តថាគតសរសើរនូវការបួសតាមភិក្ខុទាំងនោះថាជាការមានឧបការៈច្រើន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលបានស្តាប់ធម៌របស់ពួកភិក្ខុបែបនោះហើយ រមែងឃ្លាតចេញដោយការឃ្លាតកាយខ្លះ ការឃ្លាតចិត្តខ្លះ កាលបើភិក្ខុនោះឃ្លាតចេញដូច្នោះហើយ រមែងរឭករឿយ ៗ ត្រិះរិះរឿយ ៗ នូវធម៌នោះ ។

(៣៧៦) ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុបានឃ្លាតចេញយ៉ាងនោះ ហើយរឭករឿយ ៗ ត្រិះរិះរឿយ ៗ នូវធម៌នោះ សតិ-សម្ពោជ្ឈង្គ ឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនសតិសម្ពោជ្ឈង្គក្នុងសម័យនោះ សតិសម្ពោជ្ឈង្គក៏បានពេញលេញព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ ភិក្ខុនោះដែលមានសតិរស់នៅដូច្នោះ ឈ្មោះថាពិចារណា ត្រិះរិះនូវធម៌នោះដោយបញ្ញា ។

(៣៧៥) យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថា សតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ធម្មវិចយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរិវីមំសមាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ។

(៣៧៦) យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរិវីមំសមាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា ។



(៣៧៥) ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុបានខំរឭកដូច្នោះ ពិចារណា ត្រិះរិះគន់គូរនូវធម៌នោះដោយបញ្ញាហើយ ធម្មវិចយសម្ពោជ្ឈង្គឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនធម្មវិចយសម្ពោជ្ឈង្គក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គក៏បានពេញលេញព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ កាលភិក្ខុនោះពិចារណា ត្រិះរិះគន់គូរនូវធម៌នោះដោយបញ្ញា សេចក្តីព្យាយាមមិនធូរថយ ឈ្មោះថាបានប្រារព្ធហើយ ។

(៣៧៦) ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុពិចារណា ត្រិះរិះគន់គូរនូវធម៌នោះដោយបញ្ញា សេចក្តីព្យាយាមមិនធូរថយឈ្មោះថាបានប្រារព្ធហើយ វីរិយសម្ពោជ្ឈង្គឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើននូវវីរិយសម្ពោជ្ឈង្គក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គក៏បានពេញលេញព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ បីតិដែលប្រាសចាកអាមិស កើតឡើងដល់ភិក្ខុដែលមានព្យាយាមបរិបូណ៌ហើយ ។

[៣៧៧] យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ ។

[៣៧៨] យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ ។





(៣៧៧) ម្នាលភិក្ខុទាំងឡាយ បីតិដែលប្រាសចាកអាមិស កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាមហើយក្នុងសម័យណា បីតិសម្ពោជ្ឈង្គ ឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើននូវបីតិសម្ពោជ្ឈង្គក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គក៏បានពេញលេញព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ ចិត្តក៏ស្ងប់រម្ងាប់បាន ។

(៣៧៨) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ ចិត្តក៏ស្ងប់រម្ងាប់ ក្នុងសម័យណា បស្សទ្ធិសម្ពោជ្ឈង្គ ឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើននូវបស្សទ្ធិសម្ពោជ្ឈង្គក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គក៏បានពេញលេញព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ កាលបើភិក្ខុមានកាយស្ងប់រម្ងាប់ប្រកបដោយសេចក្តីសុខ ចិត្តក៏តាំងនៅមាំ ។

(៣៧៩) យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធោ ហោតិ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ សោ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។

(៣៨០) យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។

(៣៨១) ឯវំ ភាវិតេសុ ខោ ភិក្ខវេ សត្តសុ ពោជ្ឈង្គេសុ ឯវំ ពហុលីកតេសុ សត្ត ផលា សត្តានិសំសា បាដិកង្ខា ។ កតមេ សត្ត ផលា សត្តានិសំសា ។





(៣៧៩) ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់ភិក្ខុអ្នកមានកាយស្ងប់រម្ងាប់ មានសេចក្ដីសុខ ជួនតាំងមាំក្នុងសម័យណា ម្នាលភិក្ខុទាំងឡាយ សមាធិសម្ពោជ្ឈង្គ ឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើននូវសមាធិសម្ពោជ្ឈង្គក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គក៏បានពេញលេញ ព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថាធ្វើចិត្តដែលតាំងមាំយ៉ាងនោះឲ្យជាឧបេក្ខាបានល្អ ។

(៣៨០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើចិត្តដែលតាំងមាំយ៉ាងនោះឲ្យជាឧបេក្ខាបានល្អក្នុងសម័យណា ឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថាភិក្ខុបានប្រារព្ធហើយក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើននូវឧបេក្ខាសម្ពោជ្ឈង្គក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គក៏បានពេញលេញ ព្រោះការចំរើនរបស់ភិក្ខុក្នុងសម័យនោះ ។

(៣៨១) ម្នាលភិក្ខុទាំងឡាយ កាលបើពោជ្ឈង្គទាំង ៧ ដែលភិក្ខុបានចំរើនយ៉ាងនេះ ធ្វើឲ្យក្រាស់ក្រែលយ៉ាងនេះហើយ រមែងបានផល ៧ គឺអានិសង្ស ៧ ។ ផលទាំង ៧ គឺអានិសង្សទាំង ៧ តើអ្វីខ្លះ ។

(៣៨៦) ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ អថ មរណកាលេ អញ្ញំ អារាធេតិ ។ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ មរណកាលេ អញ្ញំ អារាធេតិ អថ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ មរណកាលេ អញ្ញំ អារាធេតិ នោ ចេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ អថ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ ។ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ



(៣៨៦) ភិក្ខុរមែងសម្រេចនូវព្រះអរហត្តផលក្នុងបច្ចុប្បន្ននេះឯងមុន (ស្លាប់) បើមិនសម្រេចអរហត្តផលក្នុងបច្ចុប្បន្នមុនស្លាប់ទេ រមែងសម្រេចអរហត្តផលក្នុងកាលជិតស្លាប់ ។ បើមិនសម្រេចអរហត្តផលក្នុងបច្ចុប្បន្នមុនស្លាប់ទេ បើមិនសម្រេចអរហត្តផលក្នុងកាលជិតស្លាប់ទេ គង់បានជាអន្តរាបរិនិព្វាយី(១) ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ បើមិនសម្រេចអរហត្តផលក្នុងបច្ចុប្បន្នមុនស្លាប់ទេ បើមិនសម្រេចអរហត្តផលក្នុងកាលជិតស្លាប់ទេ បើមិនបានជាអន្តរាបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ គង់បានជាឧបហច្ចបរិនិព្វាយី(២) ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ បើមិនសម្រេចអរហត្តផលក្នុងបច្ចុប្បន្នមុនស្លាប់ទេ

---

១ ព្រះអនាគាមីអស់សំយោជនៈខាងក្រោម ៥ ហើយ សម្រេចអរហត្តបរិនិព្វានក្នុងកាលអាយុមិនទាន់ដល់ពាក់កណ្ដាល ហៅថា អន្តរាបរិនិព្វាយី ដូចជាលោកដែលកើតក្នុងព្រហ្មជាន់អវិហាមានកំណត់អាយុ ១ ពាន់កប្ប បើបានបរិនិព្វានក្នុងវេលាអាយុបាន ១ រយកប្បក្តី ២ រយកប្បក្តី ៤ រយកប្បក្តី ក៏ហៅថា អន្តរាបរិនិព្វាយី ដូចគ្នាទាំង ៣ ពួកនោះ ។ តាមអដ្ឋកថាសារត្ថប្បកាសិនី ។ ២ ព្រះអនាគាមីដែលទៅកើតក្នុងព្រហ្មជាន់សុទ្ធាវាស សម្រេចអរហត្តបរិនិព្វានក្នុងវេលាអាយុហួសពាក់កណ្ដាលហើយ ហៅថា ឧបហច្ចបរិនិព្វាយី ។

យោ ច មរណកាលេ អញ្ញំ អារាធេតិ យោ ច បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ យោ ច បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ អយំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ ។ យោ ច ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ យោ ច មរណកាលេ អញ្ញំ អារាធេតិ យោ ច បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ យោ ច បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ យោ ច បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ អយំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ ។ យោ ច ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ



បើមិនសម្រេចអរហត្តក្នុងកាលជិតស្លាប់ទេ បើមិនបានជាអន្តរាបរិនិព្វាយី ព្រោះការអស់សំយោជនៈខាងក្រោម ៥ ទេ បើមិនបានជាឧបហច្ចបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ គង់បានជាអសង្ខារបរិនិព្វាយី(១) ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ បើមិនបានសម្រេចអរហត្តក្នុងបច្ចុប្បន្នមុនស្លាប់ទេ បើមិនបានសម្រេចអរហត្តក្នុងកាលជិតស្លាប់ទេ បើមិនបានជាអន្តរាបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ បើមិនបានជាឧបហច្ចបរិនិព្វាយី ព្រោះការអស់សំយោជនៈខាងក្រោម ៥ ទេ បើមិនបានជាអសង្ខារបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ គង់បានជាសសង្ខារបរិនិព្វាយី(២) ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ បើមិនសម្រេចអរហត្តក្នុងបច្ចុប្បន្នមុនស្លាប់ទេ

---

១ ព្រះអនាគាមិដែលបានសម្រេចអរហត្តដោយមិនបាច់ប្រឹងប្រែងប្រកបព្យាយាម ហៅថា អសង្ខារបរិនិព្វាយី ។ ២ ព្រះអនាគាមិក្នុងជាន់សុទ្ធាវាស បានសម្រេចអរហត្តបរិនិព្វានដោយការប្រឹងព្យាយាម ហៅថា សសង្ខារបរិនិព្វាយី ។

នោ ចេ មរណកាលេ អញ្ញំ អារាធេតិ នោ ចេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ នោ ចេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ នោ ចេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ នោ ចេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ អថ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ ឯវំ ភាវិតេសុ ខោ ភិក្ខវេ សត្តសុ ពោជ្ឈង្គេសុ ឯវំ ពហុលីកតេសុ ឥមេ សត្ត ផលា សត្តានិសំសា បាដិកង្ខា ។

(៣៨៣) ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច សត្តិមេ អាវុសោ ពោជ្ឈង្គា ។ កតមេ សត្ត ។



បើមិនសម្រេចអរហត្តក្នុងកាលជិតស្លាប់ទេ បើមិនបានជាអន្តរាបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ បើមិនបានជាឧបហច្ចបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ បើមិនបានជាអសង្ខារបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ បើមិនបានជាសសង្ខារបរិនិព្វាយី ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ទេ គង់នឹងបានជាឧទ្ធំសោតអកនិដ្ឋគាមី[១] ព្រោះការអស់សំយោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពោជ្ឈង្គទាំង ៧ ដែលភិក្ខុបានចំរើនយ៉ាងនេះ ធ្វើឲ្យច្រើនៗ យ៉ាងនេះហើយ ផល ៧ អានិសង្ស ៧ នេះ គង់កើតប្រាកដ ។

(៣៨៣) សម័យមួយ ព្រះសារីបុត្តដ៏មានអាយុគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុបានហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ ដូច្នេះ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពោជ្ឈង្គនេះមាន ៧ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។

---

១ ព្រះអនាគាមីដែលមិនបានសម្រេចអរហត្តក្នុងភពដែលកើតទេ ក៏ត្រូវទៅកើតក្នុងភពអកនិដ្ឋ បរិនិព្វានក្នុងភពនោះ ហៅថា ឧទ្ធំសោតអកនិដ្ឋគាមី ។

សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ។

(៣៨៦) ឥមេសំ ខោ ភិក្ខវេ សត្តន្នំ ពោជ្ឈង្គានំ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ បុព្វណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន បុព្វណ្ហសមយំ វិហរាមិ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ មជ្ឈន្តិកសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន មជ្ឈន្តិកសមយំ វិហរាមិ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ សាយណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន សាយណ្ហសមយំ វិហរាមិ ។

(៣៨៧) សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ ភិក្ខវេ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ[១] តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។បេ។

១ ឱ. ម. តិដ្ឋន្តំ ចំ ។



គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងពោជ្ឈង្គទាំង ៧ ។

(៣៨៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពោជ្ឈង្គទាំង ៧ ប្រការនេះឯង បើខ្ញុំប្រាថ្នានឹងនៅដោយពោជ្ឈង្គណាៗ ក្នុងបុព្វណ្ហសម័យ ខ្ញុំក៏សម្រេចឥរិយាបថដោយពោជ្ឈង្គនោះៗ ក្នុងបុព្វណ្ហសម័យបាន ប្រាថ្នានឹងនៅដោយពោជ្ឈង្គណាៗ ក្នុងមជ្ឈន្តិកសម័យ ខ្ញុំក៏សម្រេចឥរិយាបថដោយពោជ្ឈង្គនោះៗ ក្នុងមជ្ឈន្តិកសម័យបាន ប្រាថ្នានឹងនៅដោយពោជ្ឈង្គណាៗ ក្នុងសាយណ្ហសម័យ ខ្ញុំក៏សម្រេចឥរិយាបថដោយពោជ្ឈង្គនោះៗ ក្នុងសាយណ្ហសម័យបាន ។

(៣៨៧) ម្នាលភិក្ខុទាំងឡាយ បើសតិសម្ពោជ្ឈង្គកើតមានដល់ខ្ញុំដូច្នេះ សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា សតិសម្ពោជ្ឈង្គរកប្រមាណមិនបាន សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា សតិសម្ពោជ្ឈង្គបរិបូណ៌ល្អហើយ កាលបើសតិសម្ពោជ្ឈង្គតាំងនៅ ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គតាំងនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ព្រោះហេតុនេះជាបច្ច័យ ។បេ។

(៣៨៦) ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។

(៣៨៧) សេយ្យថាបិ អាវុសោ រញ្ញោ វា រាជមហាមត្តស្ស វា នានារត្តានំ ទុស្សានំ ទុស្សករណ្ឌកោ បូរោ អស្ស សោ យំ យទេវ ទុស្សយុគំ អាកង្ខេយ្យ បុព្វណ្ហសមយំ បារុបិតុំ តទេវ ទុស្សយុគំ បុព្វណ្ហសមយំ បារុបេយ្យ យំ យទេវ ទុស្សយុគំ អាកង្ខេយ្យ មជ្ឈន្ហិកសមយំ បារុបិតុំ តទេវ ទុស្សយុគំ មជ្ឈន្ហិកសមយំ បារុបេយ្យ យំ យទេវ ទុស្សយុគំ អាកង្ខេយ្យ សាយណ្ហសមយំ បារុបិតុំ តទេវ ទុស្សយុគំ សាយណ្ហសមយំ បារុបេយ្យ ។ ឯវមេវ ខោ អហំ អាវុសោ ឥមេសំ សត្តន្នំ ពោជ្ឈង្គានំ



(៣៨៦) ម្នាលអាវុសោទាំងឡាយ បើឧបេក្ខាសម្ពោជ្ឈង្គកើតដល់ខ្ញុំដូច្នេះ សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា ឧបេក្ខាសម្ពោជ្ឈង្គមានប្រមាណមិនបាន សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា ឧបេក្ខាសម្ពោជ្ឈង្គបរិបូណ៌ល្អហើយ កាលបើឧបេក្ខាសម្ពោជ្ឈង្គតាំងនៅ ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គតាំងនៅ បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ព្រោះហេតុនេះជាបច្ច័យ ។

(៣៨៧) ម្នាលអាវុសោទាំងឡាយ ដូចទូដាក់សំពត់ ពេញដោយសំពត់ដែលជ្រលក់ដោយពណ៌ផ្សេងៗ របស់ព្រះរាជាក្តី របស់រាជមហាមាត្យក្តី ព្រះរាជាឬមហាមាត្យនោះប្រាថ្នានឹងស្លៀកដណ្តប់គូសំពត់ណាៗ ក្នុងបុព្វណ្ហសម័យ ក៏យកគូសំពត់នោះៗឯង ស្លៀកក្នុងបុព្វណ្ហសម័យបាន បើប្រាថ្នានឹងស្លៀកដណ្តប់គូសំពត់ណាៗ ក្នុងមជ្ឈន្តិកសម័យ ក៏យកគូសំពត់នោះៗឯង ស្លៀកដណ្តប់ក្នុងមជ្ឈន្តិកសម័យបាន បើប្រាថ្នានឹងស្លៀកដណ្តប់គូសំពត់ណាៗ ក្នុងសាយណ្ហសម័យ ក៏យកគូសំពត់នោះៗឯង ស្លៀកដណ្តប់ក្នុងសាយណ្ហសម័យបាន យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ បណ្តាពោជ្ឈង្គទាំង ៧ នេះឯង ខ្ញុំ

យេន យេន ពោជ្ឈង្គេន អាកង្ខាមិ បុព្វណ្ហសមយំ
វិហរិតុំ តេន តេន ពោជ្ឈង្គេន បុព្វណ្ហសមយំ វិហរាមិ
យេន យេន ពោជ្ឈង្គេន អាកង្ខាមិ មជ្ឈន្តិកសមយំ
វិហរិតុំ តេន តេន ពោជ្ឈង្គេន មជ្ឈន្តិកសមយំ
វិហរាមិ យេន យេន ពោជ្ឈង្គេន អាកង្ខាមិ សា-
យណ្ហសមយំ វិហរិតុំ តេន តេន ពោជ្ឈង្គេន សា-
យណ្ហសមយំ វិហរាមិ ។

(៣៨៨) សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ
ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ
ហោតិ តិដ្ឋន្តំ តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ
ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។បេ។



ប្រាថ្នានឹងនៅដោយពោជ្ឈង្គណាៗ ក្នុងបុព្វណ្ហសម័យ ខ្ញុំក៏សម្រេច
អរិយាបថដោយពោជ្ឈង្គនោះៗ ក្នុងបុព្វណ្ហសម័យបាន ខ្ញុំប្រាថ្នានឹងនៅ
ដោយពោជ្ឈង្គណាៗ ក្នុងមជ្ឈន្តិកសម័យ ខ្ញុំក៏សម្រេចអរិយាបថដោយ
ពោជ្ឈង្គនោះៗ ក្នុងមជ្ឈន្តិកសម័យបាន ខ្ញុំប្រាថ្នានឹងនៅដោយពោជ្ឈង្គ
ណាៗ ក្នុងសាយណ្ហសម័យ ខ្ញុំក៏សម្រេចអរិយាបថដោយពោជ្ឈង្គនោះៗ
ក្នុងសាយណ្ហសម័យបាន ក៏យ៉ាងនោះដែរ ។

(៣៨៨) ម្នាលអាវុសោទាំងឡាយ បើសតិសម្ពោជ្ឈង្គកើតមាន
ដល់ខ្ញុំដូច្នេះ សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា សតិសម្ពោជ្ឈង្គមាន
ប្រមាណមិនបាន សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា សតិសម្ពោជ្ឈង្គ
បរិបូណ៌ល្អ កាលបើសតិសម្ពោជ្ឈង្គតាំងនៅ ខ្ញុំក៏ដឹងច្បាស់ថា សតិ-
សម្ពោជ្ឈង្គតាំងនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ខ្ញុំក៏ដឹងច្បាស់ថា
សតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ព្រោះហេតុនេះជាបច្ច័យ ។បេ។

[៣៨៩] ឧបេក្ខាសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតិ អប្បមាណោតិ មេ ហោតិ សុសមារទ្ធោតិ មេ ហោតិ តិដ្ឋន្តំ តិដ្ឋតីតិ បជានាមិ សចេបិ មេ ចវតិ ឥទប្បច្ចយា មេ ចវតីតិ បជានាមិ ។

[៣៩០] (១)អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។បេ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ពោជ្ឈង្គា ពោជ្ឈង្គាតិ ភន្តេ វុច្ចន្តិ កិត្តាវតា នុ ខោ ភន្តេ ពោជ្ឈង្គាតិ វុច្ចន្តីតិ ។ ពោធាយ សំវត្តន្តីតិ ខោ ភិក្ខុ តស្មា ពោជ្ឈង្គាតិ វុច្ចន្តិ ។

[៣៩១] ឥធ ភិក្ខុ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។

១ ម. សាវត្ថី ។





[៣៨៩] ម្នាលអាវុសោទាំងឡាយ បើឧបេក្ខាសម្ពោជ្ឈង្គកើតមានដល់ខ្ញុំដូច្នេះ សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា ឧបេក្ខាសម្ពោជ្ឈង្គ មានប្រមាណមិនបាន សេចក្តីត្រិះរិះតែងកើតមានដល់ខ្ញុំថា ឧបេក្ខាសម្ពោជ្ឈង្គដែលខ្ញុំប្រារព្ធល្អ កាលបើឧបេក្ខាសម្ពោជ្ឈង្គតាំងនៅ ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គតាំងនៅ បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាតទៅ ព្រោះហេតុនេះជាបច្ច័យ ។

[៣៩០] គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យគេតែងនិយាយថា ពោជ្ឈង្គ ពោជ្ឈង្គ ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន គេតែងនិយាយថា ពោជ្ឈង្គដូច្នេះ តើដោយហេតុប៉ុន្មាន ។ ម្នាលភិក្ខុ ពួកធម៌ណាប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ហេតុនោះបានជាហៅថា ពោជ្ឈង្គដូច្នេះ ។

[៣៩១] ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ បង្អោនទៅក្នុងការលះបង់ ។បេ។

(៣៩២) ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។

(៣៩៣) តស្សិមេ សត្ត ពោជ្ឈង្គេ ភាវយតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ពោធាយ សំវត្តន្តីតិ ភិក្ខុ តស្មា ពោជ្ឈង្គាតិ វុច្ចន្តីតិ ។

(៣៩៤) ឯកំ សមយំ ភគវា សាកេតេ វិហរតិ អញ្ជនវនេ មិគទាយេ ។ អថខោ កុណ្ឌលិយោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។



(៣៩២) ភិក្ខុចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ដែលទន់ទោរទៅក្នុងការលះបង់ ។

(៣៩៣) កាលបើភិក្ខុនោះចំរើនពោជ្ឈង្គទាំង ៧ នេះ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ ភិក្ខុនោះក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចារ្យបានប្រព្រឹត្តស្រេចហើយ សោឡសកិច្ចបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុ ពួកធម៌ណាប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ហេតុនោះបានជាហៅថា ពោជ្ឈង្គ ។

(៣៩៤) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃអញ្ជនវ័ន ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងសាកេត ។ គ្រានោះឯង បរិព្វាជកឈ្មោះកុណ្ឌលិយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

ឯកមន្តំ និសិន្នោ ខោ កុណ្ឌលិយោ បរិព្វាជកោ ភគវន្តំ ឯតទវោច អហមស្មិ ភោ គោតម អារាម-និស្សយី បរិសាវចរោ(១) តស្ស មយ្ហំ ភោ គោតម បច្ឆាភត្តំ ភុត្តបាតរាសស្ស អយមាចារោ(២) ហោតិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ អនុចង្កមាមិ អនុវិចរាមិ សោ តត្ថ បស្សាមិ ឯកេ សមណព្រាហ្ម-ណេ ឥតិ វាទប្បមោក្ខានិសំសំ ចេវ កថំ កថេន្តេ ឧបារម្ភានិសំសំ ច កថំ ភវំ គោតមោ កិមានិសំសោ វិហរតីតិ ។ វិជ្ជាវិមុត្តិផលានិសំសោ ខោ កុណ្ឌលិយ តថាគតោ វិហរតីតិ ។

១ ម. អារាមនិស្សយី បរិសាវចរោ ។ ម. អារាមនិស្សយី បរិសាវចរោ ។ ២ ឱ. អយមា-ចារោ ។



កុណ្ឌលិយបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គជាអ្នកចេញចូលក្នុងសួនច្បារ ជាអ្នកចរទៅក្នុងបរិស័ទ បពិត្រព្រះគោតមដ៏ចំរើន ការទៅសួនច្បារនេះជាអាចាររបស់ខ្ញុំដែលបរិភោគបាយព្រឹកក្នុងកាលជាខាងក្រោយភត្តរួចហើយ ខ្ញុំព្រះអង្គតែងចង្ក្រមនឹងត្រាច់ទៅអំពីសួនច្បារមួយ ទៅកាន់សួនច្បារមួយ អំពីឧទ្យានមួយ ទៅកាន់ឧទ្យានមួយ ខ្ញុំព្រះអង្គតែងឃើញសមណព្រាហ្មណ៍មួយពួកក្នុងអារាមនិងឧទ្យាននោះ ថ្លែងនូវកថាមានអានិសង្សនៃការដោះគ្រោះរួចផង នូវកថាមានអានិសង្សនៃការប្រណាំងប្រជែងផង ដូច្នេះ ចំណែកខាងព្រះគោតមដ៏ចំរើន តើមានអ្វីជាអានិសង្សហ្ន៎ ។ ម្នាលកុណ្ឌលិយ ព្រះតថាគតមានវិជ្ជានិងវិមុត្តិជាផលានិសង្ស ។

[៣៩៨] កតមេ ច ភោ គោតម ធម្មា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តិ ។ សត្ត ខោ កុណ្ឌលិយ ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តិ ។ កតមេ ច ភោ គោតម ធម្មា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ ចត្តារោ ខោ កុណ្ឌលិយ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ កតមេ ច ភោ គោតម ធម្មា ភាវិតា ពហុលីកតា ចត្តារោ សតិ-បដ្ឋានេ បរិបូរេន្តិ ។ តីណិ ខោ កុណ្ឌលិយ សុចរិតានិ ភាវិតានិ ពហុលីកតានិ ចត្តារោ សតិ-បដ្ឋានេ បរិបូរេន្តិ ។ កតមេ ច ភោ គោតម ធម្មា ភាវិតា ពហុលីកតា តីណិ សុចរិតានិ បរិបូរេន្តិ ។



[៣៩៨] បពិត្រព្រះគោតមដ៏ចំរើន ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ញុំាងវិជ្ជានិងវិមុត្តិឲ្យពេញលេញបាន តើដូចម្តេចខ្លះ ។ ម្នាលកុណ្ឌលិយ ពោជ្ឈង្គទាំង ៧ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញលេញបាន ។ បពិត្រព្រះគោតមដ៏ចំរើន ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញលេញបាន តើដូចម្តេចខ្លះ ។ ម្នាលកុណ្ឌលិយ សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញលេញបាន ។ បពិត្រព្រះគោតមដ៏ចំរើន ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញលេញបាន តើដូចម្តេចខ្លះ ។ ម្នាលកុណ្ឌលិយ សុចរិតទាំង ៣ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញលេញបាន ។ បពិត្រព្រះគោតមដ៏ចំរើន ធម៌ទាំងឡាយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ញុំាងសុចរិតទាំង ៣ ឲ្យពេញលេញបាន តើដូចម្តេចខ្លះ ។

(៣៩៦) ឥន្ទ្រិយសំវរោ ខោ កុណ្ឌលិយ ភាវិតោ ពហុលីកតោ តីណិ សុចរិតានិ បរិបូរេតិ ។ កថំ ភាវិតោ កុណ្ឌលិយ ឥន្ទ្រិយសំវរោ កថំ ពហុលីកតោ តីណិ សុចរិតានិ បរិបូរេតិ ។ ឥធ កុណ្ឌលិយ ភិក្ខុ ចក្ខុនា រូបំ ទិស្វា មនាបំ នាភិជ្ឈាយតិ(១) នាភិហំសតិ(២) ន រាគំ ជនេតិ តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ចក្ខុនា ខោ បនេវ រូបំ ទិស្វា អមនាបំ ន មង្កុ ហោតិ អប្បតិដ្ឋិតចិត្តោ អាទិន្នមានសោ អព្យាបន្នចេតសោ តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ បុន ចបរំ កុណ្ឌលិយ ភិក្ខុ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ មនាបំ នាភិជ្ឈាយតិ នាភិហំសតិ ន រាគំ ជនេតិ តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ

---

១ ឱ. ម. នាភិជ្ឈតិ ។ ២ នាភិសតិ ។





(៣៩៦) ម្នាលកុណ្ឌលិយ ឥន្ទ្រិយសំវរៈដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើន ៗ ហើយ រមែងញ៉ាំងសុចរិតទាំង ៣ ឲ្យពេញលេញបាន ។ ម្នាលកុណ្ឌលិយ ឥន្ទ្រិយសំវរៈដែលបុគ្គលចំរើនហើយដូចម្តេច ធ្វើឲ្យច្រើន ៗ ហើយដូចម្តេច ទើបញ៉ាំងសុចរិតទាំង ៣ ឲ្យពេញលេញបាន ។ ម្នាលកុណ្ឌលិយ ភិក្ខុក្នុងសាសនានេះ ឃើញរូបជាទីគាប់ចិត្តដោយចក្ខុហើយ មិនសំឡឹងរំពៃ មិនរីករាយ មិនញ៉ាំងតម្រេកឲ្យកើត តាមកាយរបស់ភិក្ខុនោះដំកល់នៅបាន ចិត្តក៏តាំងនៅខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ភិក្ខុឃើញរូបដែលមិនគាប់ចិត្តដោយភ្នែកហើយ ជាអ្នកមិនមានមុខស្រពន់ មានចិត្តមិនតាំងខ្ជាប់ (ដោយអំណាចនៃកិលេស) មានចិត្តមិនរួញ មានចិត្តមិនព្យាបាទ តាមកាយរបស់ភិក្ខុនោះដំកល់នៅហើយ ចិត្តក៏តាំងនៅខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ម្នាលកុណ្ឌលិយ មួយទៀត ភិក្ខុស្តាប់សំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជក់រសដោយអណ្តាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់នូវធម្មារម្មណ៍ជាទីគាប់ចិត្តដោយមនោហើយ មិនសំឡឹងរំពៃ មិនរីករាយ មិនញ៉ាំងសេចក្តីត្រេកត្រអាលឲ្យកើត តាមកាយរបស់ភិក្ខុនោះតាំងនៅបាន ចិត្តក៏តាំងនៅ

អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ មនសា ខោ បនេវ ធម្មំ វិញ្ញាយ អមនាបំ ន មង្កុ ហោតិ អប្បតិដ្ឋិត- ចិត្តោ អទីនមានសោ អព្យាបន្នចេតសោ តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ យតោ ខោ កុណ្ឌលិយ ភិក្ខុ ចក្ខុនា រូបំ ទិស្វា មនាបាមនាបេសុ រូបេសុ ឋិតោ អទីនមាន- សោ អព្យាបន្នចេតសោ តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃា- យិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ មនាបាមនាបេសុ ធម្មេសុ ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ឯវំភាវិតោ ខោ កុណ្ឌលិយ ឥន្ទ្រិយសំវរោ ឯវំ ពហុលីកតោ តីណិ សុចរិតានិ បរិបូរេតិ ។





ខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ការដឹងច្បាស់នូវធម្មារម្មណ៍មិនជាទីគាប់ចិត្តដោយមនោហើយ មិនមានមុខស្រពាប់ មានចិត្តមិនតាំងនៅស៊ប់ មានចិត្តនឹងធួន មានចិត្តមិនព្យាបាទ នោះកាយរបស់ភិក្ខុនោះតាំងនៅហើយ ចិត្តក៏តាំងនៅខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ម្នាលកុណ្ឌលិយ កាលណាភិក្ខុឃើញរូបដោយភ្នែកហើយ តាំងនៅក្នុងរូបជាទីគាប់ចិត្តនិងមិនគាប់ចិត្ត មានចិត្តនឹងធួន មានចិត្តមិនព្យាបាទ នាមកាយរបស់ភិក្ខុនោះតាំងនៅហើយ ចិត្តក៏តាំងនៅខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយមនោ កាយរបស់ភិក្ខុនោះតាំងនៅក្នុងធម៌ទាំងឡាយជាទីគាប់ចិត្តនិងមិនគាប់ចិត្តហើយ ចិត្តក៏តាំងនៅខាងក្នុង តាំងនៅដោយល្អ ផុតស្រឡះដោយល្អ ។ ម្នាលកុណ្ឌលិយ ឥន្ទ្រិយសំវរៈដែលភិក្ខុចំរើនយ៉ាងនេះហើយ ធ្វើឲ្យច្រើនយ៉ាងនេះហើយ រមែងញុំាងសុចរិតទាំង ៣ ឲ្យពេញលេញបាន ។

[៣៩៧] កថំ ភាវិតានិ ច កុណ្ឌលិយ តីណិ សុចរិតានិ កថំ ពហុលីកតានិ ចត្តារោ សតិបដ្ឋានេ បរិបូរេន្តិ ។ ឥធ កុណ្ឌលិយ ភិក្ខុ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ ។ ឯវំ ភាវិតានិ ខោ កុណ្ឌលិយ តីណិ សុចរិតានិ ឯវំ ពហុលីកតានិ ចត្តារោ សតិបដ្ឋានេ បរិបូរេន្តិ ។

[៣៩៨] កថំ ភាវិតា ច កុណ្ឌលិយ ចត្តារោ សតិបដ្ឋានា កថំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ ឥធ កុណ្ឌលិយ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ ។បេ។ ចិត្តេ ។បេ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។



[៣៩៧] ម្នាលកុណ្ឌលិយ សុចរិតទាំង ៣ ដែលភិក្ខុចំរើនហើយដូចម្តេច ធ្វើឲ្យរឿយៗ ហើយដូចម្តេច ទើបញ៉ាំងសតិប្បដ្ឋានទាំង ៤ ឲ្យពេញលេញបាន ។ ម្នាលកុណ្ឌលិយ ភិក្ខុក្នុងសាសនានេះ លះបង់នូវកាយទុច្ចរិត ចំរើននូវកាយសុចរិត លះបង់នូវវចីទុច្ចរិត ចំរើននូវវចីសុចរិត លះបង់នូវមនោទុច្ចរិត ចំរើននូវមនោសុចរិត ។ ម្នាលកុណ្ឌលិយ សុចរិតទាំង ៣ ដែលភិក្ខុចំរើនយ៉ាងនេះហើយ ធ្វើឲ្យរឿយៗ យ៉ាងនេះហើយ រមែងញ៉ាំងសតិប្បដ្ឋានទាំង ៤ ឲ្យពេញលេញបាន ។

[៣៩៨] ម្នាលកុណ្ឌលិយ សតិប្បដ្ឋានទាំង ៤ ដែលភិក្ខុចំរើនហើយដូចម្តេច ធ្វើឲ្យរឿយៗ ហើយដូចម្តេច ទើបញ៉ាំងពោជ្ឈង្គទាំង ៧ ឲ្យពេញលេញបាន ។ ម្នាលកុណ្ឌលិយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ក្នុងវេទនាទាំងឡាយ ។បេ។ ក្នុងចិត្ត ។បេ។ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ឯវំ ភាវិតា ខោ កុណ្ឌលិយ ចត្តារោ សតិប្បដ្ឋានា ឯវំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។

[៣៩៩] កថំ ភាវិតា ច កុណ្ឌលិយ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តិ ។ ឥធ កុណ្ឌលិយ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមិំ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមិំ ។ ឯវំ ភាវិតា ខោ កុណ្ឌលិយ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តីតិ ។



ម្នាលកុណ្ឌលិយ សតិប្បដ្ឋានទាំង ៤ ដែលភិក្ខុចំរើនយ៉ាងនេះហើយ ធ្វើឲ្យច្រើនៗ យ៉ាងនេះហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញលេញបាន ។

[៣៩៩] ម្នាលកុណ្ឌលិយ ពោជ្ឈង្គទាំង ៧ ដែលភិក្ខុចំរើនហើយ ដូចម្តេច ធ្វើឲ្យច្រើនៗ ហើយដូចម្តេច ទើបញុំាងវិជ្ជានិងវិមុត្តិឲ្យពេញលេញបាន ។ ម្នាលកុណ្ឌលិយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ដែលបង្អោនទៅក្នុងការលះបង់ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ដែលបង្អោនទៅក្នុងការលះបង់ ។ ម្នាលកុណ្ឌលិយ ពោជ្ឈង្គទាំង ៧ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនៗ ហើយយ៉ាងនេះឯង រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញលេញបាន ។

[៦០០] ឯវំ វុត្តេ កុណ្ឌលិយោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។



[៦០០] កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ កុណ្ឌលិយបរិព្វាជកក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន (ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ) ដូចជាគេផ្ងារនូវវត្ថុដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះសោតដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹតដោយគិតថា មនុស្សដែលមានចក្ខុនឹងមើលឃើញរូបទាំងឡាយ ។ ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់ប្រកាសហើយដោយអនេកបរិយាយក៏ដូច្នោះដែរ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ តាំងអំពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចំរើនចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ។

(៤០១) សេយ្យថាបិ ភិក្ខវេ កូដាគារស្ស យា កាចិ គោបានសិយោ សព្វា តា កូដនិន្នា កូដបោណា កូដបព្ភារា ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។

(៤០២) កថញ្ច ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។





(៤០១) ម្នាលភិក្ខុទាំងឡាយ ដូចជាបង្កង់នៃផ្ទះមានកំពូលឯណាមួយ បង្កង់ទាំងអស់នោះបង្អោនទៅរកកំពូល ទេរទៅរកកំពូល ឈមទៅរកកំពូល យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ ជាបុគ្គលមានចិត្តបង្អោនទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

(៤០២) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ តែងមានចិត្តទន់ទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវសេចក្តីរលត់ ដែលទន់ទោរទៅក្នុងការលះបង់ ។ បេ ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវសេចក្តីរលត់ ដែលទន់ទោរទៅក្នុងការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ តែងមានចិត្តទន់ទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

(៦០៣) ឯកំ សមយំ អាយស្មា ច ឧបវាណោ អាយស្មា ច សារីបុត្តោ កោសម្ពិយំ វិហរន្តិ ឃោសិតារាមេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា ឧបវាណោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា ឧបវាណេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ឧបវាណំ ឯតទវោច ជានេយ្យ នុ ខោ អាវុសោ ឧបវាណ ភិក្ខុ បច្ចត្តំ យោនិសោមនសិការា ឯវំ សុសមារទ្ធា មេ សត្ត ពោជ្ឈង្គា ផាសុវិហារាយ សំវត្តន្តីតិ ។ ជានេយ្យ ខោ អាវុសោ សារីបុត្ត ភិក្ខុ បច្ចត្តំ យោនិសោមនសិការា ឯវំ សុសមារទ្ធា មេ សត្ត ពោជ្ឈង្គា ផាសុវិហារាយ សំវត្តន្តីតិ ។



(៦០៣) សម័យមួយ ព្រះឧបវាណមានអាយុនឹងព្រះសារីបុត្តមានអាយុគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅរកព្រះឧបវាណមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះឧបវាណមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះឧបវាណមានអាយុដូច្នេះថា ម្នាលអាវុសោឧបវាណ ភិក្ខុគប្បីដឹងដោយកិរិយាធ្វើទុកក្នុងចិត្តដោយឧបាយចំពោះខ្លួនថា សត្តពោជ្ឈង្គ៍ដែលអាត្មាញ៉ាំងព្រមផ្តើមល្អយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីនៅសប្បាយ ដូច្នេះដែរឬ ។ ម្នាលអាវុសោសារីបុត្ត ភិក្ខុគប្បីដឹងដោយកិរិយាធ្វើទុកក្នុងចិត្តដោយឧបាយចំពោះខ្លួនថា សត្តពោជ្ឈង្គ៍ដែលអាត្មាអញញ៉ាំងព្រមផ្តើមល្អយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីសប្បាយដូច្នេះបាន ។

(៤០៤) សតិសម្ពោជ្ឈង្គំ ខោ អាវុសោ ភិក្ខុ ភា-
វយមានោ, បជានាតិ ចិត្តញ្ច មេ សុវិមុត្តំ ថីនមិទ្ធញ្ច
មេ សុសមូហតំ ឧទ្ធច្ចកុក្កុច្ចញ្ច មេ សុប្បដិវិនីតំ
អារទ្ធញ្ច មេ វីរិយំ អដ្ឋិកត្វា មនសិករោមិ នោ ច
លីនត្តំ ។ បេ ។

(៤០៥) ឧបេក្ខាសម្ពោជ្ឈង្គំ អាវុសោ ភិក្ខុ ភា-
វយមានោ បជានាតិ ចិត្តញ្ច មេ សុវិមុត្តំ ថីនមិទ្ធញ្ច
មេ សុសមូហតំ ឧទ្ធច្ចកុក្កុច្ចញ្ច មេ សុប្បដិវិនីតំ
អារទ្ធញ្ច មេ វីរិយំ អដ្ឋិកត្វា មនសិករោមិ នោ ច
លីនត្តំ ។

(៤០៦) ឯវំ ខោ អាវុសោ សារីបុត្ត ភិក្ខុ ជានេយ្យ
បច្ចត្តំ យោនិសោមនសិការា ឯវំ សុសមារទ្ធា មេ
សត្ត ពោជ្ឈង្គា ផាសុវិហារាយ សំវត្តន្តីតិ ។



(៤០៤) ម្នាលអាវុសោ កាលភិក្ខុចំរើនសតិសម្ពោជ្ឈង្គ រមែង
ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញផុតល្អហើយ ថីនមិទ្ធអាត្មាអញក៏បាន
គាស់រំលើងល្អហើយ ឧទ្ធច្ចកុក្កុច្ចអាត្មាអញក៏បានបន្ទោបង់ល្អហើយ
ព្យាយាមអាត្មាអញក៏បានប្រារព្ធហើយ អាត្មាអញមានសេចក្ដីត្រូវការ
ទើបធ្វើទុកក្នុងចិត្ត ព្យាយាមមិនធូរថយឡើយ ។ បេ ។

(៤០៥) ម្នាលអាវុសោ កាលភិក្ខុចំរើនឧបេក្ខាសម្ពោជ្ឈង្គ រមែង
ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញផុតល្អហើយ ថីនមិទ្ធអាត្មាអញបាន
គាស់រំលើងហើយ ឧទ្ធច្ចកុក្កុច្ចអាត្មាអញក៏បានបន្ទោបង់ល្អហើយ
សេចក្ដីព្យាយាមអាត្មាអញក៏បានប្រារព្ធហើយ អាត្មាអញមានសេចក្ដី
ត្រូវការទើបធ្វើទុកក្នុងចិត្ត ព្យាយាមមិនធូរថយឡើយ ។

(៤០៦) ម្នាលអាវុសោសារីបុត្ត ភិក្ខុគប្បីដឹងដោយការធ្វើទុក
ក្នុងចិត្តដោយឧបាយចំពោះខ្លួនយ៉ាងនេះថា សត្តពោជ្ឈង្គអាត្មាអញធ្វើល្អ
យ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីនៅសប្បាយ ។

[៦០៧] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្ស ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

[៦០៨] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា អនុប្បន្នា ឧប្បជ្ជន្តិ នាញ្ញត្រ សុគតវិនយាតិ ។

បព្វតវគ្គោ បឋមោ ។



(៦០៧) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើងបាន តែក្រៅអំពីការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធចេញ កើតឡើងមិនបានទេ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើងបាន តែក្រៅអំពីការកើតឡើងនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធចេញ កើតឡើងមិនបានទេ ។

(៦០៨) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ មិនដែលកើតឡើង រមែងកើតឡើងបាន តែក្រៅអំពីវិន័យរបស់ព្រះសុគតចេញ កើតឡើងមិនបានទេ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ ដែលមិនទាន់កើតឡើង រមែងកើតឡើងបាន តែក្រៅអំពីវិន័យរបស់ព្រះសុគតចេញ កើតឡើងមិនបានទេ ។

ចប់ បព្វតវគ្គទី ១ ។

បព្វតវគ្គោ

## តស្សុទ្ទានំ

ហិមវន្តំ កាយសីលំ(១) ច
វត្ថំ ភិក្ខុ ច កុណ្ឌលិ
កូដំ ច ឧបវាណញ្ច
ឧប្បាទ(២) អបរេ ទុវេ ។

១ ឱ. ម. កាយំ សីលំ ។ ២ ឧប្បន្នា ។



បព្វតវគ្គ

## ឧទ្ទាននៃបព្វតវគ្គនោះគឺ

និយាយអំពីស្តេចភ្នំឈ្មោះហិមវន្ត ១ កាយ ១ សីល ១ វត្ថ របស់ព្រះសារីបុត្ត ១ ភិក្ខុសួរនូវពាក្យជាពោជ្ឈង្គ ១ បរិព្វាជកឈ្មោះកុណ្ឌលិយ ១ ផ្ទះមានកំពូល ១ ព្រះឧបវាណ ១ និងការកើតឡើងនៃសត្តពោជ្ឈង្គ ២ លើកដទៃទៀត ។

# គិលានវគ្គោ

(៤០៩) សេយ្យថាបិ ភិក្ខវេ យេ កេចិ បាណា ចត្តារោ ឥរិយាបថេ កប្បេន្តិ កាលេន គមនំ កាលេន ឋានំ កាលេន និសជ្ជំ កាលេន សេយ្យំ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ចត្តារោ ឥរិយាបថេ កប្បេន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។

(៤១០) កថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ

# គិលានវគ្គ

(៤០៩) ម្នាលភិក្ខុទាំងឡាយ ដូចសត្វទាំងឡាយណាមួយ សម្រេចឥរិយាបថទាំង ៤ គឺដើរតាមកាល ឈរតាមកាល អង្គុយតាមកាល ដេកតាមកាល សត្វទាំងអស់នោះ អាស្រ័យផែនដី តាំងស្ថិតលើផែនដី ទើបសម្រេចឥរិយាបថទាំង ៤ នោះយ៉ាងនេះឯង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងនៅក្នុងសីល ទើបចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ បាន ក៏យ៉ាងនោះដែរ ។

(៤១០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងនៅក្នុងសីល ទើបចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ បាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក

និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ ឧបេក្ខា-
សម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធ-
និស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ
និស្សាយ សីលេ បតិដ្ឋាយ សត្ត ពោជ្ឈង្គេ ភាវេតិ
សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។

(៦០១) សុរិយស្ស ភិក្ខវេ ឧទយតោ ឯតំ បុព្វង្គមំ
ឯតំ បុព្វនិមិត្តំ យទិទំ អរុណុគ្គំ ឯវមេវ ខោ ភិក្ខវេ
ភិក្ខុនោ សត្តន្នំ ពោជ្ឈង្គានំ ឧប្បាទាយ ឯតំ បុព្វង្គមំ
ឯតំ បុព្វនិមិត្តំ យទិទំ កល្យាណមិត្តតា ។ កល្យា-
ណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត
ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីក-
រិស្សតីតិ ។

(៦០២) កថញ្ច ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ
សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីក-
រោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ



អាស្រ័យសេចក្តីរលត់ ដែលបង្អោនទៅក្នុងការលះបង់ ។ បេ ។ ចំរើន
ឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តី
ប្រាសចាករាគៈ អាស្រ័យសេចក្តីរលត់ ដែលបង្អោនទៅក្នុងការលះ
បង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងនៅក្នុងសីល តែង
ចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន ៗ នូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

(៦០១) ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះឯង ជា
ប្រធាន ជាបុព្វនិមិត្ត នៃព្រះអាទិត្យដែលកើតឡើង (យ៉ាងណា) ការ
នៃកល្យាណមិត្តនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្ត នៃការញ៉ាំងពោជ្ឈង្គ
ទាំង ៧ ឲ្យកើតឡើងដល់ភិក្ខុ គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ
ហេតុនេះ ភិក្ខុដែលនឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន ៗ នូវពោ-
ជ្ឈង្គទាំង ៧ (នោះ) គួរប្រាថ្នានូវភិក្ខុដែលជាកល្យាណមិត្ត (កុំខាន) ។

(៦០២) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានកល្យាណមិត្ត រមែង
ចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន ៗ នូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។
ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ

វិវេកនិស្សិតំ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។

[៦១៣] សុរិយស្ស ភិក្ខវេ ឧទយតោ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ អរុណុគ្គំ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ សត្តន្នំ ពោជ្ឈង្គានំ ឧប្បាទាយ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ យោនិសោមនសិការោ ។ យោនិសោមនសិការសម្បន្នស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីករិស្សតីតិ ។



អាស្រ័យសេចក្តីស្ងប់ស្ងាត់ ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ដែលបង្អោនទៅក្នុងការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត តែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន ៗ នូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

[៦១៣] ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះ ជាប្រធាន ជាបុព្វនិមិត្ត នៃព្រះអាទិត្យដែលកើតឡើង (យ៉ាងណា) ម្នាលភិក្ខុទាំងឡាយ យោនិសោមនសិការ (ការធ្វើទុកក្នុងចិត្តដោយឧបាយ) នុ៎ះ ជាប្រធាន ជាបុព្វនិមិត្ត នៃការញ៉ាំងពោជ្ឈង្គទាំង ៧ ឲ្យកើតឡើងដល់ភិក្ខុ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ ភិក្ខុដែលនឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើន ៗ នូវពោជ្ឈង្គទាំង ៧ (នោះ) គួរប្រាថ្នានូវភិក្ខុដែលបរិបូណ៌ដោយយោនិសោមនសិការ (ក៏មាន) ។

[៦១៦] កថញ្ច ភិក្ខវេ ភិក្ខុ យោនិសោមនសិការសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យោនិសោមនសិការសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។

[៦១៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា មហាកស្សបោ បិប្ផលិគុហាយំ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។



[៦១៦] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ដោយយោនិសោមនសិការ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ ។បេ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្ដីរលត់ ដែលបង្អោនទៅក្នុងការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយយោនិសោមនសិការ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

[៦១៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបដ៏មានអាយុ គង់នៅក្នុងបិប្ផលិគុហា លោកមានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺជាទម្ងន់ ។

[៤០៦] អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ មហាកស្សបំ ឯតទវោច កច្ចិ តេ កស្សប ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន[១] យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[៤០៧] សត្តិមេ កស្សប ពោជ្ឈង្គា មយា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្ពានាយ សំវត្តន្តិ ។ កតមេ សត្ត ។

១ ម. ឆ. ន យាបនីយំ ។



[៤០៦] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ទ្រង់ចូលទៅរកព្រះមហាកស្សបដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលទុក ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះមហាកស្សបដ៏មានអាយុដូច្នេះថា ម្នាលកស្សប សរីរយន្តរបស់អ្នក ល្មមអត់ធន់បានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាធូរថយ មិនចំរើនឡើង មានតែស្រាកស្រាន្តទៅ មិនកើតឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចំរើន សរីរយន្តរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គក្លៀវក្លាខ្លាំងណាស់ មិនធូរថយទេ មានតែកើតឡើង មិនស្រាកស្រាន្តទេ ។

[៤០៧] ម្នាលកស្សប ពោជ្ឈង្គៈ ៧ នេះ ដែលតថាគតសំដែងប្រពៃហើយ បានចំរើនហើយ ធ្វើឲ្យច្រើនៗហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ពោជ្ឈង្គៈ ៧ តើអ្វីខ្លះ ។

## គិលានសូត្រ

[៤០៨] សតិសម្ពោជ្ឈង្គោ ខោ កស្សប មយា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ខោ កស្សប មយា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ ឥមេ ខោ កស្សប សត្ត ពោជ្ឈង្គា មយា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

[៤០៩] តគ្ឃ ភគវា[១] ពោជ្ឈង្គា តគ្ឃ សុគត ពោជ្ឈង្គាតិ ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា មហាកស្សបោ ភគវតោ ភាសិតំ អភិនន្ទិ ។ វុដ្ឋាហិ ចាយស្មា មហាកស្សបោ តម្ហា អាពាធា តថា បហីនោ ចាយស្មតោ មហាកស្សបស្ស សោ អាពាធោ អហោសីតិ ។

១ ម. ភគវា ។



## គិលានសូត្រ

[៤០៨] ម្នាលកស្សប សតិសម្ពោជ្ឈង្គដែលតថាគតបានសំដែងច្បាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យច្រើនៗហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។បេ។ ម្នាលកស្សប ឧបេក្ខាសម្ពោជ្ឈង្គដែលតថាគតសំដែងច្បាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យច្រើនៗហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលកស្សប ពោជ្ឈង្គទាំង ៧ នេះឯង ដែលតថាគតសំដែងច្បាស់ប្រពៃហើយ ចំរើនហើយ ធ្វើឲ្យច្រើនៗហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

[៤០៩] បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ ។ លុះព្រះដ៏មានព្រះភាគបានត្រាស់ធម៌នេះចប់ហើយ ។ ព្រះមហាកស្សបដ៏មានអាយុ ក៏ត្រេកអរចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ឯព្រះមហាកស្សបដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ មួយទៀត អាពាធនោះ ក៏ព្រះមហាកស្សបដ៏មានអាយុ បានលះបង់យ៉ាងនោះហើយ ។

(៦៦០) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ គិជ្ឈកូដេ បព្វតេ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។

(៦៦១) អថខោ ភគវា សាយណ្ហសមយំ បដិ-សល្លានា វុដ្ឋិតោ យេនាយស្មា មហាមោគ្គល្លានោ តេ-នុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ ឯត-ទវោច កច្ចិ តេ មោគ្គល្លាន ខមនីយំ កច្ចិ យាប-នីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្ក-មោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។



(៦៦០) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុគង់នៅជិតភ្នំគិជ្ឈកូដ មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺធ្ងន់ ។

(៦៦១) គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ទ្រង់ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏មានព្រះពុទ្ធដីកានឹងព្រះមហាមោគ្គ-ល្លានដ៏មានអាយុដូច្នេះថា ម្នាលមោគ្គល្លាន សរីរយន្តរបស់អ្នក ល្មមអត់ធន់បាននូវដែរឬ ល្មមឲ្យប្រព្រឹត្តទៅបាននូវដែរឬ ទុក្ខវេទនាធូរថយទៅ មិនចំរើនឡើង មានតែស្រាកស្រាន្តទៅ មិនកើនឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចំរើន សរីរយន្តរបស់ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងក្រៃណាស់ មិនធូរថយទេ មានតែកើនឡើង មិនស្រាកស្រាន្តទេ ។

## គិលានវគ្គោ

(៦៦៦) សត្តិមេ មោគ្គល្លាន ពោជ្ឈង្គា មយា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ សត្ត ។

(៦៦៧) សតិសម្ពោជ្ឈង្គោ ខោ មោគ្គល្លាន មយា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ខោ មោគ្គល្លាន មយា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ ឥមេ ខោ មោគ្គល្លាន សត្ត ពោជ្ឈង្គា មយា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។



## គិលានវគ្គ

(៦៦៦) នែមោគ្គល្លាន ពោជ្ឈង្គ ៧ នេះ ដែលតថាគត សំដែងប្រាប់ប្រាកដហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ពោជ្ឈង្គ ៧ តើដូចម្តេចខ្លះ ។

(៦៦៧) ម្នាលមោគ្គល្លាន សតិសម្ពោជ្ឈង្គ ដែលតថាគត សំដែងប្រាប់ប្រាកដហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ បេ ។ ម្នាលមោគ្គល្លាន ឧបេក្ខាសម្ពោជ្ឈង្គ ដែលតថាគតសំដែងប្រាប់ប្រាកដហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ម្នាលមោគ្គល្លាន ពោជ្ឈង្គ ៧ នេះឯង ដែលតថាគតសំដែងប្រាប់ប្រាកដហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

(៦៦៧) តគ្ឃ ភគវា ពោជ្ឈង្គា តគ្ឃ សុគត ពោជ្ឈង្គាតិ ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា មហាមោគ្គល្លានោ ភគវតោ ភាសិតំ អភិនន្ទិ ។ វុដ្ឋាហិ ចាយស្មា មហាមោគ្គល្លានោ តម្ហា អាពាធា តថា បហីនោ ចាយស្មតោ មហាមោគ្គល្លានស្ស សោ អាពាធោ អហោសីតិ ។

(៦៦៨) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភគវា អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។

(៦៦៩) អថខោ អាយស្មា មហាចុន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មហាចុន្ទំ ភគវា ឯតទវោច បដិភន្តុ តំ ចុន្ទ ពោជ្ឈង្គាតិ ។ សត្តិមេ ភន្តេ ពោជ្ឈង្គា ភគវតា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ សត្ត ។



(៦៦៧) បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ បពិត្រព្រះសុគត ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ធម៌នេះចប់ហើយ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ឯព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ អាពាធនោះ ក៏ព្រះមហាមោគ្គល្លានបានលះបង់យ៉ាងនោះហើយ ។

(៦៦៨) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជម្ងឺធ្ងន់ ។

(៦៦៩) គ្រានោះឯង ព្រះមហាចុន្ទដ៏មានអាយុបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាចុន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគបានត្រាស់សួរថា ម្នាលចុន្ទ ចូរអ្នកសំដែងពោជ្ឈង្គទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គទាំង ៧ នេះ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ហើយ ចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។

[៤៦៧] សតិសម្ពោជ្ឈង្គោ ខោ ភន្តេ ភគវតា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ខោ ភន្តេ ភគវតា សម្មទក្ខាតោ ភាវិតោ ពហុលីកតោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ ឥមេ ខោ ភន្តេ សត្ត ពោជ្ឈង្គា ភគវតា សម្មទក្ខាតា ភាវិតា ពហុលីកតា អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

[៤៦៨] តគ្ឃ ចុន្ទ ពោជ្ឈង្គា តគ្ឃ ចុន្ទ ពោជ្ឈង្គាតិ ។ ឥទមវោចាយស្មា មហាចុន្ទោ សមនុញ្ញោ សត្ថា អហោសិ ។ វុដ្ឋាហិ ច ភគវា តម្ហា អាពាធា តថា បហីនោ ច ភគវតោ សោ អាពាធោ អហោសីតិ ។



(៤៦៧) បពិត្រព្រះអង្គដ៏ចំរើន សតិសម្ពោជ្ឈង្គ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ឧបេក្ខាសម្ពោជ្ឈង្គ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គទាំង ៧ នេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ហើយ ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ តែងប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

(៤៦៨) ម្នាលចុន្ទ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ ម្នាលចុន្ទ ពិតមែនហើយ ពោជ្ឈង្គទាំងឡាយ ។ លុះព្រះមហាចុន្ទដ៏មានអាយុ សំដែងនូវធម៌នេះចប់ហើយ ព្រះសាស្តាក៏ទ្រង់ពេញព្រះហឫទ័យ ។ ព្រះដ៏មានព្រះភាគក៏ក្រោកជាសះស្បើយចាកអាពាធនោះ អាពាធនោះ ព្រះដ៏មានព្រះភាគក៏បានលះបង់យ៉ាងនោះហើយ ។

(៦២៩) សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា អបារា បារង្គមនាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា អបារា បារង្គមនាយ សំវត្តន្តីតិ ។

(៦៣០) អប្បកា តេ មនុស្សេសុ
យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា
តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ
ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ
មច្ចុធេយ្យំ សុទុត្តរំ ។
កណ្ហំ ធម្មំ វិប្បហាយ
សុក្កំ ភាវេថ បណ្ឌិតោ



(៦២៩) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីឲ្យឃ្លាតចាកទីមិនមែនជាត្រើយ ឲ្យដល់ទីជាត្រើយ ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីឲ្យឃ្លាតចាកទីមិនមែនជាត្រើយ ឲ្យដល់ទីជាត្រើយ ។

(៦៣០) បណ្តាមនុស្សទាំងឡាយ ជនទាំងឡាយឯណា ដល់នូវត្រើយគឺព្រះនិព្វាន ជនទាំងឡាយនោះ មានចំនួនតិច ឯសត្វក្រៅពីនេះសេសសៀរ តែងរត់តាមត្រើយគឺវដ្តៈ ។ ពួកជនណាប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតសំដែងប្រពៃហើយ ពួកជននោះនឹងឆ្លងនូវទីកន្លែងរបស់មច្ចុ ដែលជាទីឆ្លងបានដោយលំបាកពេក ហើយដល់នូវត្រើយគឺព្រះនិព្វាន ។ បណ្ឌិតលះបង់នូវធម៌ខ្មៅ ហើយចំរើនធម៌ស

## បណ្ឌិតវគ្គោ

ឱកា អនោកមាគម្ម
វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ
ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ
ចិត្តក្លេសេហិ បណ្ឌិតោ
យេសំ សម្ពោធិយង្គេសុ
សម្មា ចិត្តំ សុភាវិតំ
អាទានបដិនិស្សគ្គេ
អនុបាទាយ យេ រតា
ខីណាសវា ជុតិមន្តោ
តេ លោកេ បរិនិព្វុតា ។



## បណ្ឌិតវគ្គ

ចេញចាកអាល័យ អាស្រ័យព្រះនិព្វាន ដែលគ្មានសេចក្តីអាល័យហើយ លះបង់កាមទាំងឡាយ ជាអ្នកឥតមានកង្វល់ ប្រាថ្នាខ្លួនសេចក្តីត្រេកអរ ចំពោះវិវេកគឺសេចក្តីស្ងប់ស្ងាត់ ដែលសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតត្រូវធ្វើខ្លួនឲ្យផូរផង់អំពីពួកសេចក្តីសៅហ្មងនៃចិត្ត ពួកជនណាបានចំរើនចិត្តដោយប្រពៃ ក្នុងសម្ពោជ្ឈង្គទាំងឡាយហើយ មិនបានប្រកាន់មាំ ត្រេកអរក្នុងការលះសេចក្តីប្រកាន់ ពួកជននោះ ជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានហើយក្នុងលោក ។

(៤៣១) យេសំ កេសញ្ចិ ភិក្ខវេ សត្ត ពោជ្ឈង្គា វិរទ្ធា វិរទ្ធា តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី ។ យេសំ កេសញ្ចិ ភិក្ខវេ សត្ត ពោជ្ឈង្គា អារទ្ធា អារទ្ធា តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។

(៤៣២) យេសំ កេសញ្ចិ ភិក្ខវេ ឥមេ សត្ត ពោជ្ឈង្គា វិរទ្ធា វិរទ្ធា តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី ។ យេសំ កេសញ្ចិ ភិក្ខវេ ឥមេ សត្ត ពោជ្ឈង្គា អារទ្ធា អារទ្ធា តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមីតិ ។



(៤៣១) ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយ លះបង់ពោជ្ឈង្គទាំង ៧ ហើយ ពួកជននោះក៏ឈ្មោះថាលះបង់អរិយមគ្គ ដែលប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃផង ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាមួយបានប្រារព្ធពោជ្ឈង្គទាំង ៧ ហើយ អ្នកនោះក៏ឈ្មោះថាបានប្រារព្ធអរិយមគ្គ ដែលប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃផង ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

(៤៣២) ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយលះបង់ពោជ្ឈង្គទាំង ៧ នេះ ពួកជននោះក៏ឈ្មោះថាលះបង់អរិយមគ្គ ដែលប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ពួកជនណាមួយប្រារព្ធពោជ្ឈង្គទាំង ៧ នេះ ពួកជននោះក៏ឈ្មោះថាបានប្រារព្ធអរិយមគ្គ ដែលប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃផង ។

[៤៣៣] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មាទុក្ខក្ខយាយ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។

[៤៣៤] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

និរោធវគ្គោ ទុតិយោ ។



[៤៣៣] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ ជាធម៌ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខ ដល់អ្នកចំរើនពោជ្ឈង្គនោះ ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ ជានិយ្យានិកធម៌ដ៏ប្រសើរ រមែងប្រព្រឹត្តទៅដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដល់អ្នកចំរើនពោជ្ឈង្គនោះ ។

[៤៣៤] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ ដើម្បីចូលទៅរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនៗហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ ដើម្បីចូលទៅរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

ចប់ និរោធវគ្គទី ២ ។

## តស្សុទ្ទានំ

បាណា សុរិយុបមា ទ្វេ
កិលេសេ(១) អបរេ តយោ
បារគាមី វិរទ្ធា ច
អរិយា និព្ពាយ(២) ចាតិ ។

១ ម. ម. គិលានា ។ ២ និព្វិទាយ ។



## ឧទ្ទាននៃគិលានវគ្គនោះគឺ

និយាយអំពីក្លុកសត្វ ១ ឧបមាដូចព្រះអាទិត្យមាន ២ លើក ឯម្យ៉ាងមាន ៣ លើកផងទៀត បុគ្គលដល់ត្រើយ ១ សាបសូន្យ ១ មគ្គដ៏ប្រសើរ ១ ពោធិបក្ខប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ១ ។

## ឧទាយិវគ្គោ

[២៣៧] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ពោជ្ឈង្គា ពោជ្ឈង្គាតិ ភន្តេ វុច្ចន្តិ កិត្តាវតា នុ ខោ ភន្តេ ពោជ្ឈង្គាតិ វុច្ចន្តីតិ ។ សម្ពោធាយ សំវត្តន្តីតិ ខោ ភិក្ខុ តស្មា ពោជ្ឈង្គាតិ វុច្ចន្តិ ។

[២៣៨] ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សម្ពោធាយ សំវត្តន្តីតិ ខោ ភិក្ខុ តស្មា ពោជ្ឈង្គាតិ វុច្ចន្តិ ។

## ឧទាយិវគ្គ

(២៣៧) គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យគេតែងនិយាយថា ពោជ្ឈង្គ ពោជ្ឈង្គ ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថាពោជ្ឈង្គ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ធម៌ទាំងឡាយប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ព្រោះហេតុនោះ ទើបហៅថាពោជ្ឈង្គ ។

(២៣៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីនឿយណាយ អាស្រ័យសេចក្តីរលត់ បង្អោនទៅរកការលះបង់ ។បេ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីនឿយណាយ អាស្រ័យសេចក្តីរលត់ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុ ធម៌ទាំងឡាយប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ព្រោះហេតុនោះ ទើបហៅថាពោជ្ឈង្គ ។

[៥៣៧] សត្ត ឥមេ ភិក្ខវេ ពោជ្ឈង្គេ ទេសិស្សាមិ តំ សុណាថ ។ កតមេ ច ភិក្ខវេ សត្ត ពោជ្ឈង្គា ។ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គាតិ ។

[៥៣៨] កាមរាគដ្ឋានីយានំ ភិក្ខវេ ធម្មានំ ពហុលីការា អនុប្បន្នោ ចេវ កាមច្ឆន្ទោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

[៥៣៩] ព្យាបាទដ្ឋានីយានំ ភិក្ខវេ ធម្មានំ ពហុលីការា អនុប្បន្នោ ចេវ ព្យាបាទោ ឧប្បជ្ជតិ ឧប្បន្នោ ច ព្យាបាទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

[៥៤០] ថីនមិទ្ធដ្ឋានីយានំ ភិក្ខវេ ធម្មានំ ពហុលីការា អនុប្បន្នញ្ចេវ ថីនមិទ្ធំ ឧប្បជ្ជតិ ឧប្បន្នញ្ច ថីនមិទ្ធំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ



(៥៣៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវពោជ្ឈង្គទាំង ៧ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះពោជ្ឈង្គទាំង ៧ តើដូចម្ដេច ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គមាន ៧ នេះឯង ។

(៥៣៨) ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងកាមច្ឆន្ទៈដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីភាវៈដ៏ធំទូលាយជាភិយ្យោភាព ព្រោះធ្វើទុកក្នុងចិត្តនឹងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃកាមរាគ ។

(៥៣៩) ម្នាលភិក្ខុទាំងឡាយ ព្យាបាទដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងព្យាបាទដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីភាវៈដ៏ធំទូលាយជាភិយ្យោភាព ព្រោះធ្វើទុកក្នុងចិត្តនឹងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃព្យាបាទ ។

(៥៤០) ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងថីនមិទ្ធៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ធំទូលាយជាភិយ្យោភាព ព្រោះធ្វើទុកក្នុងចិត្តនឹងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃថីនមិទ្ធៈ ។

(៦៦១) ឧទ្ធច្ចកុក្កុច្ចដ្ឋានីយានំ ភិក្ខវេ ធម្មានំ អយោនិសោមនសិការពហុលីការា អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ ឧប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៦៦២) វិចិកិច្ឆាដ្ឋានីយានំ ភិក្ខវេ ធម្មានំ អយោនិសោមនសិការពហុលីការា អនុប្បន្នា ចេវ វិចិកិច្ឆា ឧប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៦៦៣) សតិសម្ពោជ្ឈង្គដ្ឋានីយានំ ភិក្ខវេ ធម្មានំ យោនិសោមនសិការពហុលីការា អនុប្បន្នោ ចេវ សតិសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច សតិសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គដ្ឋានីយានំ ភិក្ខវេ ធម្មានំ យោនិសោមនសិការពហុលីការា អនុប្បន្នោ ចេវ ឧបេក្ខាសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច ឧបេក្ខាសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។



(៦៦១) ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចដែលមិនទាន់កើតឡើង ក៏កើតឡើង និងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីការរីកធំទូលាយជាភិយ្យោភាព ព្រោះធ្វើទុកក្នុងចិត្តនិងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃឧទ្ធច្ចកុក្កុច្ច ។

(៦៦២) ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏កើតឡើង និងវិចិកិច្ឆាដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីការធំទូលាយជាភិយ្យោភាព ព្រោះធ្វើទុកក្នុងចិត្តនិងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា ។

(៦៦៣) ម្នាលភិក្ខុទាំងឡាយ សតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើង និងសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ព្រោះធ្វើទុកក្នុងចិត្តនិងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គ ។បេ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើង និងឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ព្រោះធ្វើទុកក្នុងចិត្តនិងធ្វើឲ្យច្រើននូវធម៌ទាំងឡាយដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

(៤៤៤) អយោនិសោ ភិក្ខវេ មនសិការោតោ អនុប្បន្នោ ចេវ កាមច្ឆន្ទោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អនុប្បន្នោ ចេវ ព្យាបាទោ ឧប្បជ្ជតិ ឧប្បន្នោ ច ព្យាបាទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អនុប្បន្នញ្ចេវ ថីនមិទ្ធំ ឧប្បជ្ជតិ ឧប្បន្នញ្ច ថីនមិទ្ធំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ ឧប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អនុប្បន្នា ចេវ វិចិកិច្ឆា ឧប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៤៤៥) អនុប្បន្នោ ចេវ សតិសម្ពោជ្ឈង្គោ នុប្បជ្ជតិ ឧប្បន្នោ ច សតិសម្ពោជ្ឈង្គោ និរុជ្ឈតិ ។ បេ ។ អនុប្បន្នោ ចេវ ឧបេក្ខាសម្ពោជ្ឈង្គោ នុប្បជ្ជតិ ឧប្បន្នោ ច ឧបេក្ខាសម្ពោជ្ឈង្គោ និរុជ្ឈតិ ។



(៤៤៤) ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយមិនមានឧបាយប្រាជ្ញា កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងកាមច្ឆន្ទៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ចំរើនទូលាយជាភិយ្យោភាព ។ ព្យាបាទដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងព្យាបាទដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ចំរើនទូលាយជាភិយ្យោភាព ។ ថីនមិទ្ធដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងថីនមិទ្ធដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ចំរើនទូលាយជាភិយ្យោភាព ។ ឧទ្ធច្ចកុក្កុច្ចដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងឧទ្ធច្ចកុក្កុច្ចដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ចំរើនទូលាយជាភិយ្យោភាព ។ វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងវិចិកិច្ឆាដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីភាវៈដ៏ចំរើនទូលាយជាភិយ្យោភាព ។

(៤៤៥) សតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏រលត់ទៅវិញ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏រលត់ទៅវិញ ។

[៤៤៦] យោនិសោ ច ខោ ភិក្ខវេ មនសិករោតោ អនុប្បន្នោ ចេវ កាមច្ឆន្ទោ នុប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ បហីយតិ ។ អនុប្បន្នោ ចេវ ព្យាបាទោ នុប្បជ្ជតិ ឧប្បន្នោ ច ព្យាបាទោ បហីយតិ ។ អនុប្បន្នញ្ចេវ ថីនមិទ្ធំ នុប្បជ្ជតិ ឧប្បន្នំ ច ថីនមិទ្ធំ បហីយតិ ។ អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ នុប្បជ្ជតិ ឧប្បន្នំ ច ឧទ្ធច្ចកុក្កុច្ចំ បហីយតិ ។ អនុប្បន្នា ចេវ វិចិកិច្ឆា នុប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា បហីយតិ ។

[៤៤៧] អនុប្បន្នោ ចេវ សតិសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច សតិសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។បេ។ អនុប្បន្នោ ចេវ ឧបេក្ខាសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច ឧបេក្ខាសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។





(៤៤៦) ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងកាមច្ឆន្ទៈដែលកើតឡើងហើយ ក៏លះចេញបាន ។ ព្យាបាទដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងព្យាបាទដែលកើតឡើងហើយ ក៏លះចេញបាន ។ ថីនមិទ្ធៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងថីនមិទ្ធៈដែលកើតឡើងហើយ ក៏លះចេញបាន ។ ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏លះចេញបាន ។ វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏មិនកើតឡើង ទាំងវិចិកិច្ឆាដែលកើតឡើងហើយ ក៏លះចេញបាន ។

(៤៤៧) សតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើង ទាំងឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ។

(៦៦៨) សត្ត ភេ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ ។ កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ។ យទិទំ សត្ត ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត អបរិហានិយា ធម្មាតិ ។

(៦៦៩) យោ ភិក្ខវេ មគ្គោ យា បដិបទា តណ្ហាក្ខយាយ សំវត្តតិ តំ មគ្គំ តំ បដិបទំ ភាវេថ ។ កតមោ ច ភិក្ខវេ មគ្គោ កតមា ច បដិបទា តណ្ហាក្ខយាយ សំវត្តតិ ។ យទិទំ សត្ត ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោតិ ។



(៦៦៨) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវអបរិហានិយធម៌ គឺធម៌ដែលមិនសាបសូន្យ ៧ ប្រការ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ទាំង ៧ ប្រការ តើដូចម្តេច ។ គឺពោជ្ឈង្គទាំង ៧ ប្រការនេះឯង ។ ចុះពោជ្ឈង្គទាំង ៧ តើដូចម្តេច ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌មាន ៧ ប្រការនេះឯង ។

(៦៦៩) ម្នាលភិក្ខុទាំងឡាយ មគ្គឯណា បដិបទាឯណា ប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា ចូរអ្នកទាំងឡាយចំរើនមគ្គនោះ បដិបទានោះចុះ ។ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា ។ គឺពោជ្ឈង្គទាំង ៧ ប្រការនេះឯង ។ ចុះពោជ្ឈង្គទាំង ៧ ប្រការ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

## ឧទាយិវគ្គោ

[៤៩០] ឯវំ វុត្តេ អាយស្មា ឧទាយី ភគវន្តំ ឯតទវោច កថំ ភាវិតា នុ ខោ ភន្តេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា តណ្ហក្ខយាយ សំវត្តន្តីតិ ។ ឥធ ឧទាយិ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វិបុលំ មហគ្គតំ អប្បមាណំ អព្យាបជ្ជំ តស្ស សតិសម្ពោជ្ឈង្គំ ភាវយតោ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ (១) វិបុលំ មហគ្គតំ អប្បមាណំ អព្យាបជ្ជំ តណ្ហា បហីយតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វិបុលំ មហគ្គតំ អប្បមាណំ អព្យាបជ្ជំ តស្ស ឧបេក្ខាសម្ពោជ្ឈង្គំ ភាវយតោ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វិបុលំ

១ ម. ឯត្ថន្តរេ វោស្សគ្គបរិណាមិន្តិ បាឋោ អត្ថិ ។



## ឧទាយិវគ្គ

(៤៩០) កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយីដ៏មានអាយុក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គទាំង ៧ ប្រការ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ ដ៏ប្រមាណមិនបាន មិនមានព្យាបាទ កាលភិក្ខុនោះចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ ដ៏ប្រមាណមិនបាន មិនមានព្យាបាទ ភិក្ខុនោះក៏លះបង់តណ្ហាបានដាច់ ។ បេ ។ ភិក្ខុចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ ដ៏ប្រមាណមិនបាន មិនមានព្យាបាទ កាលភិក្ខុនោះកំពុងចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ

មហគ្គតំ អប្បមាណំ អព្យាបជ្ឈំ តណ្ហា បហីយតិ តណ្ហាយ បហានា កម្មំ បហីយតិ កម្មស្ស បហានា ទុក្ខំ បហីយតិ ។ ឥតិ ខោ ឧទាយិ តណ្ហក្ខយា កម្មក្ខយោ កម្មក្ខយា ទុក្ខក្ខយោតិ ។

(៦៨៣) យោ ភិក្ខវេ មគ្គោ យា បដិបទា តណ្ហានិរោធាយ សំវត្តតិ តំ មគ្គំ តំ បដិបទំ ភាវេថ ។ កតមោ ច ភិក្ខវេ មគ្គោ កតមា ច បដិបទា តណ្ហានិរោធាយ សំវត្តតិ ។ យទិទំ សត្ត ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។



ដ៏ប្រមាណមិនបាន មិនមានព្យាបាទ ភិក្ខុនោះក៏លះបង់តណ្ហាចេញ ព្រោះការលះបង់តណ្ហាបាន ទើបលះបង់កម្មបាន ព្រោះការលះបង់កម្មបាន ទើបលះបង់សេចក្តីទុក្ខបាន ។ ម្នាលឧទាយិ ការអស់ទៅនៃកម្ម ព្រោះអស់ទៅនៃតណ្ហា ការអស់ទៅនៃសេចក្តីទុក្ខ ព្រោះអស់ទៅនៃកម្ម ដោយប្រការដូច្នេះឯង ។

(៦៨៣) ម្នាលភិក្ខុទាំងឡាយ មគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីសេចក្តីរលត់នៃតណ្ហា ចូរអ្នកទាំងឡាយចំរើនមគ្គនោះ បដិបទានោះ ។ ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីរលត់ទៅនៃតណ្ហា ។ គឺពោជ្ឈង្គទាំង៧ នេះឯង ។ ពោជ្ឈង្គទាំង៧ តើដូចម្តេច ។ គឺសតិសម្ពោជ្ឈង្គ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ១ ។

[៦៩៦] កថំ ភាវិតា ច ភិក្ខវេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា តណ្ហក្ខយាយ សំវត្តន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា តណ្ហក្ខយាយ សំវត្តន្តីតិ ។

[៦៩៧] និព្វេធភាគិយំ វោ ភិក្ខវេ មគ្គំ ទេសេស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ និព្វេធភាគិយោ មគ្គោ ។ យទិទំ សត្ត សម្ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោតិ ។



[៦៩៦] ម្នាលភិក្ខុទាំងឡាយ ចុះពោជ្ឈង្គទាំង ៧ ប្រការ ដែលភិក្ខុបានចំរើនដូចម្ដេច បានធ្វើឲ្យច្រើនដូចម្ដេច ទើបប្រព្រឹត្តទៅដើម្បីសេចក្ដីអស់ទៅនៃតណ្ហា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ដែលភិក្ខុបានចំរើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីអស់ទៅនៃតណ្ហា ។

[៦៩៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងមគ្គ ជាចំណែកនៃការចាក់ទម្លុះនូវ (កងកិលេស) ចូរអ្នកទាំងឡាយស្ដាប់មគ្គនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដែលជាចំណែកនៃការចាក់ទម្លុះនូវ (កងកិលេស) តើដូចម្ដេច ។ គឺពោជ្ឈង្គទាំង ៧ ប្រការនេះឯង ។ ពោជ្ឈង្គទាំង ៧ ប្រការតើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

(៤៨៤) ឯវំ វុត្តេ អាយស្មា ឧទាយិ ភគវន្តំ ឯតទវោច កថំ ភាវិតា នុ ខោ ភន្តេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា និព្ភិទាយ សំវត្តន្តិ ។ ឥធ ឧទាយិ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វិបុលំ មហគ្គតំ អប្បមាណំ អព្យាបជ្ឈំ សោ សតិសម្ពោជ្ឈង្គភាវិតេន ចិត្តេន អនិព្ភិន្នបុព្វំ អប្បទាលិតបុព្វំ លោភក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ អនិព្ភិន្នបុព្វំ អប្បទាលិតបុព្វំ ទោសក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ អនិព្ភិន្នបុព្វំ អប្បទាលិតបុព្វំ មោហក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វិបុលំ មហគ្គតំ អប្បមាណំ អព្យាបជ្ឈំ សោ ឧបេក្ខាសម្ពោជ្ឈង្គភាវិតេន ចិត្តេន អនិព្ភិន្នបុព្វំ អប្បទាលិតបុព្វំ លោភក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ



(៤៨៤) កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គទាំង ៧ ដែលភិក្ខុបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីការចាក់ធ្លុះខ្ទេច (កង-កិលេស) ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ ដ៏ប្រមាណមិនបាន មិនមានព្យាបាទ ភិក្ខុនោះមានចិត្តអប់រំដោយសតិសម្ពោជ្ឈង្គ រមែងចាក់ធ្លុះទំលាយនូវគំនរលោភ ដែលខ្លួនមិនទាន់ចាក់ធ្លុះ មិនទាន់ទំលាយទេ រមែងចាក់ធ្លុះទំលាយនូវគំនរទោសៈ ដែលខ្លួនមិនទាន់បានចាក់ធ្លុះ មិនទាន់បានទំលាយទេ រមែងចាក់ធ្លុះទំលាយនូវគំនរមោហៈ ដែលខ្លួនមិនទាន់បានចាក់ធ្លុះ មិនទាន់បានទំលាយទេ ។បេ។ ភិក្ខុចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ ដ៏ទូលាយ ដ៏ប្រមាណមិនបាន មិនមានព្យាបាទ ភិក្ខុនោះមានចិត្តអប់រំដោយឧបេក្ខាសម្ពោជ្ឈង្គ រមែងចាក់ធ្លុះទំលាយនូវគំនរលោភ ដែលខ្លួនមិនទាន់បានចាក់ធ្លុះ

អនិព្ពិទ្ធបុព្វំ អប្បទាលិតបុព្វំ ទោសក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ អនិព្ពិទ្ធបុព្វំ អប្បទាលិតបុព្វំ មោហក្ខន្ធំ និព្ពិជ្ឈតិ បទាលេតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ឯវំ ភាវិតា ឯវំ ពហុលីកតា និព្វេធភាគិយា សំវត្តន្តីតិ ។

(៦៨៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ ភាវិតោ ពហុលីកតោ សញ្ញោជនិយានំ ធម្មានំ បហានាយ សំវត្តតិ យថយិទំ ភិក្ខវេ សត្ត ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។

(៦៨៩) កថំ ភាវិតា ច ភិក្ខវេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា សញ្ញោជនិយានំ ធម្មានំ បហានាយ សំវត្តន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គ-



មិនធ្លាប់បានទំលាយចេញ រមែងចាក់ទម្លុះទំលាយនូវគំនរទោសៈ ដែលខ្លួនមិនធ្លាប់បានចាក់ទម្លុះ មិនធ្លាប់បានទំលាយចេញ រមែងចាក់ទម្លុះទំលាយនូវគំនរមោហៈ ដែលខ្លួនមិនធ្លាប់បានចាក់ទម្លុះ មិនធ្លាប់បានទំលាយចេញ ។ ម្នាលខេមាយ៍ ពោជ្ឈង្គទាំង៧ប្រការ ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីការចាក់ទម្លុះខ្ទៀ (កងកិលេស) ។

(៦៨៨) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញធម៌ដទៃណាមួយ ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវធម៌ទាំងឡាយ ដែលកប់បញ្ចូលក្នុងគ្រឿងសញ្ញោជនៈ ដូចជាពោជ្ឈង្គទាំង៧នេះឡើយ ។ ពោជ្ឈង្គទាំង៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

(៦៨៩) ម្នាលភិក្ខុទាំងឡាយ ចុះពោជ្ឈង្គទាំង៧ ដែលភិក្ខុបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីលះបង់នូវធម៌ទាំងឡាយ ដែលកប់បញ្ចូលក្នុងគ្រឿងសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅ

បរិណាមឹ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេក-និស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិ-ណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា សញ្ញោជនិយានំ ធម្មានំ បហានាយ សំវត្តន្តិ ។

[៤៨៧] កតមេ ច ភិក្ខវេ សញ្ញោជនិយា ធម្មា ។ ចក្ខុំ ភិក្ខវេ សញ្ញោជនិយោ ធម្មោ ឯត្ថេតេ ឧប្បជ្ជន្តិ សញ្ញោជនវិនិពន្ធា អជ្ឈោសានា ។ សោតំ ឃានំ ជិវ្ហា សញ្ញោជនិយោ ធម្មោ ឯត្ថេតេ ឧប្បជ្ជន្តិ សញ្ញោជន-វិនិពន្ធា អជ្ឈោសានា ។ មនោ សញ្ញោជនិយោ ធម្មោ ឯត្ថេតេ ឧប្បជ្ជន្តិ សញ្ញោជនវិនិពន្ធា អជ្ឈោសានា ។ ឥមេ វុច្ចន្តិ ភិក្ខវេ សញ្ញោជនិយា ធម្មាតិ ។



ដើម្បីការលះបង់ ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ប្រការ ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវធម៌ទាំងឡាយ ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈ ។

[៤៨៧] ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាធម៌ ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈ ការប្រកាន់មាំ ជាគ្រឿងរួបរឹត នឹងសញ្ញោជនៈទាំងនោះ រមែងកើតឡើងក្នុងចក្ខុនោះ សោតៈ ឃានៈ ជិវ្ហា ជាធម៌ ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈដែរ ការប្រកាន់មាំ ជាគ្រឿងរួបរឹត នឹងសញ្ញោជនៈទាំងនុ៎ះ រមែងកើតឡើង ក្នុងធម៌ទាំងនោះ មនោជាធម៌ ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈដែរ ការប្រកាន់មាំ ជាគ្រឿងរួបរឹត នឹងសញ្ញោជនៈទាំងនុ៎ះ រមែងកើតឡើង ក្នុងមនោនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ដែលកប់បញ្ចូលគន្លឹកសញ្ញោជនៈ ។

(៦៨៨) ឯកំ សមយំ ភគវា សុម្ភេសុ វិហរតិ សេទកន្នាម សុម្ភានំ និគមោ ។ អថខោ អាយស្មា ឧទាយី យេន ភគវា តេនុបសង្កមិ ។បេ។ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧទាយី ភគវន្តំ ឯតទវោច ។

(៦៨៩) អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ ពហុការកំ(១) មេ ភន្តេ ភគវតិ បេមញ្ច គារវោ ច ហិរី ច ឱត្តប្បញ្ច អហញ្ហិ ភន្តេ បុព្វេ អាគារិកភូតោ សមានោ អពហុកតោ អហោសឹ ធម្មេន អពហុកតោ សង្ឃេន សោ ខ្វាហំ(២) ភគវតិ បេមញ្ច គារវញ្ច ហិរិញ្ច ឱត្តប្បញ្ច សម្បស្សមានោ អគារស្មា អនគារិយំ បព្វជឹ(៣) តស្ស មេ ភគវា ធម្មំ ទេសេសិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ។បេ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។

១. ពហុកតញ្ច មេ ។ ម. ពហុការកំ មេ ។ ២ ខ្វាហំ ភន្តេ ឥតិសទ្ទោបិ ។ ៣ បព្វជិតោ ។



(៦៨៨) សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងនិគម ឈ្មោះសេទកៈ របស់អ្នកស្រុកសុម្ភៈទាំងឡាយ ក្នុងដែនសុម្ភៈ ។ គ្រានោះឯង ព្រះឧទាយីដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះឧទាយីដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ។

(៦៨៩) បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះអស្ចារ្យ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះចំឡែក បពិត្រព្រះអង្គដ៏ចំរើន សេចក្តីស្រឡាញ់ សេចក្តីគោរព សេចក្តីអៀនខ្មាស និងសេចក្តីកោតក្រែង ចំពោះព្រះដ៏មានព្រះភាគ ព្រោះមានឧបការៈច្រើន ដល់ខ្ញុំព្រះអង្គដោយពិត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ កាលពីដើមនៅជាគ្រហស្ថ មិនមានសេចក្តីរាប់អានច្រើន ចំពោះព្រះធម៌ទេ មិនមានសេចក្តីរាប់អានច្រើន ចំពោះព្រះសង្ឃទេ ខ្ញុំព្រះអង្គកាលណាឃើញនូវសេចក្តីស្រឡាញ់ សេចក្តីគោរព សេចក្តីអៀនខ្មាស និងសេចក្តីកោតក្រែង ចំពោះព្រះដ៏មានព្រះភាគ ទើបចេញចាកផ្ទះមកកាន់ផ្នួស ព្រះដ៏មានព្រះភាគបានសំដែងធម៌ ដល់ខ្ញុំព្រះអង្គថា រូបដូច្នេះ ហេតុជាទីកើតនៃរូបដូច្នេះ សេចក្តីវិនាសនៃរូបដូច្នេះ វេទនាដូច្នេះ ។បេ។ សញ្ញាដូច្នេះ ។ សង្ខារទាំងឡាយដូច្នេះ ។

អត្ថិ វិញ្ញាណំ អត្ថិ វិញ្ញាណស្ស សមុទយោ អត្ថិ វិញ្ញា-
ណស្ស អត្ថង្គមោតិ ។

[៤៦០] សោ ខ្វាហំ ភន្តេ សុញ្ញាគារគតោ ឥមេសំ បញ្ចុបាទានក្ខន្ធានំ ឧទយព្វយំ អនុបស្សន្តោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។

[៤៦១] ធម្មោ ច មេ ភន្តេ អភិសមេតោ មគ្គោ ច មេ បដិលទ្ធោ យោ មេ ភាវិតោ ពហុលីកតោ តថា តថា វិហរន្តំ តថត្តាយ ឧបនេស្សតិ យថាហំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានិស្សាមិ ។ សតិសម្ពោជ្ឈង្គោ មេ ភន្តេ បដិលទ្ធោ យោ មេ ភាវិតោ ពហុលីកតោ



វិញ្ញាណក្ខន្ធ ហេតុជាទីកើតនៃវិញ្ញាណក្ខន្ធ សេចក្តីវិនាសនៃវិញ្ញាណក្ខន្ធ ។

(៤៦០) បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គទៅក្នុងផ្ទះដ៏ស្ងាត់ បានប្រែប្រួលប់ឲ្យឃើញនូវការកើតនិងរលត់ចុះឡើងៗ នៃឧបាទានក្ខន្ធទាំង ៥ នេះ បានដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ បានដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុជាទីកើតនៃទុក្ខ បានដឹងច្បាស់តាមសេចក្តីពិតថា នេះជាទីរលត់នៃទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់នៃទុក្ខ ។

(៤៦១) បពិត្រព្រះអង្គដ៏ចំរើន ធម៌ខ្ញុំព្រះអង្គបានត្រាស់ដឹងហើយផង មគ្គខ្ញុំព្រះអង្គបានចំពោះហើយផង មគ្គឯណា ដែលខ្ញុំព្រះអង្គបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ មគ្គនោះនឹងនាំខ្ញុំព្រះអង្គដែលកំពុងសម្រេចសម្រាន្តនៅដោយអាការនោះៗ ដើម្បីសេចក្តីពិត ដែលជាហេតុឲ្យខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន សតិសម្ពោជ្ឈង្គ ខ្ញុំព្រះអង្គបានចំពោះហើយ សតិសម្ពោជ្ឈង្គឯណា ដែលខ្ញុំព្រះអង្គបានចំរើន បានធ្វើឲ្យច្រើនហើយ

តថា តថា វិហរន្តំ តថត្តាយ ឧបេក្ខតិ យថាហំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានិស្សាមិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ មេ ភន្តេ បដិលទ្ធោ យោ មេ ភាវិតោ ពហុលីកតោ តថា តថា វិហរន្តំ តថត្តាយ ឧបេក្ខតិ យថាហំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានិស្សាមិ ។ អយំ ខោ មេ ភន្តេ មគ្គោ



សតិសម្ពោជ្ឈង្គនោះ ទំនងនាំឲ្យខ្ញុំព្រះអង្គដែលកំពុងសម្រេចសម្រាន្តនៅដោយប្រការដូច្នោះៗ ដើម្បីសេចក្តីពិត ដែលជាហេតុឲ្យខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបេក្ខាសម្ពោជ្ឈង្គខ្ញុំព្រះអង្គបានចំពោះហើយ ឧបេក្ខាសម្ពោជ្ឈង្គឯណា ដែលខ្ញុំព្រះអង្គបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ ឧបេក្ខាសម្ពោជ្ឈង្គនោះ ទំនងនាំឲ្យខ្ញុំព្រះអង្គដែលកំពុងសម្រេចសម្រាន្តនៅដោយប្រការដូច្នោះៗ ដើម្បីសេចក្តីពិត ដែលជាហេតុឲ្យខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងជាមគ្គ ដែលខ្ញុំ

បដិលទ្ធោ យោ មេ ភាវិតោ ពហុលីកតោ តថា តថា វិហរន្តំ តថត្តាយ ឧបនេស្សតិ យថាហំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានិស្សាមីតិ ។

(៦៦៦) សាធុ សាធុ ឧទាយិ ឯសោ ហិ តេ ឧទាយិ មគ្គោ បដិលទ្ធោ យោ តេ ភាវិតោ ពហុលីកតោ តថា តថា វិហរន្តំ តថត្តាយ ឧបនេស្សតិ យថា ត្វំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានិស្សសីតិ ។

ឧទាយិវគ្គោ តតិយោ ។



ព្រះអង្គបានចំពោះហើយ មគ្គឯណា ដែលខ្ញុំព្រះអង្គបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ មគ្គនោះ នឹងនាំឲ្យខ្ញុំព្រះអង្គដែលកំពុងសម្រេចសម្រាន្តនៅដោយប្រការដូច្នោះៗ ដើម្បីសេចក្តីពិត ដែលជាហេតុឲ្យខ្ញុំព្រះអង្គដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

(៦៦៦) ម្នាលឧទាយិ ប្រពៃណាស់ហើយ ម្នាលឧទាយិ ប្រពៃណាស់ហើយ ព្រោះថាមគ្គនុ៎ះអ្នកបានចំពោះហើយ មគ្គឯណា ដែលអ្នកបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ មគ្គនោះ នឹងនាំអ្នកដែលកំពុងសម្រេចសម្រាន្តនៅដោយប្រការដូច្នោះៗ ដើម្បីសេចក្តីពិត ដែលជាហេតុឲ្យអ្នកដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

ចប់ ឧទាយិវគ្គទី ៣ ។

ទសកៈ់រ្ហ

## ពស្បុទ្ធិ

ពោធិសា នេសនាថ្នាថា

អយោនិសោ ចាបរំបាកំ

ទយោ ធំពេនោ ចំពេរនោ

បាកាជប្បោ ទុតាយំទាតំ ។



ទសកៈ់ទ្វ

## ទុក្ខនៃទុក្ខាយវិត្តនោះគឺ

ពោលអំពីពោជ្ឈន្ត្របែព្រែក្តពោធិយ៍ព្រែសរដ៏ ១ អំពីការ សំផែនពោជ្ឈន្ត ១ អំពីធម៌ជាហេតុដាច់កាំនៃកាមរាគ ១ អំពីការធ្វើទុក្ខក្នុងចិត្តដោយមិនមានទុក្ខាយព្រែញ ១ អំពី អបរិហានិយធម៌ ១ អំពីការអស់ទៅនៃតណ្ហា ១ អំពីការ លេកនៃតណ្ហា ១ អំពីការពាក់ទម្ងន់ខ្លាំងកាចចិត្តលេស ១ អំពី ព្រែន័មិនឃើញធម៌ដទៃស្មើមួយ ១ អំពីព្រែះទុក្ខាយមិនមាន កាយុ ១ ។

## នីវរណវគ្គោ

[៤៦៣] យេ កេចិ ភិក្ខវេ ធម្មា កុសលា កុសលភាគិយា កុសលបក្ខិកា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ ។ អប្បមត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីករិស្សតីតិ ។

[៤៦៤] កថញ្ច ភិក្ខវេ ភិក្ខុ អប្បមត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អប្បមត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។

## នីវរណវគ្គ

[៤៦៣] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយឯណានីមួយ ជាកុសល ជាចំណែកកុសល ជាបក្ខពួកកុសល ធម៌ទាំងអស់នោះ មានសេចក្តីមិនប្រមាទជាឫសគល់ ជាទីប្រជុំចុះក្នុងសេចក្តីមិនប្រមាទ សេចក្តីមិនប្រមាទ ប្រាកដជាកំពូលនៃកុសលធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនោះនឹងប្រាកដដល់ភិក្ខុដែលមិនប្រមាទ ភិក្ខុនោះ នឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ ប្រការ ។

[៤៦៤] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនប្រមាទ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅរកការលះបង់ ។ បេ ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនប្រមាទ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

(២៦៥) យេ កេចិ ភិក្ខវេ ធម្មា កុសលា កុស-
លភាគិយា កុសលបក្ខិកា សព្វេ តេ យោនិសោម-
នសិការមូលកា យោនិសោមនសិការសមោសរណា
យោនិសោមនសិការោ តេសំ ធម្មានំ អគ្គមក្ខាយតិ ។
យោនិសោមនសិការសម្បន្នស្សេតំ ភិក្ខវេ ភិក្ខុនោ
បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ
ពហុលីករិស្សតិ ។

(២៦៦) កថញ្ច ភិក្ខវេ ភិក្ខុ យោនិសោមនសិ-
ការសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ
ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ
ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ
វោស្សគ្គបរិណាមឹ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ
វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គប-
រិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យោនិសោមនសិកា-
រសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ
ពហុលីករោតីតិ ។



(២៦៥) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយឯណាមួយ ជា
កុសល ជាចំណែកនៃកុសល ជាបក្សពួកនៃកុសល ធម៌ទាំងអស់នោះ
មានយោនិសោមនសិការៈជាមូលរបស់ មានយោនិសោមនសិការៈជាទី
ប្រជុំ យោនិសោមនសិការៈ ប្រាកដជាកំពូលនៃធម៌ទាំងនោះ ។
ម្នាលភិក្ខុទាំងឡាយ ដំណើរនុះគឺប្រាកដដល់ភិក្ខុដែលបរិបូណ៌ដោយ
យោនិសោមនសិការៈ ភិក្ខុនោះនឹងចំរើននូវពោជ្ឈង្គទាំង ៧ នឹងធ្វើឲ្យ
ច្រើននូវពោជ្ឈង្គទាំង ៧ ។

(២៦៦) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ដោយយោ
និសោមនសិការៈ រមែងចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គ
ទាំង ៧ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើន
នូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យ
នូវនិរោធ បង្អោនទៅរកការលះបង់ ។ បេ ។ រមែងចំរើនឧបេក្ខាសម្ពោជ្ឈង្គ
ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោន
ទៅរកការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយយោនិ
សោមនសិការៈ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គ
ទាំង ៧ យ៉ាងនេះឯង ។

(៦៦៧) បញ្ចិមេ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។ កតមេ បញ្ច ។

(៦៦៨) អយោ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។

(៦៦៩) លោហំ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋំ ជាតរូបំ ។បេ។

(៦៧០) តិបុ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសោ ។បេ។

(៦៧១) សីសំ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសោ ។បេ។



(៦៦៧) ម្នាលភិក្ខុទាំងឡាយ ឧបក្កិលេសរបស់មាសនេះ មាន ៥ យ៉ាង ដែលធ្វើឲ្យមាសសៅហ្មង ទៅជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាពុកផុយផង មិនគួរប្រកបការងារដោយប្រពៃផង ។ ឧបក្កិលេស ៥ តើអ្វីខ្លះ ។

(៦៦៨) ម្នាលភិក្ខុទាំងឡាយ ដែកជាឧបក្កិលេសរបស់មាស ដែលធ្វើឲ្យមាសសៅហ្មង ទៅជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាពុកផុយផង មិនគួរប្រកបការងារដោយប្រពៃផង ១ ។

(៦៦៩) ម្នាលភិក្ខុទាំងឡាយ ស្ពាន់ជាឧបក្កិលេសរបស់មាស ដែលធ្វើឲ្យមាសសៅហ្មង ។បេ។

(៦៧០) ម្នាលភិក្ខុទាំងឡាយ សំណប៉ាហាំងជាឧបក្កិលេសរបស់មាស ។បេ។

(៦៧១) ម្នាលភិក្ខុទាំងឡាយ សំណកក់ជាឧបក្កិលេសរបស់មាស ។បេ។

(៦៧២) សជ្ឈុ ភិក្ខវេ ជាតរូបស្ស ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។

(៦៧៣) ឥមេ ខោ ភិក្ខវេ បញ្ច ជាតរូបស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ជាតរូបំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។

(៦៧៤) ឯវមេវ ខោ ភិក្ខវេ បញ្ចិមេ ចិត្តស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ចិត្តំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា សមាធិយតិ អាសវានំ ខយាយ ។ កតមេ បញ្ច ។

(៦៧៥) កាមច្ឆន្ទោ ភិក្ខវេ ចិត្តស្ស ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋំ ចិត្តំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា សមាធិយតិ អាសវានំ ខយាយ ។





(៦៧២) ម្នាលភិក្ខុទាំងឡាយ ប្រាក់ជាឧបក្កិលេសរបស់មាស ដែលធ្វើឲ្យមាសសៅហ្មង ទៅជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាពុកផុយផង មិនគួរប្រកបការងារដោយប្រពៃផង ១ ។

(៦៧៣) ម្នាលភិក្ខុទាំងឡាយ ឧបក្កិលេសរបស់មាសទាំង ៥ នេះឯង ដែលធ្វើឲ្យមាសសៅហ្មង ទៅជារបស់មិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាពុកផុយផង មិនគួរប្រកបការងារដោយប្រពៃផង ។

(៦៧៤) ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះដែរហើយ ឧបក្កិលេសនៃចិត្តទាំង ៥ នេះ ដែលធ្វើឲ្យចិត្តសៅហ្មង ទៅជាធម្មជាតមិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ជាចិត្តពុកផុយផង មិនដំកល់មាំដោយប្រពៃ ដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយផង ។ ឧបក្កិលេសទាំង ៥ តើអ្វីខ្លះ ។

(៦៧៥) ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាឧបក្កិលេសនៃចិត្ត ដែលធ្វើចិត្តឲ្យសៅហ្មង ទៅជាចិត្តមិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ជាចិត្តពុកផុយផង មិនដំកល់មាំដោយប្រពៃ ដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយផង ១ ។

(៤៧៦) កាមច្ឆន្ទោ ភិក្ខវេ ចិត្តស្ស ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋំ ចិត្តំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា សមាធិយតិ អាសវានំ ខយាយ ។ បេ ។

(៤៧៧) ឥមេ ខោ ភិក្ខវេ បញ្ច ចិត្តស្ស ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ចិត្តំ ន ចេវ មុទុ ហោតិ ន ច កម្មនិយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា សមាធិយតិ អាសវានំ ខយាយ ។

(៤៧៨) សត្តិមេ ភិក្ខវេ ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ កតមេ សត្ត ។

(៤៧៩) សតិសម្ពោជ្ឈង្គោ ភិក្ខវេ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។ បេ ។



(៤៧៦) ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាឧបក្កិលេសនៃចិត្ត ធ្វើឲ្យចិត្តសៅហ្មង ទៅជាចិត្តមិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាអំពុកផុយផង មិនដំកល់មាំដោយប្រពៃ ដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយផង ។ បេ ។

(៤៧៧) ម្នាលភិក្ខុទាំងឡាយ ឧបក្កិលេសនៃចិត្តទាំង ៥ នេះឯង ដែលធ្វើឲ្យចិត្តសៅហ្មង ជាចិត្តមិនទន់ផង មិនគួរដល់ការងារផង មិនមានពន្លឺផង ទៅជាអំពុកផុយផង មិនដំកល់មាំដោយប្រពៃ ដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយផង ។

(៤៧៨) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ប្រការនេះ ជាគ្រឿងមិនរាំង មិនបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។

(៤៧៩) ម្នាលភិក្ខុទាំងឡាយ សតិសម្ពោជ្ឈង្គជាគ្រឿងមិនរាំង មិនបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។ បេ ។

(៥៨០) ឧបេក្ខាសម្ពោជ្ឈង្គោ ភិក្ខវេ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ច ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។

(៥៨១) ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។

(៥៨២) អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នោ ចេវ កាមច្ឆន្ទោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៥៨៣) អនុប្បន្នោ ចេវ ព្យាបាទោ ឧប្បជ្ជតិ ឧប្បន្នោ ច ព្យាបាទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។





(៥៨០) ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាសម្ពោជ្ឈង្គជាគ្រឿងមិនរាំង មិនបិទបាំង មិនមែនជាបច្ច័យសៅហ្មងរបស់ចិត្ត បុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។

(៥៨១) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង មិនមែនជាគ្រឿងរាំង មិនបិទបាំង មិនមែនជាបច្ច័យសៅហ្មងរបស់ចិត្តទេ បុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។

(៥៨២) ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយមិនបានដោយប្រាជ្ញា កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបាន ចំណែកកាមច្ឆន្ទៈដែលកើតឡើងហើយ ក៏រមែងប្រព្រឹត្តទៅដើម្បីភាពដ៏ធំទូលាយ ជាភិយ្យោភាព ។

(៥៨៣) ព្យាបាទដែលមិនទាន់កើតឡើង រមែងកើតឡើងបាន ចំណែកព្យាបាទដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីភាពដ៏ធំទូលាយ ជាភិយ្យោភាព ។

(៦៨៤) អនុប្បន្នញ្ចេវ ថីនមិទ្ធំ ឧប្បជ្ជតិ ឧប្បន្នញ្ច ថីនមិទ្ធំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៦៨៥) អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ ឧប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៦៨៦) អនុប្បន្នា ចេវ វិចិកិច្ឆា ឧប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

(៦៨៧) យោនិសោ ច ភិក្ខវេ មនសិករោតោ អនុប្បន្នោ ចេវ សតិសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច សតិសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។បេ។

(៦៨៨) អនុប្បន្នោ ចេវ ឧបេក្ខាសម្ពោជ្ឈង្គោ ឧប្បជ្ជតិ ឧប្បន្នោ ច ឧបេក្ខាសម្ពោជ្ឈង្គោ ភាវនាបារិបូរឹ គច្ឆតិ ។



(៦៨៤) ថីនមិទ្ធដែលមិនទាន់កើតឡើង រមែងកើតឡើងបាន ចំណែកថីនមិទ្ធដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីការធំទូលាយ ជាភិយ្យោភាព ។

(៦៨៥) ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង រមែងកើតឡើង ចំណែកឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏រមែងប្រព្រឹត្តទៅដើម្បីការធំទូលាយ ជាភិយ្យោភាព ។

(៦៨៦) វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបាន ចំណែកវិចិកិច្ឆាដែលកើតឡើងហើយ ក៏រមែងប្រព្រឹត្តទៅដើម្បីការធំទូលាយ ជាភិយ្យោភាព ។

(៦៨៧) ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គល កាលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា សតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើងបាន ចំណែកសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ។បេ។

(៦៨៨) ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ក៏កើតឡើងបាន ចំណែកឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ។

(៤៨៩) សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ភាវិតា ពហុលីកតា វុឌ្ឍិយា អបរិហានាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វុឌ្ឍិយា អបរិហានាយ សំវត្តន្តីតិ ។

(៤៩០) បញ្ចិមេ ភិក្ខវេ អាវរណា នីវរណា ចេតសោ ឧបក្កិលេសា បញ្ញាយ ទុព្ពលីករណា ។ កតមេ បញ្ច ។ កាមច្ឆន្ទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ ឧបក្កិលេសោ បញ្ញាយ ទុព្ពលីករណោ ។ ព្យាបាទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ ឧបក្កិលេសោ បញ្ញាយ ទុព្ពលីករណោ ។ ថីនមិទ្ធំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ ឧបក្កិលេសំ បញ្ញាយ ទុព្ពលីករណំ ។ ឧទ្ធច្ចកុក្កុច្ចំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ ឧបក្កិលេសំ បញ្ញាយ ទុព្ពលីករណំ ។ វិចិកិច្ឆា ភិក្ខវេ អាវរណា នីវរណា ចេតសោ ឧបក្កិលេសា





[៤៨៩] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីមិនសាបសូន្យ ។ ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីមិនសាបសូន្យ ។

[៤៩០] ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ មាន ៥ ប្រការនេះ ។ ធម៌ ៥ ប្រការតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈ ជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ ព្យាបាទជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចៈជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាជាគ្រឿងកាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត

បញ្ញាយ ទុព្វលីករណា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាវរណា នីវរណា ចេតសោ ឧបក្កិលេសា បញ្ញាយ ទុព្វលីករណាតិ ។

[៤៩១] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ភិក្ខវេ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ភិក្ខវេ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។



ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ ប្រការនេះឯង ជាគ្រឿងរាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ។

(៤៩១) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ជាគ្រឿងមិនរាំង មិនបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សតិសម្ពោជ្ឈង្គ ជាគ្រឿងមិនរាំង មិនបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្តទេ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។បេ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាសម្ពោជ្ឈង្គ មិនមែនជាគ្រឿងរាំង មិនមែនបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្តទេ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង មិនមែនជាគ្រឿងរាំង មិនមែនជាគ្រឿងបិទបាំង មិនមែនជាឧបក្កិលេសរបស់ចិត្តទេ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។

នីវរណវគ្គោ

(៦៩៦) យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ បញ្ចស្ស[១] នីវរណា តស្មឹ សមយេ ន ហោន្តិ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តិ ។

(៦៩៧) កតមស្ស បញ្ច[២] នីវរណា តស្មឹ សមយេ ន ហោន្តិ ។ កាមច្ឆន្ទនីវរណំ តស្មឹ សមយេ ន ហោតិ ព្យាបាទនីវរណំ តស្មឹ សមយេ ន ហោតិ ថីនមិទ្ធនីវរណំ តស្មឹ សមយេ ន ហោតិ ឧទ្ធច្ចកុក្កុច្ចនីវរណំ តស្មឹ សមយេ ន ហោតិ វិចិកិច្ឆានីវរណំ តស្មឹ សមយេ ន ហោតិ ។ បញ្ចស្ស នីវរណា តស្មឹ សមយេ ន ហោន្តិ ។

១ ម. ឱ. ឥមស្ស បញ្ច ។ ២ ម. ឱ. កតមេ បញ្ច ។



នីវរណវគ្គ

(៦៩៦) ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងអស់ ផ្ទៀងសោតប្រសាទ ស្តាប់ធម៌ សម័យនោះ នីវរណធម៌ទាំង ៥ មិនមានដល់ភិក្ខុនោះឡើយ ពោជ្ឈង្គទាំង ៧ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះដែរ ។

(៦៩៧) ចុះនីវរណធម៌ទាំង ៥ ដែលមិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ តើដូចម្តេច ។ កាមច្ឆន្ទនីវរណៈ មិនមានក្នុងសម័យនោះ ព្យាបាទនីវរណៈ មិនមានក្នុងសម័យនោះ ថីនមិទ្ធនីវរណៈ មិនមានក្នុងសម័យនោះ ឧទ្ធច្ចកុក្កុច្ចនីវរណៈ មិនមានក្នុងសម័យនោះ វិចិកិច្ឆានីវរណៈ មិនមានក្នុងសម័យនោះ ។ នីវរណធម៌ទាំង ៥ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ ។

(៦៩៦) កតមេ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តិ ។ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆតិ ។ ឥមេ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តិ ។

(៦៩៧) យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ បញ្ចស្ស នីវរណា តស្មឹ សមយេ ន ហោន្តិ ឥមេ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តីតិ ។

(៦៩៨) សន្តិ ភិក្ខវេ មហារុក្ខា អណុពីជា មហាកាយា រុក្ខានំ អជ្ឈារុហា(១) យេហិ រុក្ខា អជ្ឈារុហា ឱភគ្គវិភគ្គា វិបតិតា សេន្តិ ។

១ ម. ឆ. អជ្ឈោរុហា ។



(៦៩៦) ពោជ្ឈង្គទាំង ៧ ដែលដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះ តើដូចម្តេច ។ សតិសម្ពោជ្ឈង្គ ដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះ ។ ពោជ្ឈង្គទាំង ៧ នេះ រមែងដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះ ។

(៦៩៧) ម្នាលភិក្ខុទាំងឡាយ សម័យណា ដែលអរិយសាវកធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលចិត្តទាំងអស់ ផ្ទៀងសោតប្រសាទស្តាប់ធម៌ សម័យនោះ នីវរណធម៌ ៥ រមែងមិនមានដល់ភិក្ខុនោះឡើយ ពោជ្ឈង្គទាំង ៧ នេះ ក៏ដល់នូវការពេញបរិបូណ៌ដោយភាវនា ក្នុងសម័យនោះដែរ ។

(៦៩៨) ម្នាលភិក្ខុទាំងឡាយ មានដើមឈើធំៗ មានគ្រាប់តូច មានទំហំដើមធំ ដុះគ្របដើមឈើទាំងឡាយ ពួកដើមឈើ ដែលដើមឈើធំៗ ដុះគ្រប ក៏បាក់បែកខ្ទេចខ្ទី រលំដួលទៅ ។

(៦៩៧) កតមេ ច តេ ភិក្ខវេ មហារុក្ខា អណុពីជា មហាកាយា រុក្ខានំ អជ្ឈារុហា យេហិ រុក្ខា អជ្ឈារុឡ្ហា ឱភគ្គវិភគ្គា វិបតិតា សេន្តិ ។ សេយ្យថីទំ ។ អស្សត្ថោ និគ្រោធោ បិលក្ខោ[១] ឧទុម្ពរោ កច្ឆកោ កបិត្ថនោ ។ ឥមេ ខោ តេ ភិក្ខវេ មហារុក្ខា អណុពីជា មហាកាយា រុក្ខានំ អជ្ឈារុហា យេហិ រុក្ខា អជ្ឈារុឡ្ហា ឱភគ្គវិភគ្គា វិបតិតា សេន្តិ ។

(៦៩៨) ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ កុលបុត្តោ យាទិសកេ កាមេ ឱហាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ តាទិសកេហិ[២] កាមេហិ តតោ វា បាបិដ្ឋតរេហិ ឱភគ្គវិភគ្គោ វិបតិតោ សេតិ ។

(៦៩៩) បញ្ចិមេ ភិក្ខវេ អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្វលីករណា ។ កតមេ បញ្ច ។ កាមច្ឆន្ទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ អជ្ឈារុហោ បញ្ញាយ ទុព្វលីករណោ ។

១ ឱ. ម. បិលក្ខោ ។ ២ ឱ. ឆន្ទកេហិ ហោតិ ។



(៦៩៧) ម្នាលភិក្ខុទាំងឡាយ ចុះដើមឈើធំៗ ដែលមានគ្រាប់តូច មានទំហំដើមធំ ដុះគ្របដើមឈើទាំងឡាយ ពួកដើមឈើ ដែលឈើធំៗដុះគ្រប ក៏បាក់បែកខ្ទេចខ្ទី រលំដួលទៅ តើដូចម្តេច ។ ដើមឈើទាំងនោះ គឺអ្វីខ្លះ ។ គឺដើមពោធិ៍ធ្លាយ ដើមជ្រៃ ដើមល្វៀង ដើមល្វា ដើមជ្រៃគ្រឹម ដើមក្រាង ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើធំៗទាំងនេះឯង មានគ្រាប់តូច មានទំហំដើមធំ ដុះគ្របដើមឈើទាំងឡាយ ពួកដើមឈើ ដែលឈើធំៗដុះគ្រប ក៏បាក់បែកខ្ទេចខ្ទី រលំដួលទៅ ។

(៦៩៨) ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះដែរហើយ កុលបុត្តខ្លះក្នុងលោកនេះ លះបង់ពួកកាមបែបណាហើយ ចេញចាកផ្ទះចូលកាន់ផ្នួស កុលបុត្តនោះត្រូវពួកកាមបែបនោះ ឬពួកកាមដ៏លាមកក្រៃលែងជាងនោះទៅទៀត គ្របសង្កត់ រួចក៏ ដួលផ្តេកទៅ ។

(៦៩៩) ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ ប្រការនេះ ជាគ្រឿងរារាំង ជាគ្រឿងបិទបាំង ដុះរួបរឹតចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ។ ធម៌ ៥ ប្រការគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាគ្រឿងរារាំង ជាគ្រឿងបិទបាំង ដុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ១ ។

ព្យាបាទោ ភិក្ខវេ អាវរណោ នីវរណោ ចេតសោ អជ្ឈារុហោ បញ្ញាយ ទុព្ពលីករណោ ។ ថីនមិទ្ធំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ អជ្ឈារុហំ បញ្ញាយ ទុព្ពលីករណំ ។ ឧទ្ធច្ចកុក្កុច្ចំ ភិក្ខវេ អាវរណំ នីវរណំ ចេតសោ អជ្ឈារុហំ បញ្ញាយ ទុព្ពលីករណំ ។ វិចិកិច្ឆា ភិក្ខវេ អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្ពលីករណា ។ ឥមេ ខោ ភិក្ខវេ បញ្ច អាវរណា នីវរណា ចេតសោ អជ្ឈារុហា បញ្ញាយ ទុព្ពលីករណា ។

[៤០០] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនជ្ឈារុហា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ភិក្ខវេ អនាវរណោ អនីវរណោ ចេតសោ អនជ្ឈារុហោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។បេ។



ម្នាលភិក្ខុទាំងឡាយ ព្យាបាទជាគ្រឿងរាំង ជាគ្រឿងបិទបាំង ផុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ១ ។ ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈជាគ្រឿងរាំង ជាគ្រឿងបិទបាំង ផុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចៈជាគ្រឿងរាំង ជាគ្រឿងបិទបាំង ផុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ១ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាជាគ្រឿងរាំង ជាគ្រឿងបិទបាំង ផុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ នេះឯង ជាគ្រឿងរាំង ជាគ្រឿងបិទបាំង ផុះគ្របសង្កត់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ។

[៤០០] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ មិនមែនជាគ្រឿងរាំង មិនមែនជាគ្រឿងបិទបាំង មិនមែនផុះគ្របសង្កត់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។ ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សតិសម្ពោជ្ឈង្គ មិនមែនជាគ្រឿងរាំង មិនមែនជាគ្រឿងបិទបាំង មិនមែនផុះគ្របសង្កត់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។បេ។

ឧបេក្ខាសម្ពោជ្ឈង្គំ ។បេ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនជ្ឈារុហា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

[៤០១] បញ្ចិមេ ភិក្ខវេ នីវរណា អន្ធករណា អចក្ខុករណា អញ្ញាណករណា បញ្ញានិរោធិកា វិឃាតបក្ខិយា អនិព្វានសំវត្តនិកា ។ កតមេ បញ្ច ។ កាមច្ឆន្ទនីវរណំ ភិក្ខវេ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិយំ អនិព្វានសំវត្តនិកំ ។ ព្យាបាទនីវរណំ ភិក្ខវេ អន្ធករណំ ។បេ។ ថីនមិទ្ធនីវរណំ ភិក្ខវេ អន្ធករណំ ។ ឧទ្ធច្ចកុក្កុច្ចនីវរណំ ភិក្ខវេ អន្ធករណំ ។ វិចិកិច្ឆានីវរណំ ភិក្ខវេ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិយំ អនិព្វានសំវត្តនិកំ ។





ឧបេក្ខាសម្ពោជ្ឈង្គ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង មិនមែនជាគ្រឿងរាំង មិនមែនជាគ្រឿងបិទបាំង មិនមែនជាគ្របសង្កត់ចិត្ត ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល ។

[៤០១] ម្នាលភិក្ខុទាំងឡាយ នីវរណធម៌ ៥ ប្រការនេះ ជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុឲ្យរលត់នៃបញ្ញា ជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ នីវរណធម៌ ៥ ប្រការតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទនីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុឲ្យរលត់ទៅនៃបញ្ញា ជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ព្យាបាទនីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ។បេ។ ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធនីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆានីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុឲ្យរលត់ទៅនៃបញ្ញា ជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

ឥមេ ខោ ភិក្ខវេ បញ្ច នីវរណា អន្ធករណា អចក្ខុករណា អញ្ញាណករណា បញ្ញានិរោធិកា វិឃាតបក្ខិយា អនិព្ពានសំវត្តនិកា ។

[៤០៤] សត្តិមេ ភិក្ខវេ ពោជ្ឈង្គា ចក្ខុករណា ញាណករណា បញ្ញាវុទ្ធិយា អវិឃាតបក្ខិយា និព្ពានសំវត្តនិកា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ភិក្ខវេ ចក្ខុករណោ ញាណករណោ បញ្ញាវុទ្ធិយោ អវិឃាតបក្ខិយោ និព្ពានសំវត្តនិកោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ភិក្ខវេ ចក្ខុករណោ ញាណករណោ បញ្ញាវុទ្ធិយោ អវិឃាតបក្ខិយោ និព្ពានសំវត្តនិកោ ។ ឥមេ ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ចក្ខុករណា ញាណករណា បញ្ញាវុទ្ធិយា អវិឃាតបក្ខិយា និព្ពានសំវត្តនិកាតិ ។

នីវរណវគ្គោ ចតុត្ថោ ។



ម្នាលភិក្ខុទាំងឡាយ នីវរណធម៌ ៥ ប្រការនេះឯង ជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុឲ្យរលត់ទៅនៃបញ្ញា ជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

[៤០៤] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ជាធម៌ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យដឹង ជាហេតុឲ្យចំរើនប្រាជ្ញា មិនមែនជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សតិសម្ពោជ្ឈង្គ ជាធម៌ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យដឹង ជាហេតុឲ្យចំរើនប្រាជ្ញា មិនមែនជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាសម្ពោជ្ឈង្គ ជាធម៌ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យដឹង ជាហេតុឲ្យចំរើនប្រាជ្ញា មិនមែនជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ជាធម៌ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យដឹង ជាហេតុឲ្យចំរើនប្រាជ្ញា មិនមែនជាបក្ខពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

ចប់ និវរណវគ្គ ទី ៤ ។

## តស្សុទ្ទានំ

ទ្វេ កុសលា អកុសលោ ច

ទ្វេ យោនិសោ ច ពោជ្ឈា ច

អវារណា(១) អបរិហានិ

នីវរណាវរណា ទ្វេ

ឧប្បាទនា ច តេ ទសាតិ ។

---

១ ម. ឱ. អាវារណា ។





## ឧទ្ទាននៃនីវរណវគ្គនោះគឺ

និយាយអំពីកុសលមាន ២ លើក អំពីអកុសល ១ អំពីអយោនិសោមនសិការៈនិងយោនិសោមនសិការៈ ២ លើក អំពីពោជ្ឈង្គទាំង ៧ ប្រព្រឹត្តទៅដើម្បីសេចក្តីចំរើន ១ អំពីពោជ្ឈង្គទាំង ៧ មិនមែនជាគ្រឿងរាំង ១ អំពីអបរិហានិយធម៌ ១ អំពីធម៌ជាគ្រឿងបិទបាំង និងធម៌ជាគ្រឿងរាំង ប្រែបន្ទូរដើម្បីញាណ ១ អំពីនីវរណធម៌ ១ រួមទាំងអស់ជា ១០ ។

## ចក្កវត្តិវគ្គោ

(៥០៣) សាវត្ថីនិទានំ ។ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា តិស្សោ វិធា បជហឹសុ សព្វេ តេ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា តិស្សោ វិធា បជហិស្សន្តិ សព្វេ តេ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា តិស្សោ វិធា បជហន្តិ សព្វេ តេ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា ។

## ចក្កវត្តិវគ្គ

(៥០៣) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលកន្លងទៅហើយជាយូរអង្វែង បានលះបង់នូវមានះទាំង ៣ ប្រការចេញបាន ព្រោះសមណៈឬព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកចំរើន ជាអ្នកធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអនាគត នឹងលះបង់នូវមានះទាំង ៣ ប្រការចេញបាន ព្រោះសមណៈឬព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកចំរើន ជាអ្នកធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដែលមានក្នុងកាលឥឡូវនេះ រមែងលះបង់នូវមានះទាំង ៣ ប្រការចេញបាន ព្រោះសមណៈឬព្រាហ្មណ៍ទាំងអស់នោះ ក៏ជាអ្នកចំរើន ជាអ្នកធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ដែរ ។

(៨០៦) កតមេសំ សត្តន្នំ ពោជ្ឈង្គានំ ។ សតិសម្ពោជ្ឈង្គស្ស ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា តិស្សោ វិធា បជហឹសុ ។បេ។ បជហិស្សន្តិ ។បេ។ បជហន្តិ សព្វេ តេ ឥមេសំ យេវ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា ។

(៨០៧) រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស បាតុភាវា សត្តន្នំ រតនានំ បាតុភាវោ ហោតិ ។ កតមេសំ សត្តន្នំ ។ ចក្ករតនស្ស បាតុភាវោ ហោតិ ហត្ថិរតនស្ស បាតុភាវោ ហោតិ អស្សរតនស្ស បាតុភាវោ ហោតិ មណិរតនស្ស បាតុភាវោ ហោតិ ឥត្ថីរតនស្ស បាតុភាវោ ហោតិ គហបតិរតនស្ស បាតុភាវោ ហោតិ បរិណាយករតនស្ស បាតុភាវោ ហោតិ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស បាតុភាវា ឥមេសំ សត្តន្នំ រតនានំ បាតុភាវោ ហោតិ ។





(៨០៦) ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលកន្លងទៅហើយជាយូរអង្វែង បានលះបង់នូវមានះទាំង ៣ ប្រការចេញបាន ។បេ។ នឹងលះបង់ ។បេ។ កំពុងលះបង់ ព្រោះពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកចំរើន ជាអ្នកធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះឯង ។

(៨០៧) ម្នាលភិក្ខុទាំងឡាយ ការកើតឡើងប្រាកដនៃរតនៈទាំង ៧ ព្រោះការកើតប្រាកដនៃស្តេចចក្រពត្តិ ។ រតនៈទាំង ៧ គឺអ្វីខ្លះ ។ គឺការកើតប្រាកដនៃចក្ររតន៍ (ចក្រកែវ) ១ ការកើតប្រាកដនៃហត្ថិរតន៍ (ដំរីកែវ) ១ ការកើតប្រាកដនៃអស្សរតន៍ (សេះកែវ) ១ ការកើតប្រាកដនៃមណិរតន៍ (កែវមណី) ១ ការកើតប្រាកដនៃឥត្ថីរតន៍ (ស្រីកែវ) ១ ការកើតប្រាកដនៃគហបតិរតន៍ (គហបតីកែវ) ១ ការកើតប្រាកដនៃបរិនាយករតន៍ (នាយឃុំនីកែវ) ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃរតនៈទាំង ៧ នេះ ព្រោះការកើតប្រាកដនៃស្តេចចក្រពត្តិ ។

(៩០៦) តថាគតស្ស ភិក្ខវេ បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្ស សត្តន្នំ ពោជ្ឈង្គរតនានំ បាតុភាវោ ហោតិ ។ កតមេសំ សត្តន្នំ ពោជ្ឈង្គរតនានំ ។ សតិសម្ពោជ្ឈង្គរតនស្ស បាតុភាវោ ហោតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គរតនស្ស បាតុភាវោ ហោតិ ។ តថាគតស្ស ភិក្ខវេ បាតុភាវា អរហតោ សម្មាសម្ពុទ្ធស្ស ឥមេសំ សត្តន្នំ ពោជ្ឈង្គរតនានំ បាតុភាវោ ហោតីតិ ។

(៩០៧) មារសេនប្បមទ្ទនំ វោ ភិក្ខវេ មគ្គំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ មារសេនប្បមទ្ទនោ មគ្គោ ។ យទិទំ សត្ត ពោជ្ឈង្គា ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ អយំ ភិក្ខវេ មារសេនប្បមទ្ទនោ មគ្គោតិ ។



(៩០៦) ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃពោជ្ឈង្គរតនៈទាំង ៧ ព្រោះការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។ ពោជ្ឈង្គរតនៈទាំង ៧ គឺអ្វីខ្លះ ។ គឺការកើតប្រាកដនៃសតិសម្ពោជ្ឈង្គរតនៈ ១ ។បេ។ ការកើតប្រាកដនៃឧបេក្ខាសម្ពោជ្ឈង្គរតនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃពោជ្ឈង្គរតនៈទាំង ៧ នេះ ព្រោះការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។

(៩០៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវមគ្គជាគ្រឿងញាំញីនូវពួកសេនារបស់មារ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដែលជាគ្រឿងញាំញីពួកសេនានៃមារ តើដូចម្តេច ។ គឺពោជ្ឈង្គទាំង ៧ នេះឯង ។ ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាមគ្គជាគ្រឿងញាំញីពួកសេនានៃមារ ។

[៨០៨] សាវត្ថីនិទានំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ទុប្បញ្ញោ ឯឡមូគោ ទុប្បញ្ញោ ឯឡមូគោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ទុប្បញ្ញោ ឯឡមូគោតិ វុច្ចតីតិ ។

[៨០៩] សត្តន្នំ ខោ ភិក្ខុ ពោជ្ឈង្គានំ អភាវិតត្តា អពហុលីកតត្តា ទុប្បញ្ញោ ឯឡមូគោតិ វុច្ចតិ ។ កតមេសំ សត្តន្នំ ។ សតិសម្ពោជ្ឈង្គស្ស ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស ។ ឥមេសំ ខោ ភិក្ខុ សត្តន្នំ ពោជ្ឈង្គានំ អភាវិតត្តា អពហុលីកតត្តា ទុប្បញ្ញោ ឯឡមូគោតិ វុច្ចតីតិ ។

[៨១០] សាវត្ថីនិទានំ ។ បញ្ញវា អនេឡមូគោ បញ្ញវា អនេឡមូគោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ បញ្ញវា អនេឡមូគោតិ វុច្ចតីតិ ។



[៨០៨] សាវត្ថីនិទាន ។ គ្រានោះឯង ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យគេតែងនិយាយថា មនុស្សឥតប្រាជ្ញាល្ងង់ខ្លៅ មនុស្សឥតប្រាជ្ញាល្ងង់ខ្លៅ បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា មនុស្សឥតប្រាជ្ញាល្ងង់ខ្លៅ តើដោយហេតុដូចម្តេច ។

[៨០៩] ម្នាលភិក្ខុ ដែលហៅថា មនុស្សឥតប្រាជ្ញាល្ងង់ខ្លៅ ព្រោះមិនបានចំរើន មិនបានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ។ ពោជ្ឈង្គទាំង ៧ គឺអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុ ដែលហៅថា មនុស្សឥតប្រាជ្ញាល្ងង់ខ្លៅ ព្រោះមិនបានចំរើន មិនបានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះឯង ។

[៨១០] សាវត្ថីនិទាន ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យគេតែងនិយាយថា មនុស្សមានប្រាជ្ញាមិនល្ងង់ខ្លៅ មនុស្សមានប្រាជ្ញាមិនល្ងង់ខ្លៅ បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា មនុស្សមានប្រាជ្ញាមិនល្ងង់ខ្លៅ តើដូចម្តេច ។

[៨១១] សត្តន្នំ ខោ ភិក្ខុ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា បញ្ញោ អនេឡមូគោតិ វុច្ចតិ ។ កតមេសំ សត្តន្នំ ។ សតិសម្ពោជ្ឈង្គស្ស ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស ។ ឥមេសំ ខោ ភិក្ខុ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា បញ្ញោ អនេឡមូគោតិ វុច្ចតីតិ ។

[៨១២] សាវត្ថីនិទានំ ។ ទលិទ្ទោ ទលិទ្ទោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ទលិទ្ទោតិ វុច្ចតីតិ ។

[៨១៣] សត្តន្នំ ខោ ភិក្ខុ ពោជ្ឈង្គានំ អភាវិតត្តា អពហុលីកតត្តា ទលិទ្ទោតិ វុច្ចតិ ។ កតមេសំ សត្តន្នំ ។ សតិសម្ពោជ្ឈង្គស្ស ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស ។ ឥមេសំ ខោ ភិក្ខុ សត្តន្នំ ពោជ្ឈង្គានំ អភាវិតត្តា អពហុលីកតត្តា ទលិទ្ទោតិ វុច្ចតីតិ ។

[៨១៤] សាវត្ថីនិទានំ ។ អទលិទ្ទោ អទលិទ្ទោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ អទលិទ្ទោតិ វុច្ចតីតិ ។



[៨១១] ម្នាលភិក្ខុ ដែលហៅថា មនុស្សមានប្រាជ្ញាមិនល្ងង់ទៅ ព្រោះបានចំរើន បានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុ ដែលហៅថា មនុស្សមានប្រាជ្ញាមិនល្ងង់ទៅ ព្រោះបានចំរើន បានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះឯង ។

[៨១២] សាវត្ថីនិទាន ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលនិយាយថា មនុស្សកំសត់ មនុស្សកំសត់ បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា មនុស្សកំសត់ តើដោយហេតុដូចម្តេច ។

[៨១៣] ម្នាលភិក្ខុ ដែលហៅថា មនុស្សកំសត់ ព្រោះមិនបានចំរើន មិនបានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុ ដែលហៅថា មនុស្សកំសត់ ព្រោះមិនបានចំរើន មិនបានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះឯង ។

[៨១៤] សាវត្ថីនិទាន ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលនិយាយថា មនុស្សមិនកំសត់ មនុស្សមិនកំសត់ បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា មនុស្សមិនកំសត់ តើដោយហេតុដូចម្តេច ។

(៨០៥) សត្តន្នំ ខោ ភិក្ខុ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា អទលិទ្ទោតិ វុច្ចតិ ។ កតមេសំ សត្តន្នំ ។ សតិសម្ពោជ្ឈង្គស្ស ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គស្ស ។ ឥមេសំ ខោ ភិក្ខុ សត្តន្នំ ពោជ្ឈង្គានំ ភាវិតត្តា ពហុលីកតត្តា អទលិទ្ទោតិ វុច្ចតីតិ ។

(៨០៦) សាវត្ថីនិទានំ ។ អាទិច្ចស្ស ភិក្ខវេ ឧទយតោ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ អរុណុគ្គំ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ សត្តន្នំ ពោជ្ឈង្គានំ ឧប្បាទាយ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ កល្យាណមិត្តតា ។ កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីករិស្សតិ ។

(៨០៧) កថញ្ច ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។





(៨០៥) ម្នាលភិក្ខុ ដែលហៅថា មនុស្សមិនកំសត់ ព្រោះបានចំរើន បានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ ។ ពោជ្ឈង្គទាំង ៧ តើអ្វីខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុ ដែលហៅថា មនុស្សមិនកំសត់ ព្រោះបានចំរើន បានធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះឯង ។

(៨០៦) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្ត នៃព្រះអាទិត្យដែលកើតឡើង ការនៃកល្យាណមិត្តនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្ត នៃកិរិយាកើតឡើងនៃពោជ្ឈង្គទាំង ៧ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាគ្រឿងប្រាកដដល់ភិក្ខុដែលមានកល្យាណមិត្ត ភិក្ខុនោះនឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ ។

(៨០៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលមានមិត្រល្អ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។

(៥០៨) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ សត្តន្នំ ពោជ្ឈង្គានំ ឧប្បាទាយ យថយិទំ ភិក្ខវេ យោនិសោមនសិការោ ។ យោនិសោមនសិការសម្បន្នស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីករិស្សតិ ។

(៥០៩) កថញ្ច ភិក្ខវេ ភិក្ខុ យោនិសោមនសិការសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ



ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក ។បេ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានមិត្តល្អ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

(៥០៨) ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើធម៌ខាងក្នុងឲ្យជាអង្គហើយ ក៏មិនឃើញធម៌ដទៃ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅដើម្បីធ្វើពោជ្ឈង្គទាំង ៧ ឲ្យកើតឡើងបាន ដូចជាយោនិសោមនសិការៈនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាគ្រឿងប្រាកដដល់ភិក្ខុដែលបរិបូណ៌ដោយយោនិសោមនសិការៈ ភិក្ខុនោះនឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ ។

(៥០៩) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ដោយយោ-និសោមនសិការៈ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក ។បេ។ ចំរើននូវឧបេក្ខា-សម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ

វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យោនិសោមនសិការសម្បន្នោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។

(៤៦០) ពាហិរំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ សត្តន្នំ ពោជ្ឈង្គានំ ឧប្បាទាយ យទិទំ ភិក្ខវេ កល្យាណមិត្តតា ។ កល្យាណមិត្តស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ សត្ត ពោជ្ឈង្គេ ភាវេស្សតិ សត្ត ពោជ្ឈង្គេ ពហុលីករិស្សតិ ។

(៤៦១) កថញ្ច ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ សត្ត ពោជ្ឈង្គេ ភាវេតិ សត្ត ពោជ្ឈង្គេ ពហុលីករោតីតិ ។





បរិណាមទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយយោនិសោមនសិការៈ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

(៤៦០) ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើអង្គខាងក្រៅ ឲ្យជាអង្គហើយ ក៏មិនឃើញអង្គធម៌ដទៃ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅដើម្បីកើតឡើងនៃពោជ្ឈង្គទាំង ៧ បាន ដូចជាការមានមិត្រល្អនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាគ្រឿងប្រាថ្នាដល់ភិក្ខុដែលមានមិត្រល្អ ភិក្ខុនោះនឹងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ ។

(៤៦១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានមិត្រល្អ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក ។បេ។ ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគៈ អាស្រ័យនូវនិរោធ បរិណាមទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានមិត្រល្អ រមែងចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ យ៉ាងនេះឯង ។

## តស្សុទ្ទានំ

វិជា ចក្កវត្តិ មហោ ច

ទុប្បញ្ញោ បញ្ញវេន ច

ឧទ្រិន្នោ អឧទ្រិន្នោ ច

អាធិន្នោ អវេទ្ធន តេ ទសាទេ ។



## ឧទ្ទានដែលបក្សត្តិវគ្គនោះគឺ

និយាយអំពីការលះបង់មាន ៣ ប្រការ ១ អំពីសេចក្តីប្រៀប ដោយស្តេចចក្រពត្តិ ១ អំពីបព្វជាគ្រឿងញ៉ាំញ៉ីមានទឹកសោ នៃហា ១ អំពីការប្រៀបដោយមនុស្សឥតប្រាជ្ញា ១ ដោយ មនុស្សមានប្រាជ្ញា ១ ដោយមនុស្សក្រំសត់ ១ ដោយមនុស្ស មិនក្រំសត់ ១ ដោយក្រោកពីវត្សុះឡើង ១ អំពីធម៌ជាអន្តរាយ ពីរលើក រួមជា ១០ ។

[៤៦២] សាវត្ថីនិទានំ ។ បញ្ចន្នញ្ច ភិក្ខវេ នីវរណានំ សត្តន្នញ្ច ពោជ្ឈង្គានំ អាហារញ្ច អនាហារញ្ច ទេសិស្សាមិ តំ សុណាថ ។

[៤៦៣] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ សុភនិមិត្តំ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។

[៤៦៤] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ បដិឃនិមិត្តំ តត្ថ អយោនិសោមនសិការពហុលីការោ



(៤៦២) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម៌ជាអាហារ នឹងធម៌មិនមែនជាអាហារ នៃនីវរណៈទាំង ៥ផង នៃពោជ្ឈង្គទាំង ៧ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះចុះ ។

(៤៦៣) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់កាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានសុភនិមិត្ត ឯការធ្វើឲ្យច្រើននូវអយោនិសោមនសិការក្នុងសុភនិមិត្តនោះ នេះធម៌ជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើង ឬរបស់កាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៤៦៤) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់ព្យាបាទដែលកើតឡើងហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានបដិឃនិមិត្ត ឯការធ្វើឲ្យច្រើននូវអយោនិសោមនសិការឲ្យច្រើនក្នុងបដិឃនិមិត្តនោះ

អយមាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។

(៤៦៥) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ អរតិ តន្ទិ វិជម្ភិតា ភត្តសម្មទោ ចេតសោ ច លីនត្តំ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។

(៤៦៦) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ ចេតសោ អវូបសមោ តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។



នេះឯងជាអាហាររបស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទដែលកើតឡើងហើយ ឲ្យចំរើនតែកើតច្រើនឡើង ។

(៤៦៥) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់ថីនមិទ្ធៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យចំរើនតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនត្រេកអរ ខ្ជិល មិនតក់កាយ ពុលបាយ រួញរាចិត្ត ធ្វើការធ្វើទុកដោយអយោនិសោមនសិការឲ្យច្រើនក្នុងសេចក្តីមិនត្រេកអរជាដើមនោះ នេះឯងជាអាហាររបស់ថីនមិទ្ធៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យចំរើនតែកើតច្រើនឡើង ។

(៤៦៦) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់ឧទ្ធច្ចកុក្កុច្ច ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយ ឲ្យចំរើនតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែការមិនស្ងប់ស្ងាត់ចិត្ត ធ្វើការធ្វើទុកដោយអយោនិសោមនសិការឲ្យច្រើនក្នុងការមិនស្ងប់ស្ងាត់ចិត្តនោះ នេះឯងជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយ ឲ្យចំរើនតែកើតច្រើនឡើង ។

(៤២៧) កោ ច ភិក្ខវេ អាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ វិចិកិច្ឆដ្ឋានិយា ធម្មា តត្ថ អយោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។

(៤២៨) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



(៤២៧) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់វិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយ ដែលបណ្តាលឲ្យកើតវិចិកិច្ឆា នឹងការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៤២៨) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់សតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយដែលតាំងឲ្យកើតសតិសម្ពោជ្ឈង្គ នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់សតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យចំរើនបរិបូណ៌ ។

[៤៦៩] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កុសលាកុសលា ធម្មា សាវជ្ជានវជ្ជា ធម្មា ហីនប្បណីតា ធម្មា កណ្ហសុក្កសប្បដិភាគា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

[៤៧០] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



[៤៦៩] ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់ធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសលឬអកុសល ពួកធម៌ប្រកបដោយទោសឬឥតទោស ពួកធម៌ថោកទាបឬថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅឬស នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហាររបស់ធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

[៤៧០] ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់វីរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វីរិយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតាំងផ្តើម ការខ្នះខ្នែង ការប្រឹងប្រែង នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងសេចក្តីតាំងផ្តើមជាដើមនោះ នេះជាអាហាររបស់វីរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វីរិយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

[៤៣១] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ បីតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

[៤៣២] កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កាយប្បស្សទ្ធិ ចិត្តប្បស្សទ្ធិ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



(៤៣១) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់បីតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយដែលតាំងឲ្យកើតបីតិសម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់បីតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៤៣២) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់នោះ នេះធម៌ជាអាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៣៣) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សមាធិនិមិត្តំ[១] អព្យគ្គនិមិត្តំ តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៥៣៤) កោ ច ភិក្ខវេ អាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ ឧបេក្ខាសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

---

១ ឱ. ម. សមថនិមិត្តំ ។



(៥៣៣) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់សមាធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានតែសមាធិនិមិត្ត អព្យគ្គនិមិត្ត នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងនិមិត្តទាំងនោះ នេះធម៌ជាអាហាររបស់សមាធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៣៤) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីជាអាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ដែលតាំងឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៣៥) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ អសុភនិមិត្តំ តត្ថ យោនិសោមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា កាមច្ឆន្ទស្ស ឧប្បាទាយ ឧប្បន្នស្ស វា កាមច្ឆន្ទស្ស ភិយ្យោភាវាយ វេបុល្លាយ ។

(៥៣៦) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ ចេតោវិមុត្តិ[១] តត្ថ យោនិសោមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា ព្យាបាទស្ស ឧប្បាទាយ ឧប្បន្នស្ស វា ព្យាបាទស្ស ភិយ្យោភាវាយ វេបុល្លាយ ។

---

១ ម. ឱ. មេត្តាចេតោវិមុត្តិ ។



(៥៣៥) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីមិនមែនជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់កាមច្ឆន្ទៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែអសុភនិមិត្ត នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងអសុភនិមិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់កាមច្ឆន្ទៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៥៣៦) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហាររបស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់ព្យាបាទដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែចេតោវិមុត្តិ នឹងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងចេតោវិមុត្តិនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់ព្យាបាទដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៤៣៧) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ តត្ថ យោនិសោមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា ថីនមិទ្ធស្ស ឧប្បាទាយ ឧប្បន្នស្ស វា ថីនមិទ្ធស្ស ភិយ្យោភាវាយ វេបុល្លាយ ។

(៤៣៨) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ ចេតសោ វូបសមោ តត្ថ យោនិសោមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧទ្ធច្ចកុក្កុច្ចស្ស ភិយ្យោភាវាយ វេបុល្លាយ ។



(៤៣៧) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់ថីនមិទ្ធៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែការតាំងផ្តើម ការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការតាំងផ្តើមជាដើមនោះ នេះធម៌មិនមែនជាអាហាររបស់ថីនមិទ្ធៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៤៣៨) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៨៣៩) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។ អត្ថិ ភិក្ខវេ កុសលាកុសលា ធម្មា សាវជ្ជានវជ្ជា ធម្មា ហីនប្បណីតា ធម្មា កណ្ហសុក្កសប្បដិភាគា ធម្មា តត្ថ យោនិសោមនសិការពហុលីការោ អយមនាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយ ។

(៨៤០) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។





(៨៣៩) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីមិនមែនជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសលនិងអកុសល ពួកធម៌ដែលប្រកបដោយទោសនិងឥតទោស ពួកធម៌ដែលថោកទាបនិងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅនិងស នឹងការធ្វើទុកយោនិសោមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹតតែកើតច្រើនឡើង ។

(៨៤០) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហាររបស់សតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានតែពួកធម៌ជាទីតាំងរបស់សតិសម្ពោជ្ឈង្គ នឹងការធ្វើទុកអមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់សតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៤៦១) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កុសលាកុសលា ធម្មា សាវជ្ជានវជ្ជា ធម្មា ហីនប្បណីតា ធម្មា កណ្ហសុក្កសប្បដិភាគា ធម្មា តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៤៦២) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា វិរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វិរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្ប-ន្នស្ស វា វិរិយសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា វិរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។



(៤៦១) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់ធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំង-ឡាយ មានតែពួកធម៌ជាកុសលនិងអកុសល ពួកធម៌ដែលប្រកបដោយទោសនិងឥតទោស ពួកធម៌ដែលថោកទាបនិងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅនិងស ឯការធ្វើទុកអមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់ធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៤៦២) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីមិនមែនជាអាហាររបស់វិរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិរិយ-សម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានការតាំងផ្តើម ការខ្នះខ្នែង ការប្រឹងប្រែង ការធ្វើទុកអមនសិការឲ្យច្រើន ក្នុងការតាំងផ្តើមជាដើមនោះ នេះធម៌មិនមែនជាអាហាររបស់វិរិយ-សម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិរិយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៦៣) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ បីតិសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៥៦៤) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ កាយប្បស្សទ្ធិ ចិត្តប្បស្សទ្ធិ តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។





(៥៦៣) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់បីតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានតែពួកធម៌ដែលតាំងឲ្យកើតបីតិសម្ពោជ្ឈង្គ មិនការធ្វើនូវមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់បីតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៦៤) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់បស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត មិនការធ្វើនូវមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៤៥) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ សមាធិនិមិត្តំ អព្យគ្គនិមិត្តំ តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។

(៥៤៦) កោ ច ភិក្ខវេ អនាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយា ។ អត្ថិ ភិក្ខវេ ឧបេក្ខាសម្ពោជ្ឈង្គដ្ឋានិយា ធម្មា តត្ថ អមនសិការពហុលីការោ អយមនាហារោ អនុប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទាយ ឧប្បន្នស្ស វា ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរិយាតិ ។



(៥៤៥) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់សមាធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានតែសមាធិនិមិត្ត អព្យគ្គនិមិត្ត ឥតការធ្វើឲ្យមនសិការឲ្យច្រើន ក្នុងនិមិត្តទាំងនោះ នេះធម៌មិនមែនជាអាហាររបស់សមាធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៤៦) ម្នាលភិក្ខុទាំងឡាយ ចុះធម៌អ្វីដែលមិនមែនជាអាហារ របស់ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ដែលតាំងឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ឥតការធ្វើឲ្យមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងផង ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចំរើនបរិបូណ៌ ។

(៥៦៧) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិំសុ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។ អថខោ តេ ភិក្ខូ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិំសុ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធិំ សម្មោទិំសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សមណោ អាវុសោ គោតមោ សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេថាតិ ។



(៥៦៧) លំដាប់នោះឯង ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ រួចចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ ទើបពួកភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា (ឥឡូវនេះ) យើងនឹងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីទៅ ហាក់ដូចជានៅព្រឹកពេក បើដូច្នោះពួកយើងនឹងចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយសិនចុះ ។ ហើយពួកភិក្ខុទាំងនោះចូលទៅឯអារាមរបស់បរិព្វាជកជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះនិយាយដូច្នេះថា ម្នាលអាវុសោទាំងឡាយ សមណគោតមតែងសំដែងធម៌ដល់សាវកទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមកណេះ ចូរអ្នកទាំងឡាយលះបង់នីវរណធម៌ទាំង ៥ ជាឧបក្កិលេសនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ រួចហើយចំរើនពោជ្ឈង្គទាំង ៧ ឲ្យកើតមានឡើង ។

មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេថាតិ ។ ឥធ នោ អាវុសោ កោ វិសេ-សោ កោ អធិប្បាយាសោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ(១) ។

(៥៤៨) អថខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោ-សឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។

១ ម. ឧ. អនុសាសនិន្តិ ។



ម្នាលអាវុសោទាំងឡាយ សូម្បីយើងក៏សំដែងធម៌ប្រាប់សាវកទាំងឡាយ យ៉ាងនេះថា នែអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមកណេះ ចូរអ្នកទាំងឡាយលះបង់នីវរណធម៌ទាំង ៥ ជាឧបក្កិលេសនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកំឡាំងថយ រួចហើយចំរើនពោជ្ឈង្គទាំង ៧ ឲ្យកើតមានឡើងដូច្នេះដែរ ។ ម្នាលអាវុសោទាំងឡាយ ចុះក្នុងរឿងនេះ តើមានសេចក្តីប្លែកគ្នាដូចម្តេច មានសេចក្តីអធិប្បាយដូចម្តេច មានអំពើផ្សេងគ្នាដូចម្តេច របស់ព្រះសមណគោតមក្តី របស់យើងក្តី អំពីដំណើរប្រៀបធម៌ទេសនានឹងធម៌ទេសនា ប្រៀបពាក្យប្រៀនប្រដៅនឹងពាក្យប្រៀនប្រដៅ ។

(៥៤៨) លំដាប់នោះ ភិក្ខុទាំងនោះមិនត្រេកអរ មិនឃាត់ឃាំងភាសិតរបស់បរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះមិនត្រេកអរ មិនឃាត់ឃាំងហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ហើយនិយាយគ្នាថា យើងគប្បីដឹងច្បាស់សេចក្តីនៃភាសិតនោះ ក្នុងសំណាក់នៃព្រះដ៏មានបុណ្យជាម្ចាស់ ។

(៥៤៩) អថខោ សោ ភិក្ខុ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធ មយំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិម្ហ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្ពាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។ អថខោ មយំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្ពាជកានំ អារាមោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្ពាជកេហិ សទ្ធិំ សម្មោទិម្ហ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិម្ហ ។ ឯកមន្តំ និសិន្នេ ខោ អម្ហេ ភន្តេ តេ អញ្ញតិត្ថិយា បរិព្ពាជកា ឯតទវោចុំ សមណោ អាវុសោ គោតមោ



(៥៤៩) លំដាប់នោះឯង ភិក្ខុរូបនោះចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុរូបនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងថ្ងៃនេះ ពួកខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គរូបនោះមានសេចក្តីត្រិះរិះដូច្នេះថា (ឥឡូវនេះ) ពួកយើងនឹងទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីនៅហាក់ដូចជានៅព្រឹកពេក បើដូច្នោះ ពួកយើងនឹងចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយសិនចុះ ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ពួកខ្ញុំព្រះអង្គក៏បាននាំគ្នាចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រះអង្គដ៏ចំរើន លុះពួកខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ទើបពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះនិយាយដូច្នេះថា ម្នាលអាវុសោទាំងឡាយ សមណគោតម

សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេថាតិ ។ មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេថាតិ ។ ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយសោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។

[៥៥០] អថខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោសឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។



តែងសំដែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកណេះ ចូរអ្នកទាំងឡាយលះបង់នូវនីវរណធម៌ ៥ ជាឧបក្កិលេសនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ចំរើនពោជ្ឈង្គ ៧ ឲ្យកើតមានឡើង ។ ម្នាលអាវុសោទាំងឡាយ សូម្បីយើងក៏តែងសំដែងធម៌ប្រាប់សាវកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមកអាយ ចូរអ្នកទាំងឡាយលះបង់នូវនីវរណធម៌ ៥ ជាឧបក្កិលេសនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកំឡាំងថយ ចំរើននូវពោជ្ឈង្គ ៧ ឲ្យកើតមានឡើងដែរ ។ ម្នាលអាវុសោទាំងឡាយ ចុះក្នុងដំណើរនេះ តើមានសេចក្តីប្លែកគ្នាដូចម្តេច មានសេចក្តីអធិប្បាយដូចម្តេច មានអំពើផ្សេងគ្នាដូចម្តេច របស់ព្រះសមណគោតមនឹងរបស់យើងអំពីដំណើរធម៌ទេសនានឹងធម៌ទេសនា ពាក្យប្រៀនប្រដៅនឹងពាក្យប្រៀនប្រដៅ ។

[៥៥០] សូមទ្រង់ព្រះមេត្តាប្រោស វេលានោះ ពួកខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ឃាំងភាសិតរបស់បរិព្វាជកជាអន្យតិរ្ថិយទាំងនោះទេ លុះមិនត្រេកអរ មិនបានឃាត់ឃាំងហើយ ក៏ក្រោកចាកអាសនៈដើរចេញមក ដោយគិតថា ពួកយើងនឹងយល់សេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគមិនខាន ។

[៥៥១] ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា អត្ថិ បនាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម បញ្ច នីវរណា ទស ហោន្តិ សត្ត ពោជ្ឈង្គា ចតុទ្ទសាតិ ។ ឯវំ បុដ្ឋា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ន ចេវ សម្បាយិស្សន្តិ ឧត្តរិញ្ច វិឃាតំ អាបជ្ជិស្សន្តិ ។ តំ កិស្ស ហេតុ ។ យថា តំ ភិក្ខវេ អវិសយស្មឹ ។ នាហន្តំ ភិក្ខវេ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វា ។

[៥៥២] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម បញ្ច នីវរណា ទស ហោន្តិ ។



(៥៥១) ម្នាលភិក្ខុទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវសួរយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ចុះហេតុដែលនាំឲ្យនីវរណៈ ៥ ហែកទៅជា ១០ ពោជ្ឈង្គ ៧ ហែកទៅជា ១៤ តើមានឬទេ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយសួរយ៉ាងនេះ ពួកបរិព្វាជកជាអន្យតិរ្ថិយ មុខជាឆ្លើយមិនរួចផង នឹងដល់នូវសេចក្តីចង្អៀតចង្អល់ចិត្តតទៅទៀតផង ។ ចុះដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាដំណើរនោះមិនមែនជាវិស័យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាដែលគួរដោះស្រាយប្រស្នាទាំងនេះឲ្យពេញចិត្តបាន លើកតែព្រះតថាគតឬសាវករបស់ព្រះតថាគត ឬក៏បុគ្គលដែលបានស្តាប់អំពីសាវករបស់ព្រះតថាគតចេញ ។

(៥៥២) ម្នាលភិក្ខុទាំងឡាយ ចុះហេតុដូចម្តេច ដែលនាំឲ្យនីវរណៈ ៥ ហែកទៅជា ១០ ។

(៤៤៣) យទបិ ភិក្ខវេ អជ្ឈត្តំ កាមច្ឆន្ទោ តទបិ នីវរណំ យទបិ ពហិទ្ធា កាមច្ឆន្ទោ តទបិ នីវរណំ កាមច្ឆន្ទនីវរណន្តិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៤៤៤) យទបិ ភិក្ខវេ អជ្ឈត្តំ ព្យាបាទោ តទបិ នីវរណំ យទបិ ពហិទ្ធា ព្យាបាទោ តទបិ នីវរណំ ព្យាបាទនីវរណន្តិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៤៤៥) យទបិ ភិក្ខវេ ថីនំ តទបិ នីវរណំ យទបិ មិទ្ធំ តទបិ នីវរណំ ថីនមិទ្ធនីវរណន្តិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៤៤៦) យទបិ ភិក្ខវេ ឧទ្ធច្ចំ តទបិ នីវរណំ យទបិ កុក្កុច្ចំ តទបិ នីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណន្តិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។



(៤៤៣) ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈណាជាខាងក្នុង កាមច្ឆន្ទៈនោះជានីវរណៈ ១ កាមច្ឆន្ទៈណាជាខាងក្រៅ កាមច្ឆន្ទៈនោះជានីវរណៈ ១ ព្រោះជាកាមច្ឆន្ទនីវរណៈនេះ តែងមកកាន់ទីឧទ្ទេសដោយប្រការដូច្នេះ ។ នីវរណៈនោះមានចំណែក ២ ដោយហេតុនោះឯង ។

(៤៤៤) ម្នាលភិក្ខុទាំងឡាយ ព្យាបាទណាជាខាងក្នុង ព្យាបាទនោះជានីវរណៈ ១ ព្យាបាទណាជាខាងក្រៅ ព្យាបាទនោះជានីវរណៈ ១ ព្រោះជាព្យាបាទនីវរណៈនេះ តែងមកកាន់ទីឧទ្ទេសដោយប្រការដូច្នេះ ។ នីវរណៈនោះមានចំណែក ២ ដោយហេតុនេះឯង ។

(៤៤៥) ម្នាលភិក្ខុទាំងឡាយ ថីនៈណា ថីនៈនោះជានីវរណៈ ១ មិទ្ធៈណា មិទ្ធៈនោះជានីវរណៈ ១ ព្រោះជាថីនមិទ្ធនីវរណៈនេះ តែងមកកាន់ទីឧទ្ទេសដោយប្រការដូច្នេះ ។ នីវរណៈនោះមានចំណែក ២ ដោយហេតុនេះឯង ។

(៤៤៦) ម្នាលភិក្ខុទាំងឡាយ ឧទ្ធច្ចៈណា ឧទ្ធច្ចៈនោះជានីវរណៈ ១ កុក្កុច្ចៈណា កុក្កុច្ចៈនោះជានីវរណៈ ១ ព្រោះជាឧទ្ធច្ចកុក្កុច្ចនីវរណៈនេះ តែងមកកាន់ទីឧទ្ទេសដោយប្រការដូច្នេះ ។ នីវរណៈនោះមានចំណែក ២ ដោយហេតុនេះឯង ។

(៥៥៧) យទបិ ភិក្ខវេ អជ្ឈត្តំ ធម្មេសុ វិចិកិច្ឆា តទបិ នីវរណំ យទបិ ពហិទ្ធា ធម្មេសុ វិចិកិច្ឆា តទបិ នីវរណំ វិចិកិច្ឆានីវរណន្តិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៥៥៨) អយំ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម បញ្ច នីវរណា ទស ហោន្តិ[១] ។

(៥៥៩) កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សត្ត ពោជ្ឈង្គា ចុទ្ទស ហោន្តិ ។

(៥៦០) យទបិ ភិក្ខវេ អជ្ឈត្តំ ធម្មេសុ សតិ តទបិ សតិសម្ពោជ្ឈង្គោ យទបិ ពហិទ្ធា ធម្មេសុ សតិ តទបិ សតិសម្ពោជ្ឈង្គោ សតិសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ អាគច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

---

១ ម. អយំ ខោ ភិក្ខវេ ។ បេ ។ ទស ហោន្តិ សត្ត ចុទ្ទស ហោន្តិ ។



(៥៥៧) ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាណា ក្នុងធម៌ទាំងឡាយជាខាងក្នុង វិចិកិច្ឆានោះជានីវរណៈ១ វិចិកិច្ឆាណា ក្នុងធម៌ទាំងឡាយជាខាងក្រៅ វិចិកិច្ឆានោះជានីវរណៈ១ ព្រោះថាវិចិកិច្ឆានីវរណៈនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ នីវរណៈនោះមានចំណែក ២ ដោយហេតុនេះឯង ។

(៥៥៨) ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុនាំឲ្យនីវរណៈ ៥ ចែកទៅជា ១០ ។

(៥៥៩) ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឲ្យពោជ្ឈង្គ ៧ ចែកទៅជា ១៤ តើដូចម្តេច ។

(៥៦០) ម្នាលភិក្ខុទាំងឡាយ សតិណា ក្នុងធម៌ទាំងឡាយជាខាងក្នុង សតិនោះឯង ជាសតិសម្ពោជ្ឈង្គ១ សតិណា ក្នុងធម៌ទាំងឡាយជាខាងក្រៅ សតិនោះឯង ជាសតិសម្ពោជ្ឈង្គ១ ព្រោះថាសតិសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ សតិសម្ពោជ្ឈង្គនោះមានចំណែក ២ ដោយហេតុនេះឯង ។

[៤៦១] យទបិ ភិក្ខវេ អជ្ឈត្តំ ធម្មេសុ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ តទបិ ធម្មវិចយសម្ពោជ្ឈង្គោ យទបិ ពហិទ្ធា ធម្មេសុ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ តទបិ ធម្មវិចយសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

[៤៦២] យទបិ ភិក្ខវេ កាយិកំ វីរិយំ តទបិ វីរិយសម្ពោជ្ឈង្គោ យទបិ ចេតសិកំ វីរិយំ តទបិ វីរិយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

[៤៦៣] យទបិ ភិក្ខវេ សវិតក្កសវិចារា បីតិ តទបិ បីតិសម្ពោជ្ឈង្គោ យទបិ អវិតក្កាវិចារា បីតិ តទបិ បីតិសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។



[៤៦១] ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រិះរិះពិចារណាដោយប្រាជ្ញាក្នុងធម៌ទាំងឡាយជាខាងក្នុង រមែងដល់នូវកិរិយាពិចារណា ការពិចារណានោះឯង ជាធម្មវិចយសម្ពោជ្ឈង្គ ១ បុគ្គលត្រិះរិះពិចារណាដោយប្រាជ្ញាក្នុងធម៌ទាំងឡាយជាខាងក្រៅ រមែងដល់នូវកិរិយាពិចារណា ការពិចារណានោះឯង ជាធម្មវិចយសម្ពោជ្ឈង្គ ១ ព្រោះថា ធម្មវិចយសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ ធម្មវិចយសម្ពោជ្ឈង្គនោះមានចំណែក ២ ដោយហេតុនេះឯង ។

[៤៦២] ម្នាលភិក្ខុទាំងឡាយ សេចក្ដីព្យាយាមណា ប្រព្រឹត្តទៅក្នុងកាយ សេចក្ដីព្យាយាមនោះជាវីរិយសម្ពោជ្ឈង្គ ១ សេចក្ដីព្យាយាមណា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីព្យាយាមនោះជាវីរិយសម្ពោជ្ឈង្គ ១ ព្រោះថា វីរិយសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ វីរិយសម្ពោជ្ឈង្គនោះមានចំណែក ២ ដោយហេតុនេះឯង ។

[៤៦៣] ម្នាលភិក្ខុទាំងឡាយ បីតិណាប្រកបដោយវិតក្កៈនិងវិចារៈ បីតិនោះឯង ឈ្មោះថា បីតិសម្ពោជ្ឈង្គ ១ បីតិណាមិនមានវិតក្កៈនិងវិចារៈ បីតិនោះឈ្មោះថា បីតិសម្ពោជ្ឈង្គ ១ ព្រោះថា បីតិសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ បីតិសម្ពោជ្ឈង្គនោះមានចំណែក ២ ដោយហេតុនេះឯង ។

(៨៩៧) យទបិ ភិក្ខវេ កាយប្បស្សទ្ធិ តទបិ បស្សទ្ធិសម្ពោជ្ឈង្គោ យទបិ ចិត្តប្បស្សទ្ធិ តទបិ បស្សទ្ធិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៨៩៨) យទបិ ភិក្ខវេ សវិតក្កោ សវិចារោ សមាធិ តទបិ សមាធិសម្ពោជ្ឈង្គោ យទបិ អវិតក្កោ អវិចារោ សមាធិ តទបិ សមាធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។

(៨៩៩) យទបិ ភិក្ខវេ អជ្ឈត្តំ ធម្មេសុ ឧបេក្ខា តទបិ ឧបេក្ខាសម្ពោជ្ឈង្គោ យទបិ ពហិទ្ធា ធម្មេសុ ឧបេក្ខា តទបិ ឧបេក្ខាសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោតិ ឥតិ ហិទំ ឧទ្ទេសំ គច្ឆតិ ។ តទមិនាបេតំ បរិយាយេន ទ្វយំ ហោតិ ។



(៨៩៧) ម្នាលភិក្ខុទាំងឡាយ សេចក្ដីស្ងប់ស្ងាត់កាយណា សេចក្ដីស្ងប់ស្ងាត់កាយនោះឈ្មោះថា បស្សទ្ធិសម្ពោជ្ឈង្គ ១ សេចក្ដីស្ងប់ស្ងាត់ចិត្តណា សេចក្ដីស្ងប់ស្ងាត់ចិត្តនោះឈ្មោះថា បស្សទ្ធិសម្ពោជ្ឈង្គ ១ ព្រោះថា បស្សទ្ធិសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ បស្សទ្ធិសម្ពោជ្ឈង្គនោះមាន ២ ចំណែក ដោយហេតុនេះឯង ។

(៨៩៨) ម្នាលភិក្ខុទាំងឡាយ សមាធិណា មានវិតក្កៈមានវិចារៈ សមាធិនោះឈ្មោះថា សមាធិសម្ពោជ្ឈង្គ ១ សមាធិណាមិនមានវិតក្កៈមិនមានវិចារៈ សមាធិនោះឈ្មោះថា សមាធិសម្ពោជ្ឈង្គ ១ ព្រោះថា សមាធិសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ សមាធិសម្ពោជ្ឈង្គនោះមាន ២ ចំណែក ដោយហេតុនេះឯង ។

(៨៩៩) ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាណា ក្នុងធម៌ទាំងឡាយជាខាងក្នុង ឧបេក្ខានោះឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ ១ ឧបេក្ខាណា ក្នុងធម៌ទាំងឡាយជាខាងក្រៅ ឧបេក្ខានោះឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ ១ ព្រោះថា ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះ ។ ឧបេក្ខាសម្ពោជ្ឈង្គនោះមាន ២ ចំណែក ដោយហេតុនេះឯង ។

(១៦៧) អយំ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សត្ត ពោជ្ឈង្គា ចតុទ្ទសាតិ ។

(១៦៨) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិំសុ ។ (បេយ្យាលយសុត្តសទិសំ) ។ ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា យស្មឹ អាវុសោ សមយេ លីនំ ចិត្តំ ហោតិ កតមេ តស្មឹ សមយេ ពោជ្ឈង្គា អកាលា ភាវនាយ ។ កតមេ តស្មឹ សមយេ ពោជ្ឈង្គា កាលា ភាវនាយ ។ យស្មឹ បនាវុសោ សមយេ ឧទ្ធតំ ចិត្តំ ហោតិ កតមេ តស្មឹ សមយេ ពោជ្ឈង្គា អកាលា ភាវនាយ ។ កតមេ តស្មឹ សមយេ ពោជ្ឈង្គា កាលា ភាវនាយាតិ ។ ឯវំ បុដ្ឋា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ន ចេវ សម្បាយិស្សន្តិ ឧត្តរិញ្ច វិឃាតំ អាបជ្ជិស្សន្តិ ។



(១៦៧) ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុដែលនាំឲ្យពោជ្ឈង្គ ៧ ក្លាយជា ១៤ ។

(១៦៨) គ្រានោះ ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ (រឿងទាំងអស់ដូចក្នុងបរិយាយសូត្រ) ។ ម្នាលភិក្ខុទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយគប្បីសួរយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ចិត្តរួញក្នុងសម័យណា សម័យនោះជាកាលមិនគួរនឹងចំរើនពោជ្ឈង្គអ្វីខ្លះ ។ សម័យនោះជាកាលគួរនឹងចំរើនពោជ្ឈង្គអ្វីខ្លះ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ចិត្តរាយមាយក្នុងសម័យណា សម័យនោះជាកាលមិនគួរនឹងចំរើនពោជ្ឈង្គអ្វីខ្លះ ។ សម័យនោះជាកាលគួរនឹងចំរើនពោជ្ឈង្គអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយសួរយ៉ាងនេះ ពួកបរិព្វាជកជាអន្យតិរ្ថិយ មុខជាដោះស្រាយមិនរួចទេ ទាំងដល់នូវសេចក្តីចង្អៀតចង្អល់ចិត្តដ៏លើសលុបផង ។

តំ កិស្ស ហេតុ ។ យថា តំ ភិក្ខវេ អវិសយស្មឹ ។ នាហំ តំ ភិក្ខវេ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វា ។

(៥៦៩) យស្មឹ ច ខោ ភិក្ខវេ សមយេ ឧទ្ធតំ ចិត្តំ ហោតិ អកាលោ តស្មឹ សមយេ បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ ឧទ្ធតំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ ទុរុបសមយំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុកាមោ អស្ស សោ តត្ថ អល្លានិ ចេវ តិណានិ បក្ខិបេយ្យ អល្លានិ គោមយានិ បក្ខិបេយ្យ អល្លានិ ច កដ្ឋានិ បក្ខិបេយ្យ ឧទកវាតញ្ច ទទេយ្យ បំសុកេន ច ន ឱកិរេយ្យ ភព្វោ នុ ខោ សោ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុន្តិ ។



ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មិនមែនជាវិស័យរបស់ពួកបរិព្វាជកទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាដែលគួរដោះស្រាយប្រស្នាទាំងនេះឲ្យគាប់ចិត្តបាន លើកលែងតែតថាគត ឬសាវករបស់តថាគត ឬក៏បុគ្គលដែលបានស្តាប់អំពីសាវករបស់តថាគតចេញ ។

(៥៦៩) ម្នាលភិក្ខុទាំងឡាយ បើចិត្តរញ្ជួយក្នុងសម័យណា សម័យនោះ ជាកាលមិនគួរនឹងចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនឧបេក្ខាសម្ពោជ្ឈង្គឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តដែលរញ្ជួយ ចិត្តនោះមិនងាយនឹងឲ្យស្ងប់ដោយធម៌ទាំងឡាយនុ៎ះបានទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានប្រាថ្នានឹងបន្លត់ភ្លើងគំនរធំ បុរសនោះក៏ដាក់ស្មៅស្រស់ផង ដាក់គោមយស្រស់ផង ដាក់ឈើស្រស់ផង ផ្លុំខ្យល់ពាល់ទឹកផង រោយធូលីផង ក្នុងភ្លើងគំនរនោះ តើបុរសនោះគួរនឹងបន្លត់ភ្លើងគំនរធំនុ៎ះបានឬទេ ។

នោ ហេតំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ លីនំ ចិត្តំ ហោតិ អកាលោ តស្មឹ សមយេ បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ លីនំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ ទុស្សមុដ្ឋាបយំ ហោតិ ។

(៨៧០) យស្មិញ្ច ខោ ភិក្ខវេ សមយេ លីនំ ចិត្តំ ហោតិ កាលោ តស្មឹ សមយេ ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ បីតិសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ លីនំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ សុសមុដ្ឋាបយំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ បរិត្តំ អគ្គឹ ឧជ្ជាលេតុកាមោ អស្ស សោ



សូមទ្រង់ព្រះមេត្តាប្រោស មិនគួរនឹងបង្កាត់ឲ្យឆេះបានទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ ចិត្តដែលរួញរាក្នុងសម័យណា សម័យនោះ ជាកាលមិនគួរនឹងចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនឧបេក្ខាសម្ពោជ្ឈង្គឡើយ ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរួញរាហើយ ចិត្តនោះមិនងាយនឹងឲ្យស្ទុះឡើងដោយធម៌ទាំងឡាយនុ៎ះបានទេ ។

(៨៧០) ម្នាលភិក្ខុទាំងឡាយ បើចិត្តរួញរាក្នុងសម័យណា សម័យនោះ ជាកាលគួរនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនវីរិយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនបីតិសម្ពោជ្ឈង្គ ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តរួញរា ចិត្តនោះងាយនឹងឲ្យស្ទុះឡើងបានដោយធម៌ទាំងឡាយនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានប្រាថ្នានឹងបង្កាត់ភ្លើងតូច បុរសនោះ

តត្ថ សុក្ខានិ ចេវ តិណានិ បក្ខិបេយ្យ សុក្ខានិ គោមយានិ បក្ខិបេយ្យ សុក្ខានិ កដ្ឋានិ បក្ខិបេយ្យ មុខវាតញ្ច ទទេយ្យ ន ច បំសុកេន ឱកិរេយ្យ ភព្វោ នុ ខោ សោ បុរិសោ បរិត្តំ អគ្គឹ ឧជ្ជាលេតុន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ លីនំ ចិត្តំ ហោតិ កាលោ តស្មឹ សមយេ ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ វិរិយសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ បីតិសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ លីនំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ សុសមុដ្ឋាបយំ ហោតិ ។

(៤៧០) យស្មឹ ភិក្ខវេ សមយេ ឧទ្ធតំ ចិត្តំ ហោតិ អកាលោ តស្មឹ សមយេ ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ វិរិយសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ បីតិសម្ពោជ្ឈង្គស្ស ភាវនាយ ។



គឺដាក់ស្មៅស្ងួតផង ដាក់គោម័យស្ងួតផង ដាក់ឧសស្ងួតផង ផ្លុំខ្យល់មាត់ពីលើផង មិនរោយកម្ទេចដីផង ក្នុងភ្លើងតូចនោះ តើបុរសនោះគួរនឹងបង្កាត់ភ្លើងតូចឲ្យឆេះឡើងបានឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស បើយ៉ាងហ្នឹង គួរនឹងបង្កាត់ឲ្យឆេះបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ ចិត្តរួញរាក្នុងសម័យណា សម័យនោះ ជាកាលគួរនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនវីរិយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនបីតិសម្ពោជ្ឈង្គ ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរួញរា ចិត្តនោះតែងនឹងឲ្យស្ទុះឡើងបាន ដោយធម៌ទាំងឡាយនុ៎ះ ។

(៤៧០) ម្នាលភិក្ខុទាំងឡាយ បើចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជាកាលមិនគួរនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនវីរិយសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនបីតិសម្ពោជ្ឈង្គទេ ។

តំ កិស្ស ហេតុ ។ ឧទ្ធតំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ ទុវូបសមំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុកាមោ អស្ស សោ តត្ថ សុក្ខានិ ចេវ តិណានិ បក្ខិបេយ្យ សុក្ខានិ គោមយានិ បក្ខិបេយ្យ សុក្ខានិ កដ្ឋានិ បក្ខិបេយ្យ មុខវាតញ្ច ទទេយ្យ ន ច បំសុកេន ឱកិរេយ្យ ភព្វោ នុ ខោ សោ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុន្តិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ ឧទ្ធតំ ចិត្តំ ហោតិ អកាលោ តស្មឹ សមយេ ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ អកាលោ បីតិសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ ឧទ្ធតំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ ទុវូបសមំ ហោតិ ។



ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរាយមាយហើយ ចិត្តនោះមិនងាយនឹងឲ្យស្ងប់ស្ងាប់ដោយធម៌ទាំងឡាយនុ៎ះបានទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានប្រាថ្នានឹងរលត់គំនរភ្លើងធំ បុរសនោះគឺដាក់ស្មៅស្ងួតផង ដាក់គោម័យស្ងួតផង ដាក់អុសស្ងួតផង ផ្លុំខ្យល់អំពីមាត់ផង មិនរោយអាចម៍ដីផង ទៅក្នុងគំនរភ្លើងធំនោះ តើបុរសនោះគួរនឹងរលត់គំនរភ្លើងធំបានឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនគួរនឹងរលត់បានទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ ចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជាកាលមិនគួរនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនវីរិយសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនបីតិសម្ពោជ្ឈង្គឡើយ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរាយមាយហើយ ចិត្តនោះមិនងាយនឹងឲ្យស្ងប់ស្ងាប់ដោយធម៌ទាំងឡាយនុ៎ះបានឡើយ ។

(៥៧៦) យស្មិញ្ច ខោ ភិក្ខវេ សមយេ ឧទ្ធតំ ចិត្តំ ហោតិ កាលោ តស្មិំ សមយេ បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ ។ តំ កិស្ស ហេតុ ។ ឧទ្ធតំ ភិក្ខវេ ចិត្តំ តំ ឯតេហិ ធម្មេហិ សុវូបសមយំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុកាមោ អស្ស សោ តត្ថ អល្លានិ ចេវ តិណានិ បក្ខិបេយ្យ អល្លានិ គោមយានិ បក្ខិបេយ្យ អល្លានិ កដ្ឋានិ បក្ខិបេយ្យ ឧទកវាតញ្ច ទទេយ្យ បំសុកានិ(១) ច ឱកិរេយ្យ ភព្វោ នុ ខោ សោ បុរិសោ មហន្តំ អគ្គិក្ខន្ធំ និព្វាបេតុន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្មិំ សមយេ ឧទ្ធតំ ចិត្តំ ហោតិ កាលោ តស្មិំ សមយេ បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ កាលោ ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ ។

១ ម. ឱ. បំសុកេន ច ។



(៥៧៦) ម្នាលភិក្ខុទាំងឡាយ បើចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជាកាលគួរចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលគួរចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលគួរចំរើនឧបេក្ខាសម្ពោជ្ឈង្គ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរាយមាយហើយ ចិត្តនោះងាយនឹងស្ងប់រម្ងាប់បានដោយធម៌ទាំងឡាយនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានប្រាថ្នានឹងរលត់គំនរភ្លើងធំ បុរសនោះគប្បីដាក់ស្មៅស្រស់ផង ដាក់គោម័យស្រស់ផង ដាក់អុសស្រស់ផង ផ្លុំខ្យល់លាយទឹកផង កេងរោយធូលីផង ក្នុងគំនរភ្លើងនោះ តើបុរសនោះគួរនឹងរលត់គំនរភ្លើងធំបានឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនអាចនឹងរលត់បាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ ចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជាកាលគួរចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលគួរចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលគួរចំរើនឧបេក្ខាសម្ពោជ្ឈង្គ ។

តំ កិស្ស ហេតុ ។ ឧទ្ធតំ ភិក្ខវេ ចិត្តំ តំ បសមេហិ ធម្មេហិ សុវូបសមយំ ហោតិ ។ សតិញ្ច ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមីតិ ។

[៥៧៣] ឯកំ សមយំ ភគវា កោលិយេសុ វិហរតិ ហាលិទ្ទវសនំ នាម កោលិយានំ និគមោ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ហាលិទ្ទវសនំ បិណ្ឌាយ បាវិសិំសុ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អតិប្បគោ ខោ តាវ ហាលិទ្ទវសនេ[១] បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។

១ ម. ហលិទ្ទវសនេ ។



ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តរាយមាយហើយ ចិត្តនោះអាចឲ្យស្ងប់រម្ងាប់បានដោយធម៌ទាំងឡាយនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថាសតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ។

(៥៧៣) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងហលិទ្ទវសនគម របស់ពួកកោលិយៈ ក្នុងដែនកោលិយ ។ គ្រានោះឯង ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងហលិទ្ទវសនគម ។ លំដាប់នោះ ភិក្ខុទាំងនោះមានសេចក្ដីត្រិះរិះដូច្នេះថា ដំណើរដែលយើងចូលទៅបិណ្ឌបាតក្នុងហលិទ្ទវសនគមនោះ ដូចជានៅព្រឹកណាស់នៅឡើយ បើដូច្នោះ គួរពួកយើងនាំគ្នាចូលទៅឯអារាមរបស់បរិព្វាជកជាអន្យតិរ្ថិយសិនចុះ ។

(៥៧៦) អថខោ តេ ភិក្ខូ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សមណោ អាវុសោ គោតមោ សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរថ ។



(៥៧៦) លំដាប់នោះឯង ពួកភិក្ខុទាំងនោះក៏នាំគ្នាចូលទៅឯការាមរបស់បរិព្វាជកជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះនិយាយដូច្នេះថា នែលោកដ៏មានអាយុទាំងឡាយ ព្រះសមណគោតមតែងសំដែងធម៌ប្រាប់សាវកទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកណាយ ចូរអ្នកទាំងឡាយលះបង់នីវរណធម៌ ៥ ជាគ្រឿងសៅហ្មងនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ផ្សាយចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង និងទិសតូចៗ ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះឯង ។

(៨៧៥) ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។

(៨៧៦) មុទិតាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មុទិតាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។



(៨៧៥) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយករុណាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយករុណា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះឯង ។

(៨៧៦) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយមុទិតាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយមុទិតា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះឯង ។

(៥៧៧) ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរថាតិ ។

(៥៧៨) មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ ។បេ។

(៥៧៩) ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរថាតិ ។



(៥៧៧) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយឧបេក្ខាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះឯង ។

(៥៧៨) នែលោកដ៏មានអាយុទាំងឡាយ សូម្បីពួកយើង ក៏តែងសំដែងធម៌ប្រាប់សាវកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមកណេះ ចូរអ្នកទាំងឡាយលះបង់នីវរណធម៌ ៥ ជាគ្រឿងសៅហ្មងនៃចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកំឡាំងថយ រួចផ្សាយចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ។បេ។

(៥៧៩) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយឧបេក្ខាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះផង ។

(៨៨០) ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយសោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។

(៨៨១) អថខោ តេ ភិក្ខូ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទឹសុ នប្បដិក្កោសឹសុ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមឹសុ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។

(៨៨២) អថខោ តេ ភិក្ខូ ហលិទ្ទវសនេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ



(៨៨០) នែលោកដ៏មានអាយុទាំងឡាយ ចុះក្នុងរឿងនេះ មានសេចក្តីវិសេសដូចម្តេច មានសេចក្តីអធិប្បាយដូចម្តេច មានអំពើផ្សេងគ្នាដូចម្តេច របស់ព្រះសមណគោតមក្តី យើងក្តី អំពីដំណើរធម៌ទេសនានឹងធម៌ទេសនា អំពីពាក្យប្រៀនប្រដៅនឹងពាក្យប្រៀនប្រដៅ ។

(៨៨១) គ្រានោះឯង ពួកភិក្ខុទាំងនោះមិនបានត្រេកអរ មិនបានឃាត់ហាមភាសិតរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះមិនត្រេកអរ មិនឃាត់ហាមហើយ ក៏ក្រោកចាកអាសនៈដើរចេញទៅដោយគិតថា យើងគង់នឹងដឹងសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគមិនខាន ។

(៨៨២) លំដាប់នោះឯង ភិក្ខុទាំងនោះត្រាច់ទៅបិណ្ឌបាតក្នុងហលិទ្ទវសននិគម លុះកន្លងបិណ្ឌបាតក្នុងកាលជាខាងក្រោយភត្ត ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគដូច្នេះថា

(៤៨៣) ឥធ មយំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ហលិទ្ទវសនំ បិណ្ឌាយ បវិសិម្ហ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អតិប្បគោ ខោ តាវ ហលិទ្ទវសនេ បិណ្ឌាយ ចរិតុំ យន្នូន មយំ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមេយ្យាមាតិ ។

(៤៨៤) តេ មយំ ភន្តេ យេន អញ្ញតិត្ថិយានំ បរិព្វាជកានំ អារាមោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា តេហិ អញ្ញតិត្ថិយេហិ បរិព្វាជកេហិ សទ្ធិំ សម្មោទិម្ហ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិម្ហ ។ ឯកមន្តំ និសិន្នេ ខោ អម្ហេ ភន្តេ តេ អញ្ញតិត្ថិយា បរិព្វាជកា ឯតទវោចុំ សមណោ អាវុសោ គោតមោ សាវកានំ ឯវំ ធម្មំ ទេសេតិ ឯថ តុម្ហេ ភិក្ខវេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ ។បេ។



(៤៨៣) សូមទ្រង់ព្រះមេត្តាប្រោស ក្នុងថ្ងៃនោះ ខ្ញុំព្រះអង្គបានស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងហលិទ្ទវសននិគម ។ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា ដំណើរដែលយើងត្រាច់ទៅបិណ្ឌបាតក្នុងហលិទ្ទវសននិគម នៅព្រឹកណាស់នៅឡើយ បើដូច្នោះគួរតែពួកយើងចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយសិនចុះ ។

(៤៨៤) សូមទ្រង់ព្រះមេត្តាប្រោស វេលានោះ ខ្ញុំព្រះអង្គក៏បាននាំគ្នាចូលទៅឯអារាមរបស់ពួកបរិព្វាជកជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះបាននិយាយដូច្នេះថា នែលោកដ៏មានអាយុទាំងឡាយ ព្រះសមណគោតមតែងសំដែងធម៌ប្រាប់សាវកទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកពេយ ចូរអ្នកទាំងឡាយលះបង់នីវរណធម៌ ៥ ជាគ្រឿងសៅហ្មងចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ហើយផ្សាយចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ។បេ។

(៤៨៥) ករុណាសហគតេន ចេតសា ។

(៤៨៦) មុទិតាសហគតេន ចេតសា ។

(៤៨៧) ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរថាតិ ។

(៤៨៨) មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម ឯថ តុម្ហេ អាវុសោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ ។បេ។

(៤៨៩) ករុណាសហគតេន ចេតសា ។

(៤៩០) មុទិតាសហគតេន ចេតសា ។



(៤៨៥) ចិត្តប្រកបដោយករុណា ។

(៤៨៦) ចិត្តប្រកបដោយមុទិតា ។

(៤៨៧) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយឧបេក្ខាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង តាមទំនងនេះចុះ ។

(៤៨៨) ម្នាលលោកដ៏មានអាយុទាំងឡាយ សូម្បីពួកយើង ក៏តែងសំដែងធម៌ប្រាប់សាវកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមកណាយ ចូរអ្នកទាំងឡាយលះបង់នីវរណៈ ៥ ជាគ្រឿងសៅហ្មងចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ចូរផ្សាយចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ។បេ។

(៤៨៩) ចិត្តប្រកបដោយករុណា ។

(៤៩០) ចិត្តប្រកបដោយមុទិតា ។

(៤៩១) ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ ។ តថា តតិយំ ។ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។

(៤៩២) ឥធ នោ អាវុសោ កោ វិសេសោ កោ អធិប្បាយោ កិំ នានាករណំ សមណស្ស វា គោតមស្ស អម្ហាកំ វា យទិទំ ធម្មទេសនាយ វា ធម្មទេសនំ អនុសាសនិយា វា អនុសាសនិន្តិ ។

(៤៩៣) អថ ខោ មយំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ភាសិតំ នេវ អភិនន្ទិម្ហ នប្បដិក្កោសិម្ហ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កមិម្ហ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមាតិ ។

៤៩៣
ពោជ្ឈង្គវគ្គ

(៤៩១) អ្នកទាំងឡាយចូរផ្សាយចិត្តប្រកបដោយឧបេក្ខាទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ។ ទិសទី ៣ ក៏ដូចគ្នា ។ ទិសទី ៤ ក៏ដូចគ្នា ។ ចូរផ្សាយចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ក្នុងទីទាំងពួង ដូច្នេះវិញ ។

(៤៩២) ម្នាលលោកដ៏មានអាយុទាំងឡាយ ចុះក្នុងដំណើរនេះ តើមានសេចក្តីវិសេសដូចម្តេច មានសេចក្តីអធិប្បាយដូចម្តេច មានអំពើផ្សេងគ្នាដូចម្តេច របស់ព្រះសមណគោតមក្តី យើងក្តី អំពីដំណើរធម្មទេសនានឹងធម្មទេសនា អំពីពាក្យប្រៀនប្រដៅនឹងពាក្យប្រៀនប្រដៅ ។

(៤៩៣) សូមទ្រង់ព្រះមេត្តាប្រោស លំដាប់នោះ ពួកខ្ញុំព្រះអង្គ មិនបានត្រេកអរ មិនឃាត់ហាមភាសិតរបស់ពួកបរិព្វាជកជាអន្យតិត្ថិយទាំងនោះទេ លុះមិនត្រេកអរ មិនឃាត់ហាមហើយ ក៏ក្រោកចាកអាសនៈដើរចេញមក ដោយគិតថា យើងនឹងដឹងនូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគមិនខាន ។

(៤៩៦) ឯវំវាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា កថំ ភាវិតា បនាវុសោ មេត្តាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ កថំ ភាវិតា បនាវុសោ ករុណាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ កថំ ភាវិតា បនាវុសោ មុទិតាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ កថំ ភាវិតា បនាវុសោ ឧបេក្ខាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានាតិ ។ ឯវំ បុដ្ឋា ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ន ចេវ សម្បាយិស្សន្តិ ឧត្តរិញ្ច វិឃាតំ អាបជ្ជិស្សន្តិ ។ តំ កិស្ស ហេតុ ។ យថា តំ ភិក្ខវេ អវិសយស្មឹ ។ នាហំ ភិក្ខវេ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ



(៤៩៦) ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវសួរយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ចុះមេត្តាចេតោវិមុត្តិត្រូវចំរើនដូចម្ដេច មានគតិដូចម្ដេច មានសេចក្ដីថ្លៃថ្លាដូចម្ដេច មានផលដូចម្ដេច មានទីបំផុតដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ចុះករុណាចេតោវិមុត្តិ ត្រូវចំរើនដូចម្ដេច មានគតិដូចម្ដេច មានសេចក្ដីថ្លៃថ្លាដូចម្ដេច មានផលដូចម្ដេច មានទីបំផុតដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ចុះមុទិតាចេតោវិមុត្តិ ត្រូវចំរើនដូចម្ដេច មានគតិដូចម្ដេច មានសេចក្ដីថ្លៃថ្លាដូចម្ដេច មានផលដូចម្ដេច មានទីបំផុតដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ចុះឧបេក្ខាចេតោវិមុត្តិ ត្រូវចំរើនដូចម្ដេច មានគតិដូចម្ដេច មានសេចក្ដីថ្លៃថ្លាដូចម្ដេច មានផលដូចម្ដេច មានទីបំផុតដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយសួរយ៉ាងនេះ ពួកបរិព្វាជកជាអន្យតិរ្ថិយ មុខជានឹងឆ្លើយមិនរួចផង ទាំងដល់នូវសេចក្ដីចង្អៀតចង្អល់ចិត្តដ៏ក្រៃលែងផង ។ ដំណើរនោះ ព្រោះហេតុដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ មិនជាវិស័យរបស់ពួកអន្យតិរ្ថិយបរិព្វាជកទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក

សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ ឥមេសំ បញ្ហានំ វេយ្យាករណេន ចិត្តំ អារាធេយ្យ អញ្ញត្រ តថាគតេន វា តថាគតសាវកេន វា ឥតោ វា បន សុត្វា ។

[៥៩៥] កថំ ភាវិតា ច ភិក្ខវេ មេត្តាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ មេត្តាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ មេត្តាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិកូលេ អប្បដិកូលសញ្ញី វិហរេយ្យន្តិ អប្បដិកូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិកូលេ ច បដិកូលេ ច



ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាអាចដោះស្រាយប្រស្នាទាំងនេះឲ្យពេញចិត្តបានឡើយ លើកលែងតែតថាគតឬសាវ័ករបស់តថាគត ឬក៏បុគ្គលដែលបានស្ដាប់អំពីសាវ័ករបស់តថាគតមក ។

[៥៩៥] ម្នាលភិក្ខុទាំងឡាយ ចុះមេត្តាចេតោវិមុត្តិ តើគួរចំរើនដូចម្ដេច មានគតិដូចម្ដេច មានសេចក្ដីថ្លៃថ្លាដូចម្ដេច មានផលដូចម្ដេច មានទីបំផុតដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គប្រកបដោយមេត្តា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គប្រកបដោយមេត្តា ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតណ្ហា អាស្រ័យនូវធម៌ជាគ្រឿងរលត់ បង្អោនទៅកាន់ការលះបង់ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាមានសេចក្ដីសំគាល់ក្នុងរបស់ដែលមិនគួរខ្ពើមថា ជារបស់គួរខ្ពើមដូច្នេះ ជាអ្នកមានសេចក្ដីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្ដីសំគាល់ក្នុងរបស់ដែលគួរខ្ពើមថា ជារបស់មិនគួរខ្ពើមវិញដូច្នេះ ជាអ្នកមានសេចក្ដីសំគាល់ក្នុងរបស់នោះថាមិនគួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្ដីសំគាល់ក្នុងរបស់មិនគួរខ្ពើមនិងគួរខ្ពើមថា

បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ សុភំ វា ខោ បន វិមោក្ខំ ឧបសម្បជ្ជ វិហរតិ ។ សុភបរមាហំ ភិក្ខវេ មេត្តាចេតោវិមុត្តឹ វទាមិ ។ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរិវិមុត្តឹ អប្បដិវិជ្ឈតោ ។

[៥៩៦] កថំ ភាវិតា ច ភិក្ខវេ ករុណាចេតោវិមុត្តិ កិំគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ ករុណាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ ករុណាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ



ជារបស់គួរខ្ពើមដូច្នេះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់គួរខ្ពើមនឹងមិនគួរខ្ពើមថា ជារបស់មិនគួរខ្ពើមដូច្នេះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់មិនគួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញកុំជាប់ចំពាក់នឹងរបស់ទាំង ២ នោះ គឺរបស់មិនគួរខ្ពើមនឹងរបស់គួរខ្ពើម ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈដូច្នេះ ទៅជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈក្នុងរបស់នោះ ឬក៏បានសម្រេចវិមោក្ខដ៏ល្អ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលមេត្តាចេតោវិមុត្តិថា ជាគុណជាតល្អប្រសើរ ។ បើភិក្ខុមិនបានចាក់ធ្លុះឧត្តរិមុត្តិដ៏លើសលុបទេ ប្រាជ្ញាក៏គង់មានក្នុងលោកនេះដែរ ។

[៥៩៦] ម្នាលភិក្ខុទាំងឡាយ ករុណាចេតោវិមុត្តិ ដែលបុគ្គលចំរើនដូចម្តេច មានគតិដូចម្តេច មានសេចក្តីថ្លៃថ្លាដូចម្តេច មានផលដូចម្តេច មានទីបំផុតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គប្រកបដោយករុណា ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយករុណា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់

វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ ។បេ។ សចេ អាកង្ខតិ អប្បដិកូលញ្ច បដិកូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ សព្វសោ វា បន រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ អាកាសានញ្ចាយតនបរមាហំ ភិក្ខវេ ករុណាចេតោវិមុត្តឹ វទាមិ ។ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរិវិមុត្តឹ អប្បដិវិជ្ឈតោ ។





អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់ដែលមិនគួរខ្ពើមថា ជារបស់គួរខ្ពើមដូច្នេះ នៅជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមបាន ។បេ។ បើប្រាថ្នាថា សូមឲ្យអាត្មាកុំជាប់ជំពាក់នឹងរបស់ទាំង ២ នោះ គឺរបស់មិនគួរខ្ពើមនឹងរបស់គួរខ្ពើម ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈដូច្នេះ នៅជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈក្នុងរបស់នោះ ហើយកន្លងបង់នូវរូបសញ្ញាសព្វអន្លើ រលត់នូវបដិឃសញ្ញា មិនយកចិត្តទុកដាក់នូវនានត្តសញ្ញា ក៏ចូលកាន់អាកាសានញ្ចាយតនៈដោយបរិកម្មថា អាកាសមិនមានទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅករុណាចេតោវិមុត្តិថា មានអាកាសានញ្ចាយតនៈជាកំពូល ។ បើភិក្ខុមិនចាក់ធ្លុះនូវវិមុត្តិដ៏លើសលុបទេ ប្រាជ្ញាក៏គង់មានក្នុងលោកនេះដែរ ។

(៦៩៧) កថំ ភាវិតា ច ភិក្ខវេ មុទិតាចេតោវិមុត្តិ កិំគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ មុទិតាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ មុទិតាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមិំ ។ សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ ។បេ។ សចេ អាកង្ខតិ អប្បដិកូលញ្ច បដិកូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ សព្វសោ វា បន អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ វិញ្ញាណញ្ចាយតនបរមាហំ ភិក្ខវេ មុទិតាចេតោវិមុត្តិំ វទាមិ ។ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរិវិមុត្តិំ អប្បដិវិជ្ឈតោ ។



(៦៩៧) ម្នាលភិក្ខុទាំងឡាយ មុទិតាចេតោវិមុត្តិ គេចំរើន ដូចម្តេច មានគតិដូចម្តេច មានសេចក្តីថ្លៃថ្លាដូចម្តេច មានផលដូចម្តេច មានទីបំផុតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយមុទិតា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយមុទិតា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់ដែលមិនគួរខ្ពើម ថាជារបស់គួរខ្ពើមចុះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមបាន ។បេ។ បើប្រាថ្នាថា សូមឲ្យអាត្មាអញកុំជាប់ចំពាក់នឹងរបស់ទាំង ២ នោះ គឺរបស់មិនគួរខ្ពើមនឹងរបស់គួរខ្ពើម ហើយជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈចុះ ជាអ្នកព្រងើយកន្តើយ មានសតិសម្បជញ្ញៈក្នុងរបស់នោះ ក៏កន្លងនូវអាកាសានញ្ចាយតនៈសព្វគ្រប់ រួចចូលកាន់វិញ្ញាណញ្ចាយតនៈដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅមុទិតាចេតោវិមុត្តិថា ជាវិញ្ញាណញ្ចាយតនៈដ៏ឧត្តម ។ បើភិក្ខុមិនបានចាក់ធ្លុះនូវវិមុត្តិដ៏លើសលុបទេ ព្រោះថាភិក្ខុនឹងមានប្រាជ្ញាក្នុងលោកនេះដែរ ។

[៥៨៤] កថំ ភាវិតា ច ភិក្ខវេ ឧបេក្ខាចេតោវិមុត្តិ កឹគតិកា ហោតិ កិំបរមា កិំផលា កិំបរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ ឧបេក្ខាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ ឧបេក្ខាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិកូលេ អប្បដិកូលសញ្ញី វិហរេយ្យន្តិ អប្បដិកូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិកូលេ ច បដិកូលេ ច បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិកូលេ ច អប្បដិកូលេ ច អប្បដិកូលសញ្ញី វិហរេយ្យន្តិ



(៥៨៤) ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាចេតោវិមុត្តិ តើគ្រូចំរើនដូចម្តេច មានគតិដូចម្តេច មានសេចក្តីថ្លៃថ្លាដូចម្តេច មានផលដូចម្តេច មានទីបំផុតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយឧបេក្ខា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយឧបេក្ខា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ បើភិក្ខុនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់ដែលមិនគួរខ្ពើមថា ជារបស់គួរខ្ពើមផងចុះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់គួរខ្ពើមថា ជារបស់មិនគួរខ្ពើមផងចុះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់មិនគួរខ្ពើម បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់មិនគួរខ្ពើមផង គួរខ្ពើមផងថាជារបស់គួរខ្ពើមផងចុះ ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់គួរខ្ពើមមែន បើប្រាថ្នាថា សូមឲ្យអាត្មាអញមានសេចក្តីសំគាល់ក្នុងរបស់គួរខ្ពើមនឹងមិនគួរខ្ពើមថា ជារបស់មិនគួរខ្ពើមផងចុះ

អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ សព្វសោ វា បន វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ អាកិញ្ចញ្ញាយតនបរមាហំ ភិក្ខវេ ឧបេក្ខាចេតោវិមុត្តឹ វទាមិ ។ ឥធ បញ្ញស្ស ភិក្ខុនោ ឧត្តរិវិមុត្តឹ អប្បដិវិជ្ឈតោតិ ។

[៥៨៨] សាវត្ថីនិទានំ ។ អថ ខោ សង្គារវោ[១] ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ

១ ឱ. ម. សង្គារោ ។



ជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់នោះថា ជារបស់មិនគួរខ្ពើមក៏បាន បើប្រាថ្នាថា សូមឲ្យអាត្មាអញកុំជាប់ចំពាក់នឹងរបស់ទាំង ២ នោះ គឺរបស់មិនគួរខ្ពើមនឹងរបស់គួរខ្ពើម ហើយជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈដូច្នេះ នៅជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈក្នុងរបស់នោះ ក៏កន្លងនូវវិញ្ញាណញ្ចាយតនៈសព្វអន្លើ រួចចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា វត្ថុបន្តិចមិនមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅឧបេក្ខាចេតោវិមុត្តិថា មានអាកិញ្ចញ្ញាយតនៈដ៏ក្រៃលែង ។ បើភិក្ខុមិនចាក់ធ្លុះនូវវិមុត្តិដ៏លើសលុបទេ ប្រាជ្ញាក៏គង់មានក្នុងលោកនេះដែរ ។

(៥៨៨) សាវត្ថីនិទាន ។ គ្រានោះឯង សង្គារវព្រាហ្មណ៍ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសង្គារវព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរសេចក្តីនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន តើហេតុដូចម្តេច បច្ច័យដូចម្តេច

យេនេកទា ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនេកទា ទីឃរត្តំ អសជ្ឈា-យកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតាតិ ។

(៦០០) យស្មិំ ខោ ព្រាហ្មណ សមយេ កាម-រាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មិំ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ តស្មិំ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ឧភយត្ថម្បិ តស្មិំ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

(៦០១) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សំសដ្ឋោ លាខាយ វា ហលិទ្ទិយា វា នីលិយា វា មញ្ជិដ្ឋាយ វា តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខ-មានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ។



បានជាជួនកាលមន្តទាំងឡាយគេស្វាធ្យាយអស់កាលយូរអង្វែងហើយ ក៏មិនភ្លឺច្បាស់បាន មន្តដែលគេមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាជួនកាលមន្តទាំងឡាយគេមិនស្វាធ្យាយអស់កាលយូរអង្វែងទេ តែភ្លឺច្បាស់បាន មន្តដែលគេស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦០០) ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលកាមរាគរួបរឹត ដែលកាមរាគគ្របសង្កត់ រមែងមិនដឹង មិនឃើញច្បាស់ នូវការរលាស់កាមរាគដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញច្បាស់ នូវប្រយោជន៍អ្នកដទៃផង ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញច្បាស់ នូវប្រយោជន៍ទាំង ២ ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏នៅតែមិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦០១) ម្នាលព្រាហ្មណ៍ ថាសដែលគេដាក់ទឹកលាយដោយល័ក្ខ ឬរមៀត ឬខៀវ ឬក្រែកមានពណ៌ហង្សបាទ បុរសមានភ្នែកក្រឡេកមើលស្រមោលមុខរបស់ខ្លួន ក្នុងថាសដែលដាក់ទឹកនោះ គឺមិនគប្បីដឹង មិនគប្បីឃើញច្បាស់លាស់ឡើយ មានឧបមាយ៉ាងណាមិញ ។

ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

[៦០៤] បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។



ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលកាមរាគរួបរឹត ដែលកាមរាគក្រោបសង្កត់ មិនដឹង មិនឃើញ នូវការរលាស់កាមរាគដែលកើតហើយ ឲ្យច្បាស់លាស់តាម ក្នុងសម័យណា ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែងហើយ គង់នៅតែមិនភ្លឺច្បាស់តាម មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី មានឧបមេយ្យយ៉ាងនោះដែរ ។

[៦០៤] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលព្យាបាទរួបរឹត ដែលព្យាបាទក្រោបសង្កត់ មិនដឹង មិនឃើញ នូវការរលាស់ព្យាបាទដែលកើតហើយ ឲ្យច្បាស់លាស់តាមពិត ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង គង់នៅតែមិនភ្លឺច្បាស់តាម មន្តដែលគេមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦០៣) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អគ្គិនា សន្តត្តោ ឧក្កុដ្ឋិតោ ឧស្មុទកជាតោ(១) តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

១ ម. ឧស្មទកជាតោ ។

៣០៣
ពោជ្ឈង្គសំយុត្ត

(៦០៣) ម្នាលព្រាហ្មណ៍ ភាជន៍ដែលពេញដោយទឹក កំពុងតែក្តៅ ពុះពោរដោយភ្លើង មានចំហាយទឹកហុយឡើង បុរសមានភ្នែកភ្លឺ ឆ្លុះមើលស្រមោលមុខរបស់ខ្លួន ក្នុងភាជន៍ដែលដាក់ទឹកនោះ ក៏មិនដឹង មិនឃើញច្បាស់លាស់ឡើយ មានឧបមាយ៉ាងណាមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលព្យាបាទរួបរឹត ដែលព្យាបាទគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់ព្យាបាទដែលកើតហើយ ឲ្យច្បាស់លាស់បាន ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍របស់ខ្លួនឲ្យច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី មានឧបមេយ្យយ៉ាងនោះ ។

(២០៦) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្ប-ជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។ បេ ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។



(២០៦) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលថីន-មិទ្ធរួបរឹត ដែលថីនមិទ្ធគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់ចេញថីនមិទ្ធដែលកើតហើយ ឲ្យច្បាស់លាស់តាម ក្នុងសម័យណា ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនឲ្យច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។ បេ ។ ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ទាំង២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ ដែលធ្វើជាស្វាធ្យាយអស់កាលយូរអង្វែង ក៏នៅតែមិនភ្លឺច្បាស់ដូច្នេះ មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(២០៨) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សេវាលបណកបរិយោនទ្ធោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។



[២០៨] ម្នាលព្រាហ្មណ៍ ថូក្រដែលពេញដោយទឹក មានសារាយនិងចករគ្រៀបក្រដុំជិត បុរសមានភ្នែកភ្លឺ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ រមែងមិនដឹង មិនឃើញច្បាស់លាស់ឡើយ តាមសភាពពិតដូចម្ដេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលថីនមិទ្ធរួបរឹត ដែលថីនមិទ្ធគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់ថីនមិទ្ធដែលកើតហើយ ឲ្យច្បាស់លាស់តាម ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំង២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី [illegible] ។

(៦០៦) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ នបស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

(៦០៧) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ វា-តេរិតោ ចលិតោ ភណ្តោ(១) ឩមិជាតោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។

១ ម. ភន្តោ ។



(៦០៦) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយ ឲ្យច្បាស់លាស់តាម ក្នុងសម័យណា ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍របស់ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំងពីរច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦០៧) ម្នាលព្រាហ្មណ៍ ដូចស្រះដែលពេញដោយទឹក ត្រូវខ្យល់បក់បោក រំភើប បែកកើតជារលក បុរសមានភ្នែក ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ មិនគប្បីដឹង មិនគប្បីឃើញច្បាស់លាស់តាម មានទំនងដូចម្ដេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយច្បាស់លាស់ ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ

ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

(២០៨) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ ។បេ។ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។



នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង មន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ក៏ខាន បាមយ្យដូច្នោះដែរ ។

(២០៨) ម្នាលព្រាហ្មណ៍ មួយវិញទៀត បុគ្គលមានចិត្តដែលវិចិកិច្ឆារួបរឹត ដែលវិចិកិច្ឆាគ្របសង្កត់ រមែងមិនដឹង មិនឃើញ នូវការរលាស់វិចិកិច្ឆាដែលកើតហើយច្បាស់លាស់ទេ ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង នូវប្រយោជន៍អ្នកដទៃផង ។បេ។ ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង មន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦០៩) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អាវិលោ លុឡិតោ កលលីភូតោ អន្ធការេ និក្ខិត្តោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នប្បជានាតិ ន បស្សតិ ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។

(៦១០) អយំ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេកទា ទីឃរត្តំ សជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ អសជ្ឈាយកតា ។



(៦០៩) ម្នាលព្រាហ្មណ៍ ថូផ្សែលពេញដោយទឹកល្អក់ កករ កើតជាភក់ល្បាប់ គេទុកដាក់ក្នុងទីងងឹត បុរសមានភ្នែកភ្លឺ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ មិនគប្បីដឹង មិនគប្បីឃើញច្បាស់លាស់ឡើយ សេចក្តីនេះមានឧបមាដូចម្តេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលវិចិកិច្ឆារួបរឹត ដែលវិចិកិច្ឆាគ្របសង្កត់ហើយ រមែងមិនដឹង មិនឃើញ នូវការរលាស់វិចិកិច្ឆាដែលកើតហើយច្បាស់លាស់ពិត ក្នុងសម័យណា ក្នុងសម័យនោះ រមែងមិនដឹង មិនឃើញ នូវប្រយោជន៍ខ្លួនច្បាស់លាស់ផង ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍អ្នកដទៃច្បាស់លាស់ផង ក្នុងសម័យនោះ មិនដឹង មិនឃើញ នូវប្រយោជន៍ទាំង ២ ច្បាស់លាស់ផង ឯមន្តទាំងឡាយ បើទុកជាស្វាធ្យាយអស់កាលយូរអង្វែង ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ក៏មានឧបមេយ្យដូច្នោះដែរ ។

(៦១០) ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ឲ្យមានជួនកាលមន្តទាំងឡាយ សូម្បីស្វាធ្យាយអស់កាលយូរអង្វែងហើយ ក៏មិនភ្លឺច្បាស់បាន មន្តដែលមិនស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦១១) យស្មិញ្ច ខោ ព្រាហ្មណ សមយេ ន កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគប-រេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថា-ភូតំ បជានាតិ បស្សតិ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

(៦១២) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អសំ-សដ្ឋោ លាខាយ វា ហលិទ្ទិយា វា នីលិយា វា មញ្ជិ-ដ្ឋាយ វា តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន កាមរាគ-បរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ ។បេ ។



(៦១១) ម្នាលព្រាហ្មណ៍ បើសម័យណា បុគ្គលមានចិត្ត ដែលកាមរាគមិនរួបរឹត ដែលកាមរាគមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់កាមរាគដែលកើតហើយ សម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង សម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍អ្នកដទៃផង សម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ទាំង ២ ផង ឯមន្តទាំងឡាយ បើទុកជាមិនសាធ្យាយអស់កាលយូរ ក៏គង់ភ្លឺច្បាស់បាន មន្តដែលសាធ្យាយ ចាំបាច់និយាយថ្វី ។

(៦១២) ម្នាលព្រាហ្មណ៍ ថាសពេញដោយទឹក មិនលាយល័ក្ខក្រមៀត ថ្នាំមានព៌ណខៀវ ថ្នាំមានព៌ណហង្សបាទ បុរសមានភ្នែកភ្លឺ ក្រឡេកមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ គប្បីដឹងច្បាស់ ឃើញច្បាស់បាន សេចក្តីនេះមានឧបមាដូចម្តេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលកាមរាគមិនរួបរឹត ដែលកាមរាគមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់កាមរាគដែលកើតហើយ ក្នុងសម័យណា មានឧបមេយ្យដូច្នោះដែរ ។បេ ។

(៦១៣) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ន ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។បេ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

(៦១៤) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ ន អគ្គិនា សន្តត្តោ ន ឧក្កុដ្ឋិតោ ន ឧស្មុទកជាតោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ន ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។បេ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។



(៦១៣) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលព្យាបាទមិនរួបរឹត ដែលព្យាបាទមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ព្យាបាទដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំង ២ ផង ។បេ។ ឯមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ គឺគង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦១៤) ម្នាលព្រាហ្មណ៍ ថូតែពេញដោយទឹក មិនក្តៅ មិនពុះពោរដោយភ្លើង មិនមានចំហាយទឹកហុយឡើងទេ បុរសមានភ្នែកក្រឡេកមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ គប្បីដឹងច្បាស់ ឃើញច្បាស់បាន យ៉ាងណាមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលព្យាបាទមិនរួបរឹត ដែលព្យាបាទមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ព្យាបាទដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំង ២ ផង ។បេ។ ឯមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ គឺគង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី យ៉ាងនោះដែរ ។

[៦១៨] បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ន ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

[៦១៩] សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ ន សេវាលបណកបរិយោនទ្ធោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ន ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។





[៦១៨] ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលថីនមិទ្ធៈមិនរួបរឹត ដែលថីនមិទ្ធៈមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ថីនមិទ្ធៈដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំង ២ ផង ។ បេ ។ ឯមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ ក៏គង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី ។

[៦១៩] ម្នាលព្រាហ្មណ៍ ថុត្រដែលពេញដោយទឹក មិនមានសារាយនិងចកគ្រៀមគ្របជិតទេ បុរសមានភ្នែកភ្លឺ ឈ្ងោកមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ គប្បីដឹងច្បាស់ ឃើញច្បាស់បាន មានឧបមាដូចម្តេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលថីនមិទ្ធៈមិនរួបរឹត ដែលថីនមិទ្ធៈមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ថីនមិទ្ធៈដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំង ២ ផង ។ បេ ។ ឯមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ ក៏គង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី មានឧបមេយ្យដូចោះដែរ ។

(៦០៧) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ ន ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ន ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។បេ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

(៦០៨) សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ ន វាតេរិតោ ន ចលិតោ ន ភន្តោ ន ឩមិជាតោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ ជានេយ្យ បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ



(៦០៧) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចមិនរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំង ២ ផង ។បេ។ មន្តទាំងឡាយ ដែលមិនបានស្វាធ្យាយអស់កាលយូរ ក៏នឹកឃើញច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយធ្វើអ្វី ។

(៦០៨) ម្នាលព្រាហ្មណ៍ ថាសដែលពេញដោយទឹក មិនត្រូវខ្យល់បក់ផាត់ មិនរំកើប មិនរលក មិនកើតទៅជារលកទេ បុរសមានភ្នែកភ្លឺ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ គប្បីដឹងច្បាស់ ឃើញច្បាស់បាន តាមសេចក្តីពិត ។ ម្នាលព្រាហ្មណ៍

យស្មឹ សមយេ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នជានាតិ នបស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នជានាតិ នបស្សតិ បរត្ថម្បិ ។ ឧភយត្ថម្បិ ។ បេ ។ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា នប្បដិភន្តិ បគេវ សជ្ឈាយកតា ។

(២០៤) បុន ចបរំ ព្រាហ្មណ យស្មឹ សមយេ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នជានាតិ នបស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ នជានាតិ នបស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ នជានាតិ នបស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ នជានាតិ នបស្សតិ ។ បេ ។



បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង នូវប្រយោជន៍អ្នកដទៃផង ។ នូវប្រយោជន៍ទាំងពីរផង ។ បេ ។ ២មន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ ក៏នឹងភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី មានឧបមេយ្យ ដូច្នោះដែរ ។

(២០៤) ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលមានចិត្តដែលវិចិកិច្ឆារួបរឹត ដែលវិចិកិច្ឆាគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់វិចិកិច្ឆាដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍អ្នកដទៃផង ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ទាំងពីរផង ។ បេ ។

[២៤០] សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ អច្ឆោ វិប្បសន្នោ អនាវិលោ អាលោកេ និក្ខិត្តោ តត្ថ ចក្ខុមា បុរិសោ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ យថាភូតំ បជានេយ្យ បស្សេយ្យ ។ ឯវមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ន វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ន វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ បជានាតិ បស្សតិ អត្តត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ បរត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ឧភយត្ថម្បិ តស្មឹ សមយេ យថាភូតំ បជានាតិ បស្សតិ ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។

[២៤១] អយំ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេកទា ទីឃរត្តំ អសជ្ឈាយកតាបិ មន្តា បដិភន្តិ បគេវ សជ្ឈាយកតា ។



[២៤០] ម្នាលព្រាហ្មណ៍ ថាសដែលពេញដោយទឹកថ្លា ស្អាត មិនល្អក់ គេទុកដាក់ក្នុងទីភ្លឺ បុរសមានភ្នែកភ្លឺ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងទឹកនោះ គប្បីដឹងច្បាស់ ឃើញច្បាស់បាន មានឧបមាដូចម្ដេចមិញ ។ ម្នាលព្រាហ្មណ៍ បុគ្គលមានចិត្តដែលវិចិកិច្ឆាមិនរួបរឹត ដែលវិចិកិច្ឆាមិនគ្របសង្កត់ រមែងដឹងច្បាស់ ឃើញច្បាស់ នូវការរលាស់វិចិកិច្ឆាដែលកើតហើយ ក្នុងសម័យណា ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ខ្លួនផង ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍អ្នកដទៃផង ក្នុងសម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់ នូវប្រយោជន៍ទាំង ២ ផង ឯមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ ក៏គង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី មានឧបមេយ្យដូច្នោះដែរ ។

[២៤១] ម្នាលព្រាហ្មណ៍ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលជួនកាលមន្តទាំងឡាយ បើទុកជាមិនស្វាធ្យាយអស់កាលយូរ ក៏គង់ភ្លឺច្បាស់បាន មន្តដែលស្វាធ្យាយ ចាំបាច់និយាយថ្វី ។

(៦៦២) សត្តិមេ ព្រាហ្មណ ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ កតមេ សត្ត ។ សតិសម្ពោជ្ឈង្គោ ខោ ព្រាហ្មណ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ខោ ព្រាហ្មណ អនាវរណោ អនីវរណោ ចេតសោ អនុបក្កិលេសោ ភាវិតោ ពហុលីកតោ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។ ឥមេ ខោ ព្រាហ្មណ សត្ត ពោជ្ឈង្គា អនាវរណា អនីវរណា ចេតសោ អនុបក្កិលេសា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

(៦៦៣) ឯវំ វុត្តេ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។



(៦៦២) ម្នាលព្រាហ្មណ៍ ពោជ្ឈង្គទាំង ៧ នេះឯង ជាធម៌មិនកាង មិនបាំងបិទ មិនមានគ្រឿងសៅហ្មងចិត្ត បើអប់រំឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវផលនៃវិជ្ជានិងវិមុត្តិ ។ ពោជ្ឈង្គទាំង ៧ តើដូចម្តេចខ្លះ ។ ម្នាលព្រាហ្មណ៍ សតិសម្ពោជ្ឈង្គ ជាធម៌មិនកាង មិនបាំងបិទ មិនមានគ្រឿងសៅហ្មងចិត្ត បើអប់រំឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវផលនៃវិជ្ជានិងវិមុត្តិ ។ បេ ។ ម្នាលព្រាហ្មណ៍ ឧបេក្ខាសម្ពោជ្ឈង្គ ជាធម៌មិនកាង មិនបាំងបិទ មិនមានគ្រឿងសៅហ្មងចិត្ត បើអប់រំឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវផលនៃវិជ្ជានិងវិមុត្តិ ។ ម្នាលព្រាហ្មណ៍ ពោជ្ឈង្គទាំង ៧ នេះហើយ ដែលជាធម៌មិនកាង មិនបាំងបិទ មិនមានគ្រឿងសៅហ្មងចិត្ត ដែលអប់រំហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវផលនៃវិជ្ជានិងវិមុត្តិ ។

(៦៦៣) កាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សង្គារវព្រាហ្មណ៍បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

(៦៦៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ អភយោ រាជកុមារោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អភយោ រាជកុមារោ ភគវន្តំ ឯតទវោច ។

(៦៦៥) បូរណោ ភន្តេ កស្សបោ ឯវមាហ នត្ថិ ហេតុ នត្ថិ បច្ចយោ អញ្ញាណាយ អទស្សនាយ អហេតុ អប្បច្ចយោ អញ្ញាណំ អទស្សនំ ហោតិ ។ នត្ថិ ហេតុ នត្ថិ បច្ចយោ ញាណាយ ទស្សនាយ អហេតុ អប្បច្ចយោ ញាណំ ទស្សនំ ហោតីតិ ។ ឥធ ភគវា កិមាហាតិ ។

(៦៦៦) អត្ថិ រាជកុមារ ហេតុ អត្ថិ បច្ចយោ អញ្ញាណាយ អទស្សនាយ សហេតុ សប្បច្ចយោ អញ្ញាណំ អទស្សនំ ហោតិ ។ អត្ថិ រាជកុមារ ហេតុ អត្ថិ បច្ចយោ ញាណាយ ទស្សនាយ សហេតុ សប្បច្ចយោ ញាណំ ទស្សនំ ហោតីតិ ។



(៦៦៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់សម្រេចព្រះឥរិយាបថលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង អភយរាជកុមារស្តេចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះអភយរាជកុមារគង់ក្នុងទីដ៏សមគួរហើយ ទើបទ្រង់ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា

(៦៦៥) បពិត្រព្រះអង្គដ៏ចំរើន បូរណកស្សបបាននិយាយយ៉ាងនេះថា ហេតុ បច្ច័យ នៃការមិនដឹង មិនឃើញ មិនមានឡើយ ការមិនដឹង មិនឃើញ ឥតមានហេតុ ឥតមានបច្ច័យទេ ។ ហេតុ បច្ច័យ នៃការដឹង ការឃើញ មិនមានឡើយ ការដឹង ការឃើញ ឥតមានហេតុ ឥតមានបច្ច័យទេ ។ ចុះព្រះអង្គទ្រង់ត្រាស់ក្នុងរឿងនេះដូចម្តេច ។

(៦៦៦) ម្នាលរាជកុមារ ហេតុ បច្ច័យ នៃការមិនដឹង មិនឃើញ រមែងមាន ការមិនដឹង មិនឃើញ រមែងមានហេតុ មានបច្ច័យ ។ ម្នាលរាជកុមារ ហេតុ បច្ច័យ នៃការដឹង ការឃើញ មាន ការដឹង ការឃើញ រមែងមានហេតុ មានបច្ច័យ ។

[៦៦៧] កោ ភន្តេ ហេតុ កោ បច្ចយោ អញ្ញាណាយ អទស្សនាយ ។ កថំ សហេតុ សប្បច្ចយំ អញ្ញាណំ អទស្សនំ ហោតីតិ ។

[៦៦៨] យស្មឹ ខោ រាជកុមារ សមយេ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ ។ អយម្បិ ខោ រាជកុមារ ហេតុ អយំ បច្ចយោ អញ្ញាណាយ អទស្សនាយ ។ ឯវម្បិ សហេតុ សប្បច្ចយំ អញ្ញាណំ អទស្សនំ ហោតិ ។

[៦៦៩] បុន ចបរំ រាជកុមារ យស្មឹ សមយេ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ ។ អយម្បិ ខោ រាជកុមារ ហេតុ អយំ បច្ចយោ អញ្ញាណាយ អទស្សនាយ ។ ឯវម្បិ សហេតុ សប្បច្ចយំ អញ្ញាណំ អទស្សនំ ហោតិ ។





(៦៦៧) បពិត្រព្រះអង្គដ៏ចំរើន ហេតុ បច្ច័យ នៃការមិនដឹង មិនឃើញ តើដូចម្តេច ។ ការមិនដឹង មិនឃើញ រមែងមានហេតុ មានបច្ច័យដូចម្តេច ។

(៦៦៨) ម្នាលរាជកុមារ ក្នុងសម័យដែលបុគ្គលមានចិត្តដែលកាមរាគរួបរឹត ដែលកាមរាគគ្របសង្កត់ រមែងមិនដឹង មិនឃើញច្បាស់ នូវការរលាស់កាមរាគដែលកើតហើយ ។ ម្នាលរាជកុមារ នេះឯងជាហេតុ នេះជាបច្ច័យ នៃការមិនដឹង មិនឃើញ ។ ការមិនដឹង មិនឃើញ រមែងមានហេតុ មានបច្ច័យយ៉ាងនេះ ។

(៦៦៩) ម្នាលរាជកុមារ មួយទៀត ក្នុងសម័យដែលបុគ្គលមានចិត្តដែលព្យាបាទរួបរឹត ដែលព្យាបាទគ្របសង្កត់ រមែងមិនដឹង មិនឃើញច្បាស់ នូវការរលាស់ព្យាបាទដែលកើតហើយ ។ ម្នាលរាជកុមារ នេះឯងជាហេតុ នេះឯងជាបច្ច័យ នៃការមិនដឹង មិនឃើញ ។ ការមិនដឹង មិនឃើញ រមែងមានហេតុ មានបច្ច័យយ៉ាងនេះ ។

[២៣០] បុន ចបរំ រាជកុមារ យស្មឹ សមយេ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា ។

[២៣១] ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា ។

[២៣២] វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ ន បស្សតិ ។ អយម្បិ ខោ រាជកុមារ ហេតុ អយំ បច្ចយោ អញ្ញាណាយ អទស្សនាយ ។ ឯវម្បិ សហេតុ សប្បច្ចយោ អញ្ញាណំ អទស្សនំ ហោតីតិ ។

[២៣៣] កោ នាមាយំ ភន្តេ ធម្មបរិយាយោតិ ។ នីវរណា នាមេតេ រាជកុមារាតិ ។ តគ្ឃ ភគវា នីវរណា តគ្ឃ សុគត នីវរណា ឯកមេកេនបិ ខោ ភន្តេ នីវរណេន អភិភូតោ យថាភូតំ នប្បជានេយ្យ ន បស្សេយ្យ កោ បន វាទោ បញ្ចហិ នីវរណេហិ ។



[២៣០] ម្នាលរាជកុមារ មួយទៀត ក្នុងសម័យដែលបុគ្គល មានចិត្តដែលថីនមិទ្ធរួបរឹត ។

[២៣១] បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចរួបរឹត ។

[២៣២] បុគ្គលមានចិត្តដែលវិចិកិច្ឆារួបរឹត ដែលវិចិកិច្ឆាគ្របសង្កត់ រមែងមិនដឹង មិនឃើញច្បាស់ នូវការរលាស់វិចិកិច្ឆាដែលកើតហើយទេ ។ ម្នាលរាជកុមារ នេះឯងជាហេតុ នេះឯងជាបច្ច័យ នៃការមិនដឹង មិនឃើញ ។ ការមិនដឹង មិនឃើញ រមែងមានហេតុ មានបច្ច័យយ៉ាងនេះ ។

[២៣៣] បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះ ឈ្មោះដូចម្តេច ។ ម្នាលរាជកុមារ ធម្មបរិយាយទាំងនុ៎ះ ឈ្មោះជានីវរណៈ ។ បពិត្រព្រះដ៏មានព្រះភាគ ឲ្យឈ្មោះជានីវរណៈសមហើយ បពិត្រព្រះសុគត ឲ្យឈ្មោះជានីវរណៈសមហើយ បពិត្រព្រះអង្គដ៏ចំរើន សូម្បីបុគ្គលដែលមាននីវរណៈមួយៗ គ្របសង្កត់ គង់មិនគប្បីដឹង មិនគប្បីឃើញច្បាស់ទៅហើយ ចាំបាច់និយាយថ្វីដល់ទៅនីវរណធម៌ទាំង៥ គ្របសង្កត់ ។

[២៣៤] កតមោ បន ភន្តេ ហេតុ កតមោ បច្ចយោ ញាណាយ ទស្សនាយ ។ កថំ សហេតុ សប្បច្ចយោ ញាណំ ទស្សនំ ហោតីតិ ។

[២៣៥] ឥធ រាជកុមារ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សោ សតិសម្ពោជ្ឈង្គំ ភាវេតិ[1] តេន ចិត្តេន យថាភូតំ បជានាតិ បស្សតិ ។ អយម្បិ ខោ រាជកុមារ ហេតុ អយំ បច្ចយោ ញាណាយ ទស្សនាយ ។ ឯវម្បិ សហេតុ សប្បច្ចយោ ញាណំ ទស្សនំ ហោតិ ។

[២៣៦] បុន ចបរំ រាជកុមារ ភិក្ខុ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សោ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ តេន ចិត្តេន យថាភូតំ បជានាតិ បស្សតិ ។ អយម្បិ ខោ រាជកុមារ ហេតុ អយំ បច្ចយោ ញាណាយ ទស្សនាយ ។ ឯវម្បិ សហេតុ សប្បច្ចយោ ញាណំ ទស្សនំ ហោតីតិ ។

---

១ ឱ. ម. ភាវិតេន ។



[២៣៤] បពិត្រព្រះអង្គដ៏ចំរើន ចុះហេតុ បច្ច័យ នៃការដឹង ការឃើញ តើដូចម្តេច ។ ការដឹង ការឃើញ ព្រមទាំងហេតុ មានបច្ច័យដូចម្តេច ។

[២៣៥] ម្នាលរាជកុមារ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ ភិក្ខុនោះ ចំរើនសតិសម្ពោជ្ឈង្គ ក៏ដឹងច្បាស់ ឃើញច្បាស់ ដោយសារចិត្តនោះ ។ ម្នាលរាជកុមារ នេះឯងជាហេតុ នេះឯងជាបច្ច័យ នៃការដឹង ការឃើញ ។ ការដឹង ការឃើញ ព្រមទាំងហេតុ មានបច្ច័យយ៉ាងនេះ ។

[២៣៦] ម្នាលរាជកុមារ មួយទៀត ភិក្ខុ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាករាគៈ អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ ភិក្ខុនោះ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ក៏ដឹងច្បាស់ ឃើញច្បាស់ ដោយសារចិត្តនោះ ។ ម្នាលរាជកុមារ នេះឯងជាហេតុ នេះឯងជាបច្ច័យ នៃការដឹង ការឃើញ ។ ការដឹង ការឃើញ ព្រមទាំងហេតុ មានបច្ច័យយ៉ាងនេះ ។

(៦៣៧) កោ នាមាយំ ភន្តេ ធម្មបរិយាយោតិ ។ ពោជ្ឈង្គា នាមេតេ រាជកុមារាតិ ។ តគ្ឃ ភគវា ពោជ្ឈង្គា តគ្ឃ សុគត ពោជ្ឈង្គា ឯកមេកេនបិ ខោ ភន្តេ ពោជ្ឈង្គេន សមន្នាគតោ យថាភូតំ ជានេយ្យ បស្សេយ្យ កោ បន វាទោ សត្តហិ ពោជ្ឈង្គេហិ ។ យោបិ មេ ភន្តេ គិជ្ឈកូដំ បព្វតំ អារោហន្តស្ស កាយកិលមថោ ចិត្តកិលមថោ សោបិ មេ បដិប្បស្សទ្ធោ ធម្មោ ច មេ អភិសមេតោតិ ។

ឧទ្ទានំ ភវតិ

អាហារា បរិយាយ អគ្គិ
មេត្តំ[១] សង្គារវេន ច
អភយោ បុច្ឆិតោ បញ្ហំ
គិជ្ឈកូដម្ហិ បព្វតេតិ ។

ពោជ្ឈង្គសំយុត្តស្ស ពោជ្ឈង្គឆក្កំ ឆដ្ឋំ ។

---

១ ឱ. ម. មេត្តំ ។



(៦៣៧) បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះ ឈ្មោះដូចម្តេច ។ ម្នាលរាជកុមារ ធម្មបរិយាយទាំងនេះ ឈ្មោះថាពោជ្ឈង្គ ។ បពិត្រព្រះដ៏មានព្រះភាគ ឈ្មោះពោជ្ឈង្គសមរហើយ បពិត្រព្រះសុគត ឈ្មោះពោជ្ឈង្គសមរហើយ បពិត្រព្រះអង្គដ៏ចំរើន សូម្បីបុគ្គលដែលប្រកបដោយពោជ្ឈង្គមួយៗ ក៏គប្បីដឹងច្បាស់ ឃើញច្បាស់ទៅហើយ នឹងចាំបាច់និយាយថ្វីដល់ទៅបុគ្គលប្រកបដោយពោជ្ឈង្គទាំង ៧ ។ បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គឡើងកាន់ភ្នំគិជ្ឈកូដ ក៏មានសេចក្តីលំបាកកាយលំបាកចិត្ត (ណាស់) ខ្ញុំព្រះអង្គបានរម្ងាប់សេចក្តីលំបាកកាយ និងលំបាកចិត្តនោះហើយ ទាំងធម៌ខ្ញុំព្រះអង្គក៏បានត្រាស់ដឹងច្បាស់ហើយ ។

មានឧទ្ទានថា

គឺនិយាយអំពីអាហារ អំពីបរិយាយ អំពីភ្លើង អំពីផ្សាយមេត្តា អំពីរឿងសង្គារវព្រាហ្មណ៍ អំពីរឿងអភយរាជកុមារ សួរប្រស្នាឯភ្នំគិជ្ឈកូដ ។

ចប់ ពោជ្ឈង្គសំយុត្ត ពោជ្ឈង្គឆក្កទី ៦ ។

## ពោជ្ឈង្គស្ស អានាបានទិបេយ្យាលោ

(២៣៨) សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ កថំ ភាវិតា ច ភិក្ខវេ អដ្ឋិកសញ្ញា កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ អដ្ឋិកសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អដ្ឋិកសញ្ញា ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

## ពោជ្ឈង្គ អានាបានទិបេយ្យាល

(២៣៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា[១] ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ បង្អោនទៅកាន់សេចក្តីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។

---

១ ការសំគាល់ជាឆ្អឹងខ្មោច ហៅថាអដ្ឋិកសញ្ញា ។

(២៣៩) សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញាយ ភិក្ខវេ ភាវិតាយ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ កថំ ភាវិតាយ ច ខោ ភិក្ខវេ អដ្ឋិកសញ្ញាយ កថំ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតាយ ខោ ភិក្ខវេ អដ្ឋិកសញ្ញាយ ឯវំ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។



(២៣៩) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ បណ្ដាផលទាំង ២ ផលណាមួយក៏កើតជាក់ស្ដែង គឺនឹងបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើមានឧបាទានទៅមានសេសសល់ ក៏គង់នឹងបានអនាគាមិផលដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះអដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្ដេច បានធ្វើឲ្យច្រើនហើយដូចម្ដេច ទើបបណ្ដាផលទាំង ២ ផលណាមួយក៏កើតជាក់ស្ដែង គឺនឹងបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើមានឧបាទានទៅមានសេសសល់ ក៏គង់បានអនាគាមិផលដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់សេចក្ដីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ទើបបណ្ដាផលទាំង ២ ផលណាមួយក៏កើតជាក់ស្ដែង គឺនឹងបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើមានឧបាទានទៅមានសេសសល់ ក៏គង់បានអនាគាមិផលដែរ ។

(៦៤០) សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហតោ អត្ថាយ សំវត្តតិ ។ កថំ ភាវិតា ច ភិក្ខវេ អដ្ឋិកសញ្ញា កថំ ពហុលីកតា មហតោ អត្ថាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ អដ្ឋិកសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អដ្ឋិកសញ្ញា ឯវំ ពហុលីកតា មហតោ អត្ថាយ សំវត្តតីតិ ។



(៦៤០) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ធំ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។

(៦៤១) សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហតោ យោគក្ខេមាយ សំវត្តតិ ។ កថំ ភាវិតា ច ភិក្ខវេ អដ្ឋិកសញ្ញា កថំ ពហុលីកតា មហតោ យោគក្ខេមាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ អដ្ឋិកសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អដ្ឋិកសញ្ញា ឯវំ ពហុលីកតា មហតោ យោគក្ខេមាយ សំវត្តតីតិ ។

(៦៤២) សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហតោ សំវេគាយ សំវត្តតិ ។ កថំ ភាវិតា ច ភិក្ខវេ អដ្ឋិកសញ្ញា កថំ ពហុលីកតា មហតោ សំវេគាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។



(៦៤១) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ ដើម្បីក្សេមចាកយោគដ៏ធំ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីក្សេមចាកយោគដ៏ធំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីក្សេមចាកយោគដ៏ធំ ។

(៦៤២) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគដ៏ធំ ។ ម្នាលភិក្ខុទាំងឡាយ ចុះអដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសង្វេគដ៏ធំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ។បេ។

អដ្ឋិកសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អដ្ឋិកសញ្ញា ឯវំ ពហុលីកតា មហតោ សំវេគាយ សំវត្តតីតិ ។

[៦៤៣] សាវត្ថីនិទានំ ។ អដ្ឋិកសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហតោ ផាសុវិហារាយ សំវត្តតិ ។ កថំ ភាវិតា ច ភិក្ខវេ អដ្ឋិកសញ្ញា កថំ ពហុលីកតា មហតោ ផាសុវិហារាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ អដ្ឋិកសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ អដ្ឋិកសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អដ្ឋិកសញ្ញា ឯវំ ពហុលីកតា មហតោ ផាសុវិហារាយ សំវត្តតីតិ ។



ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ប្រព្រឹត្តទៅដើម្បីសេចក្តីសំវេគធំ ។

[៦៤៣] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅ ដើម្បីការនៅជាសុខធំ ។ ម្នាលភិក្ខុទាំងឡាយ ចុះអដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច រមែងប្រព្រឹត្តទៅដើម្បីការនៅជាសុខធំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយអដ្ឋិកសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អដ្ឋិកសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ប្រព្រឹត្តទៅដើម្បីការនៅជាសុខធំ ។

(៦៦៤) បុឡុវកសញ្ញា ភិក្ខវេ ភាវិតា ។ល។

(៦៦៥) វិនីលកសញ្ញា ភិក្ខវេ ។

(៦៦៦) វិច្ឆិទ្ទកសញ្ញា ភិក្ខវេ ។

(៦៦៧) ឧទ្ធុមាតកសញ្ញា ភិក្ខវេ ។

(៦៦៨) មេត្តា ភិក្ខវេ ភាវិតា ។

(៦៦៩) ករុណា ភិក្ខវេ ភាវិតា ។

(៦៧០) មុទិតា ភិក្ខវេ ភាវិតា ។

(៦៧១) ឧបេក្ខា ភិក្ខវេ ភាវិតា ។

(៦៧២) អានាបានស្សតិ ភិក្ខវេ ភាវិតា ។

(៦៧៣) អសុភសញ្ញា ភិក្ខវេ ភាវិតា ។



(៦៦៤) ម្នាលភិក្ខុទាំងឡាយ បុឡុវកសញ្ញា ដែលបុគ្គលចំរើនហើយ ។ល។

(៦៦៥) ម្នាលភិក្ខុទាំងឡាយ វិនីលកសញ្ញា ។

(៦៦៦) ម្នាលភិក្ខុទាំងឡាយ វិច្ឆិទ្ទកសញ្ញា ។

(៦៦៧) ម្នាលភិក្ខុទាំងឡាយ ឧទ្ធុមាតកសញ្ញា ។

(៦៦៨) ម្នាលភិក្ខុទាំងឡាយ មេត្តាដែលបុគ្គលបានចំរើនហើយ ។

(៦៦៩) ម្នាលភិក្ខុទាំងឡាយ ករុណាដែលបុគ្គលបានចំរើនហើយ ។

(៦៧០) ម្នាលភិក្ខុទាំងឡាយ មុទិតាដែលបុគ្គលបានចំរើនហើយ ។

(៦៧១) ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាដែលបុគ្គលបានចំរើនហើយ ។

(៦៧២) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចំរើនហើយ ។

(៦៧៣) ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញាដែលបុគ្គលបានចំរើនហើយ ។

(៦៥៤) មរណសញ្ញា ភិក្ខវេ ភាវិតា ។

(៦៥៥) អាហារេ បដិក្កូលសញ្ញា ភិក្ខវេ ។

(៦៥៦) សព្វលោកេ អនភិរតសញ្ញា ភិក្ខវេ ។

(៦៥៧) អនិច្ចសញ្ញា ភិក្ខវេ ។

(៦៥៨) អនិច្ចេ ទុក្ខសញ្ញា ភិក្ខវេ ។

(៦៥៩) ទុក្ខេ អនត្តសញ្ញា ភិក្ខវេ ។

(៦៦០) បហានសញ្ញា ភិក្ខវេ ។

(៦៦១) វិរាគសញ្ញា ភិក្ខវេ ។

(៦៦២) និរោធសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ កថំ ភាវិតា ច ភិក្ខវេ និរោធសញ្ញា កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ និរោធសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ និរោធសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេក-



(៦៥៤) ម្នាលភិក្ខុទាំងឡាយ មរណសញ្ញាដែលបុគ្គលបានចំរើនហើយ ។

(៦៥៥) ម្នាលភិក្ខុទាំងឡាយ អាហារេបដិក្កូលសញ្ញា ។

(៦៥៦) ម្នាលភិក្ខុទាំងឡាយ សព្វលោកេ អនភិរតសញ្ញា ។

(៦៥៧) ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញា ។

(៦៥៨) ម្នាលភិក្ខុទាំងឡាយ អនិច្ចេ ទុក្ខសញ្ញា ។

(៦៥៩) ម្នាលភិក្ខុទាំងឡាយ ទុក្ខេ អនត្តសញ្ញា ។

(៦៦០) ម្នាលភិក្ខុទាំងឡាយ បហានសញ្ញា ។

(៦៦១) ម្នាលភិក្ខុទាំងឡាយ វិរាគសញ្ញា ។

(៦៦២) ម្នាលភិក្ខុទាំងឡាយ និរោធសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះនិរោធសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយនិរោធសញ្ញា ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយនិរោធសញ្ញា អាស្រ័យ

និស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ និរោធសញ្ញា ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

(៦៦៣) និរោធសញ្ញាយ ភិក្ខវេ ភាវិតាយ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ កថំ ភាវិតាយ ភិក្ខវេ និរោធសញ្ញាយ កថំ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ



នូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ និរោធសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ជាគុណជាតមានផលច្រើន មានអានិសង្សច្រើន ។

(៦៦៣) ម្នាលភិក្ខុទាំងឡាយ កាលបើនិរោធសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ បណ្តាផលទាំង២ ផលណាមួយក៏កើតជាក់ស្តែង គឺបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើឧបាទាននៅមានសេសសល់ គឺនឹងបានអនាគាមិផលដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះនិរោធសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ទើបបណ្តាផលទាំង២ ផលណាមួយក៏កើតជាក់ស្តែង គឺបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើឧបាទាននៅមានសេសសល់

អនាគាមិតា ។ ឥធ ភិក្ខវេ ភិក្ខុ មរណសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ មរណសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតាយ ខោ ភិក្ខវេ មរណសញ្ញាយ ឯវំ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

[៦៦៤] មរណសញ្ញា ភិក្ខវេ ភាវិតា ពហុលីកតា មហតោ អត្ថាយ សំវត្តតិ ។ មហតោ យោគក្ខេមាយ សំវត្តតិ ។ មហតោ សំវេគាយ សំវត្តតិ ។ មហតោ ផាសុវិហារាយ សំវត្តតិ ។ កថំ ភាវិតា ច ភិក្ខវេ មរណសញ្ញា កថំ ពហុលីកតា មហតោ អត្ថាយ សំវត្តតិ ។ មហតោ យោគក្ខេមាយ សំវត្តតិ ។ មហតោ សំវេគាយ សំវត្តតិ ។ មហតោ ផាសុវិហារាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ មរណសញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ



ក៏គង់បានអនាគាមិផលវិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយមរណសញ្ញា ។ បេ ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយមរណសញ្ញា ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ មរណសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ បណ្តាផលទាំង ២ ផលណាមួយក៏កើតដល់ខ្លួន គឺបានអរហត្តផលក្នុងបច្ចុប្បន្ន ឬបើឧបាទាននៅមានសេសសល់ ក៏គង់បានអនាគាមិផលវិញ ។

[៦៦៤] ម្នាលភិក្ខុទាំងឡាយ កាលបើមរណសញ្ញា ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។ ប្រព្រឹត្តទៅដើម្បីក្សេមចាកយោគៈធំ ។ ប្រព្រឹត្តទៅដើម្បីសេចក្តីសង្វេគធំ ។ ប្រព្រឹត្តទៅដើម្បីការនៅជាសុខធំ ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណសញ្ញា ដែលបុគ្គលបានចំរើនហើយដូចម្តេច បានធ្វើឲ្យច្រើនហើយដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។ ប្រព្រឹត្តទៅដើម្បីក្សេមចាកយោគៈធំ ។ ប្រព្រឹត្តទៅដើម្បីសេចក្តីសង្វេគធំ ។ ប្រព្រឹត្តទៅដើម្បីការនៅជាសុខធំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ប្រកបដោយមរណសញ្ញា

។ បេ ។ និរោធសញ្ញាសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ និរោធសញ្ញា ឯវំ ពហុលីកតា មហតោ អត្ថាយ សំវត្តតិ ។ មហតោ យោគក្ខេមាយ សំវត្តតិ ។ មហតោ សំវេគាយ សំវត្តតិ ។ មហតោ ផាសុវិហារាយ សំវត្តតីតិ ។

[៦៦៨] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ កថញ្ច ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។



។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ប្រកបដោយនិរោធសញ្ញា អាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើនិរោធសញ្ញា ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំ ។ ប្រព្រឹត្តទៅដើម្បីក្សេមចាកយោគៈធំ ។ ប្រព្រឹត្តទៅដើម្បីសេចក្តីសំវេគធំ ។ ប្រព្រឹត្តទៅដើម្បីការនៅជាសុខធំ ។

[៦៦៨] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គា ហូរទំនាបទៅខាងកើត ដាក់ចុះទៅខាងកើត ឈមទៅខាងកើត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងជ្រាលទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងជ្រាលទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ។បេ។

ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្ពាននិន្នោ ហោតិ និព្ពានបោណោ និព្ពានបព្ភារោតិ ។ (យាវ ឯសនា បាលិ វិត្ថារេតព្វា) ។

(៦៦៦) បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ សត្ត ពោជ្ឈង្គា ភាវេតព្វា ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ



ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីប្រាសចាកតម្រេក អាស្រ័យការរលត់ បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងជ្រាលទៅកាន់ព្រះនិព្វាន ទេរទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន យ៉ាងនេះឯង ។ (គប្បីសំដែងបាលីឲ្យពិស្តារដរាបដល់ការស្វែងរកផងចុះ) ។

(៦៦៦) ម្នាលភិក្ខុទាំងឡាយ ឧទ្ធម្ភាគិយសំយោជនៈនេះមាន ៥ យ៉ាង ។ ឧទ្ធម្ភាគិយសំយោជនៈទាំង ៥ តើដូចម្ដេចខ្លះ ។ គឺរូបរាគៈ ១ អរូបរាគៈ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ នេះឯង ហៅថាឧទ្ធម្ភាគិយសំយោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវចំរើនពោជ្ឈង្គទាំង ៧ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧទ្ធម្ភាគិយសំយោជនៈ ៥ នេះចេញ ។ ចំរើនពោជ្ឈង្គទាំង ៧ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យសេចក្ដីប្រាសចាកតម្រេក អាស្រ័យការរលត់

វោស្សគ្គបរិណាមឹ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សំយោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ សត្ត ពោជ្ឈង្គា ភាវេតព្វាតិ ។

(៦៦៧) សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ កថញ្ច ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។



បង្អោនទៅកាន់ការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវចំរើនពោជ្ឈង្គទាំង ៧ នេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នេះឯង ។

(៦៦៧) ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គា មានទំនាបទៅទិសកើត ដំណាលទៅទិសកើត ឈមទៅទិសកើត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងប្រាលទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងប្រាលទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ។ បេ ។

ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សត្ត ពោជ្ឈង្គេ ភាវេន្តោ សត្ត ពោជ្ឈង្គេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។ (ឯវំ រាគវិនយបរិយោសានំ យាវ ឯសនា បាលិ វិត្ថារេតព្វា) ។

[៦៦៨] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ សត្ត ពោជ្ឈង្គា ភាវេតព្វា ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ រាគវិនយ-



ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលមានការលះបង់រាគៈជាទីបំផុត មានការលះបង់ទោសៈជាទីបំផុត មានការលះបង់មោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើនពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងជ្រាលទៅរកព្រះនិព្វាន ទន់ទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វានយ៉ាងនេះឯង ។ (ត្រូវពង្រីកសេចក្ដីឲ្យពិស្ដារ ទាំងអំពីឯសនា រហូតដល់ការលះបង់រាគៈជាទីបំផុតយ៉ាងនេះផងចុះ) ។

[៦៦៨] ម្នាលភិក្ខុទាំងឡាយ ឧទ្ធម្ភាគិយសំយោជនៈនេះមាន ៥ យ៉ាង ។ ឧទ្ធម្ភាគិយសំយោជនៈ ៥ យ៉ាងតើដូចម្ដេចខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ នេះឯង ហៅថាឧទ្ធម្ភាគិយសំយោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវចំរើនពោជ្ឈង្គទាំង ៧ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវឧទ្ធម្ភាគិយសំយោជនៈ ៥ នេះចេញ ។ ចំរើនពោជ្ឈង្គទាំង ៧ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលមានការលះបង់

បរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិ-យោសានំ អមតោគធំ អមតបរាយនំ អមតបរិយោ-សានំ និព្វាននិន្នំ និព្វានបោណំ និព្វានបព្ភារំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោ-ជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ សត្ត ពោជ្ឈង្គា ភាវេតព្វា ។ (យថា មគ្គសំ-យុត្តំ វិត្ថារេតព្វំ តថា ពោជ្ឈង្គសំយុត្តំ វិត្ថារេតព្វំ) ។

## ឧទ្ទានំ

អដ្ឋិបុឡវកាវិនីលកំ
វិច្ឆិទ្ទកំ ឧទ្ធុមាតេន បញ្ចមំ
មេត្តា ករុណា មុទិតា ឧបេក្ខា
អានាបានេន តេ ទសាតិ ។

ពោជ្ឈង្គសំយុត្តស្ស អានាបានវគ្គោ សត្តមោ ។



រាគៈជាទីបំផុត មានការលះបង់ទោសៈជាទីបំផុត មានការលះបង់មោហៈជាទីបំផុត ជាធម៌យាន្ដចុះកាន់ព្រះនិព្វាន ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ព្រោលទៅរកព្រះនិព្វាន ទន់ទៅរកព្រះនិព្វាន លំបាទៅរកព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចំរើនពោជ្ឈង្គ ទាំង ៧ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧទ្ធម្ភាគិយសំយោជនៈ ៥ នេះឯង ។ (មគ្គសំយុត្ត បណ្ឌិតត្រូវធ្វើឲ្យពិស្ដារយ៉ាងណា ពោជ្ឈង្គសំយុត្ត ក៏ត្រូវធ្វើឲ្យពិស្ដារយ៉ាងនោះដែរ) ។

## ឧទ្ទានក្នុងអានាបានាទិបេយ្យាលនោះគឺ

អដ្ឋិកសញ្ញា ១ បុឡវកសញ្ញា ១ វិនីលកសញ្ញា ១ វិច្ឆិទ្ទក-សញ្ញា ១ ឧទ្ធុមាតកសញ្ញា ១ ជាគំរប់ប្រាំ មេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ អានាបានៈ ១ រួមទាំងអស់ជា ១០ ។

ចប់ ពោជ្ឈង្គសំយុត្ត អានាបានវគ្គ ទី ៧ ។

គង្គាបេយ្យាលោ

អសុភា មរណា អាហារេ

បដិក្កូលេន ច សព្វលោកេ

អនិច្ចទុក្ខអនត្តប្បហានំ

វិរាគំ និរោធេន តេ ទសាតិ ។

ពោជ្ឈង្គសំយុត្តស្ស និរោធវគ្គោ អដ្ឋមោ ។

(៦៦៨) សាវត្ថីនិទានំ ។ សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។បេ។

ឆ បាចីនតោ និន្នា

ឆ និន្នា ច សមុទ្ទតោ

ទ្វេ តេ ឆ ទ្វាទស ហោន្តិ

វគ្គោ តេន បវុច្ចតីតិ ។

គង្គាបេយ្យាលោ នវមោ ។



គង្គាបេយ្យាល

អសុភសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ទុក្ខេអនត្តសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ រួមទាំងអស់ត្រូវជា ១០ អគ់ ។

ចប់ ពោជ្ឈង្គសំយុត្ត និរោធវគ្គ ទី ៨ ។

(៦៦៨) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គា មានទំនាបទៅខាងកើត ជំរាលទៅខាងកើត ឈមទៅខាងកើត យ៉ាងណាមិញ ។បេ។

និយាយអំពីទន្លេគង្គា ដែលទំនាបទៅខាងកើត ៦ លើក ទន្លេគង្គាមានទំនាបទៅរកសមុទ្រ ៦ លើក ទាំង ៦ លើក ៦ ដងនោះ រួមជា ១២ លើក ហេតុនោះបានជាលោកឲ្យឈ្មោះថាវគ្គ ។

ចប់ គង្គាបេយ្យាល ទី ៩ ។

(៦៧១) យាវតា ភិក្ខវេ សត្តា អបាទា វា ទ្វិបាទា វា ចតុប្បាទា វា ពហុប្បាទា វា ភវេ វិត្ថារេតព្វំ ។

គជាគតំ បទំ កូដំ

មូលំ សារេន វស្សិកំ(១)

រាជា ចន្ទិមសុរិយា ច

វត្ថេន ទសមំ បទំ ។

(អប្បមាទវគ្គោ ពោជ្ឈង្គសំយុត្តស្ស ពោជ្ឈង្គវសេន វិត្ថារេតព្វោ) ។

ពោជ្ឈង្គសំយុត្តស្ស អប្បមាទវគ្គោ ទសមោ ។

---

១ ស្យាំ៍ ផលំ ឈយោ ។



(៦៧០) ពាក្យថា ម្នាលភិក្ខុទាំងឡាយ រាប់តាំងពីពួកសត្វមិន មានជើងក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី បណ្ឌិត ត្រូវធ្វើឲ្យពិស្តារដូចគ្នា ។

ព្រះតថាគត ប្រសើរជាងសត្វទាំងអស់ ១ ស្នាមជើងដំរី ធំជាង ស្នាមជើងសត្វទាំងអស់ ១ កំពូលផ្ទះ ខ្ពស់ជាងគ្រឿងផ្ទះទាំង អស់ ១ ក្លិនឫសស្លា ប្រសើរជាងក្លិនឫសទាំងអស់ ១ ក្លិន ខ្លឹមចន្ទន៍ក្រហម ប្រសើរជាងក្លិនខ្លឹមទាំងអស់ ១ ក្លិនផ្កាម្លិះ ប្រសើរជាងក្លិនផ្កាទាំងអស់ ១ ស្តេចចក្រពត្តិ ប្រសើរជាង ស្តេចទាំងអស់ ១ ពន្លឺព្រះចន្ទ ប្រសើរជាងពន្លឺផ្កាយទាំង អស់ ១ ព្រះអាទិត្យស្រឡៀវក្នុងសរទសម័យ ១ សំពត់កាសិក- វស្ត្រ ប្រសើរជាងសំពត់ទាំងអស់ ១ ត្រូវជា ១០ គត់ ។

(អប្បមាទវគ្គ បណ្ឌិតត្រូវធ្វើឲ្យពិស្តារ តាមចំនួនពោជ្ឈង្គ នៃ ពោជ្ឈង្គសំយុត្តដូចគ្នា) ។

ចប់ ពោជ្ឈង្គសំយុត្ត អប្បមាទវគ្គ ទី ១០ ។

(៦៧១) សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករីយន្តិ វិត្ថារេតព្វំ ។

ពលំ ពីជញ្ច នាគោ ច

រុក្ខោ កុម្ភេន សូកិយា

អាកាសេន ច ទ្វេ មេឃា

នាវា អាគន្តុកា នទី ។

(ពលករណីយវគ្គោ ពោជ្ឈង្គសំយុត្តស្ស ពោជ្ឈង្គវសេន វិភាវេតព្វោ) ។

ពលករណីយវគ្គោ ឯកាទសមោ ។





(៦៧១) ពាក្យថា ម្នាលភិក្ខុទាំងឡាយ ដូចការងារណាមួយ ដែលត្រូវធ្វើដោយកម្លាំង ដូច្នេះជាដើម បណ្ឌិតត្រូវសំដែងឲ្យពិស្ដារផងចុះ ។

ការងារដែលត្រូវធ្វើដោយកម្លាំង ១ ពីជ តាមខ្ទិនសូត្រតាម (កស្រួយផែនដី ទើបលូតលាស់ឡើងបាន) ១ នាគ (កម្រាយគុំហិមពាន្ត ទើបធំធាត់កាយបាន) ១ ដើមឈើទ្រេតទៅទិសខាងកើត កាលបើគេកាត់គល់ រមែងរលំទៅទិសខាងកើត ១ ឆ្នាំងផ្កាប់ ទឹកមិនដែលហូរចូល ១ ចុងស្រូវនៃស្រូវ គេដាក់មិនស្រួល តែនឹងមុតដៃជើង ១ ខ្យល់លើអាកាសរមែងបក់ទៅគ្រប់ទិស ១ អាកាសមេឃ បក់ផាត់ធូលីឲ្យស្រឡះ ១ ខ្យល់ព្យុះ បក់ផាត់មេឃហោរមេឃឲ្យស្រឡះ ១ ទំណនីនាក់សមុទ្រ ទៅនឹងពុកផុយ ១ ផ្ទះសំណាក់អ្នកដំណើរ ១ ទន្លេគង្គា (ដែលមានចំណោតទៅទិសខាងកើត មិនអាចអ្នកណាបំបែរឲ្យមានចំណោតទៅខាងទិសខាងលិចវិញបាន) ១ ។

(ពលករណីយវគ្គ បណ្ឌិតត្រូវសំដែងឲ្យពិស្ដារ តាមទំនងពោជ្ឈង្គ នៃពោជ្ឈង្គសំយុត្តនេះចុះ) ។

ចប់ ពលករណីយវគ្គ ទី ១១ ។

(៦៧៦) តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនាតិ វិត្ថារេតព្វំ ។

ឯសនា វិធា អាសវា
ភវា ច ទុក្ខតា តិស្សោ
ខីលំ មលំ ច នីឃោ ច
វេទនា តណ្ហាយេន ចាតិ ។

(ពោជ្ឈង្គសំយុត្តស្ស ឯសនាបេយ្យាលំ វិវេក-និស្សិតោ [illegible] វិត្ថារេតព្វំ) ។

ឯសនាវគ្គោ ទ្វាទសមោ ។

(៦៧៧) ចត្តារោមេ ភិក្ខវេ ឱឃា ។ កតមេ ចត្តារោ ។ កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោ-ឃោតិ វិត្ថារេតព្វំ ។



(៦៧៦) ពាក្យថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាង តើដូចម្តេចខ្លះ ។ ការស្វែងរក ៣ យ៉ាង គឺនេះ ការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយធម៌ ១ ប៉ុណ្ណេះជាដើម បណ្ឌិតត្រូវចំរើនឲ្យពិស្តារផងចុះ ។

និយាយពីការស្វែងរកផ្សេងៗ ១ អាសវៈ ១ ភព ១ ទុក្ខតា-
ធម៌ ៣ យ៉ាង ១ (កិលេស) ដូចជាសសរទ្រូង ១ មន្ទិល ១
សេចក្តីលំបាក ១ វេទនា ១ តណ្ហា ១ ។

(ឯសនាបេយ្យាលនៃពោជ្ឈង្គសំយុត្ត អ្នកប្រាជ្ញទាំងឡាយត្រូវសំដែងឲ្យពិស្តារតាមវិវេកនិស្សិតផងចុះ) ។

ចប់ ឯសនាវគ្គទី ១២ ។

(៦៧៧) ពាក្យថា ម្នាលភិក្ខុទាំងឡាយ ឱឃៈនេះមាន ៤ យ៉ាង ។ ឱឃៈ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ឱឃៈ ៤ យ៉ាង គឺនេះ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ប៉ុណ្ណេះជាដើម បណ្ឌិតត្រូវចំរើនឲ្យពិស្តារផងចុះ ។

(២៧៤) សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ សត្ត ពោជ្ឈង្គា ភាវេតព្វា ។ កតមេ សត្ត ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ អមតោគធំ អមតបរាយនំ អមតបរិយោសានំ និព្វាននិន្នំ និព្វានពោណំ និព្វានបព្ភារំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ សត្ត ពោជ្ឈង្គា ភាវេតព្វាតិ ។



(២៧៤) សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឧទ្ធម្ភាគិយសំយោជនៈនេះមាន ៥ យ៉ាង ។ ឧទ្ធម្ភាគិយសំយោជនៈ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ឧទ្ធម្ភាគិយសំយោជនៈ ៥ គឺ រូបរាគ ១ អរូបរាគ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៥ នេះឈ្មោះឧទ្ធម្ភាគិយសំយោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ភិក្ខុគប្បីចំរើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧទ្ធម្ភាគិយសំយោជនៈ ៥ នេះឯង ។ ចំរើនពោជ្ឈង្គ ៧ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យការរលត់ បង្អោនទៅកាន់ការលះបង់ ។បេ។ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលមានការលះបង់រាគៈជាទីបំផុត មានការលះបង់ទោសៈជាទីបំផុត មានការលះបង់មោហៈជាទីបំផុត ចុះស៊ប់ទៅរកព្រះនិព្វាន មានព្រះនិព្វាននៅខាងមុខ មានព្រះនិព្វានជាទីបំផុត ប្រាលទៅរកព្រះនិព្វាន ឱនទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ បណ្ឌិតគប្បីចំរើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នេះឯង ។

ឱឃោ យោគោ ឧបាទានំ
គន្ថា អនុសយេន ច
កាមគុណា នីវរណា
ខន្ធា ឧទ្ធម្ភាគិយានីតិ ។

ឱឃវគ្គោ នវមោ ។

ឆ បាចីនតោ និន្នា
ឆ និន្នា ច សមុទ្ទតោ
ទ្វេតេ ឆ ទ្វាទស ហោន្តិ
វគ្គោ តេន បវុច្ចតិ ។

(ពោជ្ឈង្គសំយុត្តស្ស គង្គាបេយ្យាលំ រាគវសេន វិត្ថារេតព្វំ) ។

វគ្គោ ទ្វាទសមោ ។

តថាគតំ បទំ កូដំ
មូលំ សារេន វស្សិកំ[១]
រាជា ចន្ទិមសុរិយា ច

១ វុច្ចតិ ឥតិ បាឋោ ។



និយាយពីឱឃ:១ យោគ:១ ឧបាទាន១ គន្ថ:១ អនុស័យ១ កាមគុណ១ នីវរណ:១ ខន្ធ១ ឧទ្ធម្ភាគិយសំយោជន:១ ។

ចប់ ឱឃវគ្គទី ៩ ។

និយាយអំពីទន្លេគង្គាមានទំនាបទៅខាងកើត ៦ លើក ទន្លេគង្គាមានទំនាបទៅកាន់សមុទ្រ ៦ លើក ទាំង ៦ លើក ២ ដង ត្រូវជា ១២ លើក ហេតុនោះទ្រង់ហៅថាវគ្គ ។ (គង្គាបេយ្យាលនៃពោជ្ឈង្គសំយុត្ត បណ្ឌិតត្រូវសំដែងឲ្យពិស្ដារ តាមចំណែករាគៈផង) ។

ចប់ វគ្គទី ១២ ។

ព្រះតថាគត ប្រសើរជាងសត្វទាំងអស់១ ស្នាមជើងដំរី ធំជាងស្នាមជើងសត្វទាំងអស់១ កំពូលផ្ទះ ខ្ពស់ជាងគ្រឿងផ្ទះទាំងអស់១ ក្លិនឫសស្លា ប្រសើរជាងក្លិនឫសទាំងអស់១ ក្លិនខ្លឹមចន្ទន៍ក្រហម ប្រសើរជាងក្លិនខ្លឹមទាំងអស់១ ក្លិនផ្កាម្លិះ ប្រសើរជាងក្លិនផ្កាទាំងអស់១ ស្ដេចក្សត្រ ប្រសើរជាងស្ដេចទាំងអស់១ រស្មីព្រះចន្ទ្រ ប្រសើរជាងរស្មីផ្កាយទាំងអស់១ ព្រះអាទិត្យរុងរឿងក្នុងសរទសម័យ១

ឯសតក្ខ

វត្ថូន ឧសបំ បត់ ។

(អប្បមាណវគ្គា ភគវសេន វិត្ថារតោ) ។

បណ្ណាសកោ ។

តស់ ពីជញ្ញ ធាតោ ច

ក្ខេត្តមេត្ត សុកាយា

អាគតសេន ច ខ្ទេ មេឃា

ឋាកំ អាគន្តុកា នធី ។

(ពោជ្ឈង្គសំយុត្តស្ស ពលការណីយវគ្គា ភគវ-

សេន វិត្ថារតោ) ។

សោឡសកោ ។

ឯសតក្ខ

សំគាល់ការសិក្សាស្ត្រ ប្រាសាទដាក់សំគាល់តាំងនិងសំ ។ ក្រៅពី

១០ គត់ ។

(អប្បមាទវគ្គ ក្រៅពីនេះនៅក្នុងរឿងពិស្តារតាមចំនួនក្នុងនិទ្ទេស)

ចប់ វគ្គទី ១៨ ។

ការងារដែលធ្វើដោយកម្លាំង ។ ពីជតាមចំនីក្នុងតាម (ការ-

ស្រុយដំរើបលូតលាស់បាន) ។ នាគ (ការស្រុយក្នុងហិមពាន្ត

ទើបធំរើនធំបាន) ។ ដើមឈើទ្រេតទៅទិសខាងកើត ។ ឆ្នាំង

ផ្កាប់ ទឹកមិនដែលហូរចូល ។ ចុងស្រួចនៃស្រូវ ដេកក់

មិនស្រួល ដែលមុតដៃជើង ។ ធូលីលើអាកាស ដែលបក់

ទៅគ្រប់ទិស ។ អាកាសមេឃ បក់ផាត់ផង់ធូលីឲ្យស្រះ-

ឡះ ៤ លើក ចំណាប់នាវាសមុទ្រ ដែលពុកផុយ ។ ផ្ទះ

សម្រាប់អ្នកដំណើរ ។ មហានទី (ដែលមានទំនាបទៅទិស

ខាងកើត មិនអាចអ្នកណាបំបែរឲ្យមានទំនាបទៅទិសខាង

លិចវិញបាន) ។ ។

(ពលករណី រោជ្ឈង្គសំយុត្ត បណ្ដាក្រៅពីរឿងពិស្តារ

តាមចំនួនក្នុងនិទ្ទេស,

ចប់ វគ្គទី ១៦ ។

ឯសនា វិធា អាសវោ

ភវោ ច ទុក្ខតា តិស្សោ

ខីលំ មលំ ច នីឃោ ច

វេទនា តណ្ហាយេន ច ។

ពោជ្ឈង្គសំយុត្តស្ស ឯសនាវគ្គោ សត្តរសមោ ។

ឱឃោ យោគោ ឧបាទានំ

គន្ថា អនុសយេន ច

កាមគុណា នីវរណា

ខន្ធា ឱរម្ភាគិយា ចាតិ ។

(រាគវិនយបរិយោសានទោសវិនយបរិយោសាន-មោហវិនយបរិយោសានវសេន ឱឃវគ្គោ វិត្ថារេតព្វោ) ។

អដ្ឋារសមោ ។

(យថា ច មគ្គសំយុត្តំ វិត្ថារិតំ តថា ពោជ្ឈង្គសំយុត្តំ វិត្ថារេតព្វំ) ។

ពោជ្ឈង្គសំយុត្តំ សមត្តំ ។



និយាយពីការស្វែងរកផ្សេងៗ ១ អាសវៈ ១ ភព ១ ទុក្ខតា-ធម៌ ៣ យ៉ាង ១ (កិលេស) ដូចសសរទ្រូង ១ មន្ទិល ១ សេចក្តីលំបាក ១ វេទនា ១ តណ្ហា ១ ។

ចប់ ឯសនាវគ្គ នៃពោជ្ឈង្គសំយុត្ត ទី ១៧ ។

និយាយអំពីឱឃៈ ១ យោគៈ ១ ឧបាទាន ១ គន្ថៈ ១ អនុ-សយ ១ កាមគុណ ១ នីវរណៈ ១ ខន្ធ ១ ឱរម្ភាគិយ-សំយោជនៈ ១ ។

(ឱឃវគ្គ បណ្ឌិតត្រូវសំដែងឲ្យពិស្តារតាមចំណែកនៃការលះបង់រាគ ទោសៈ មោហៈ ជាទីបំផុតផងចុះ) ។

ចប់ វគ្គទី ១៨ ។

(មគ្គសំយុត្ត បណ្ឌិតបានធ្វើឲ្យពិស្តារហើយបែបណា ពោជ្ឈង្គ-សំយុត្ត ក៏ត្រូវសំដែងឲ្យពិស្តារបែបនោះដែរ) ។

ចប់ ពោជ្ឈង្គសំយុត្ត ។